

# រក្សាសុវត្ថិភាពកុមារពី ការរំលោភបំពានផ្លូវភេទ

## កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួល ក្នុងវេទិកាពិភាក្សា ជាមួយអ្នកតំណាងសហគមន៍

Australian Aid

World Vision

**រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ**

កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួល ក្នុងវេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍

ISBN: 978-0-9925215-0-9

រក្សាសិទ្ធិ © ឆ្នាំ ២០១៤ ដោយអង្គការទស្សនៈពិភពលោកកម្ពុជា

សម្ភារនៅក្នុងឯកសារបោះពុម្ពផ្សាយនេះអាចយកទៅប្រើប្រាស់ និងកែសម្រួលបាន ឱ្យតែមានការបញ្ជាក់ប្រភពឯកសារត្រឹមត្រូវថាបានដកស្រង់ពីប្រភពឯកសារនេះ។ អ្នកអាចទាញយកឯកសារអេឡិចត្រូនិចពីគេហទំព័រ http://www.childsafetourism.org ឬ http://wvi.org/asiapacific/childsafetourism ។ សូមផ្ញើសំណួរ ឬយោបល់ត្រឡប់ទៅកាន់អ៊ីម៉ែល childsafetourism@wvi.org.

**រូបថត៖** រូបថតទាំងអស់គឺរក្សាសិទ្ធិដោយអង្គការទស្សនៈពិភពលោក។ រូបថតទំព័រមុខដោយ Jon Warren ។ រូបកុមារដែលប្រើក្នុងសម្ភារអប់រំនេះគ្រាន់តែជាការលម្អប៉ុណ្ណោះ គម្រោងកុមារភាពមិនយករូបពិតរបស់កុមាររងគ្រោះដោយការរំលោភបំពានមកប្រើទេ។ អង្គការទស្សនៈពិភពលោកធ្វើការដោយយោងតាមបទដ្ឋានការពារកុមារក្នុងការថតរូបរបស់កុមារ ។

**រចនាដោយ៖** Inís Communication. មានលំនាំតាមជាភាសាខ្មែរ កែសម្រួលដោយ រចនាឌីហ្សាញ

គម្រោងកុមារភាពគឺជាការផ្តួចផ្តើមគំនិតមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារឱ្យរួចផុតពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (ឆ្នាំ ២០១១-២០១៤)។



# រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ

## កញ្ចប់ឧបករណ៍សម្រាប់អ្នកសម្របសម្រួលក្នុងវេទិកាពិភាក្សា ជាមួយអ្នកតំណាងសហគមន៍

# សេចក្តីថ្លែងអំណរគុណ

ការបង្កើតឲ្យមានកញ្ចប់ឧបករណ៍ស្តីពីវេទិកាពិភាក្សា ដែលស្ថិតក្រោមកិច្ចដឹកនាំរបស់ Aarti Kapoor ប្រធានកម្មវិធី និង Afrooz Kaviani Johnson ប្រធានផ្នែកបច្ចេកទេស គម្រោងកុមារភាព ផ្នែកបង្ការ បានទទួលការចូលរួមពីសំណាក់មនុស្ស និងអង្គការជាច្រើន។ សូមថ្លែងអំណរគុណចំពោះទីប្រឹក្សាម្នាក់ គឺ Anita Dodds ដែលបានរៀបចំធ្វើអត្ថបទពង្រៀងលើកទីមួយ នៃសៀវភៅស្តីពីវេទិកាពិភាក្សាក្នុងឆ្នាំ២០១២។ សូមថ្លែងអំណរគុណចំពោះលោក ផង់ ចិន្តា, Chalermrat Chaiprasert, Chansamone Bouakhamvongsa និង Nguyen Khanh Hoi អ្នកសម្របសម្រួលថ្នាក់ជាតិសម្រាប់គម្រោងកុមារភាព ផ្នែកបង្ការ នៃប្រទេសកម្ពុជា ថៃឡាវ និងប្រទេសវៀតណាម ដែលបានចូលរួមចំណែកត្រួតពិនិត្យ និងកែសម្រួល រួមទាំងប្រើប្រាស់ថ្នាក់ជាតិ នូវកញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សាចាប់ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៤។ លើសពីនេះ ក៏សូមថ្លែងអំណរគុណ ចំពោះគោលគំនិត និងព័ត៌មានត្រឡប់វិញសំខាន់ៗ ដែលបានមកពីសហការី រាប់បញ្ចូលទាំង Kristine Mikhailidi អ្នកឯកទេសផ្នែករៀបចំកម្មវិធីការពារកុមាររបស់អង្គការទស្សនៈពិភពលោកអន្តរជាតិ និងដៃគូនានានៅតាមទីកន្លែងដែលបានប្រើប្រាស់គំនិតអប់រំសំខាន់ៗទាំងនេះ។ សូមអរគុណចំពោះ Verity Kowal ជាមន្ត្រីផ្សព្វផ្សាយ និងទំនាក់ទំនងនៃគម្រោងកុមារភាព ផ្នែកបង្ការ ដែលបានជួយបញ្ចប់ការបោះពុម្ពសៀវភៅណែនាំស្តីពីវេទិកាពិភាក្សាក្នុងឆ្នាំ២០១៤។ សូមថ្លែងអំណរគុណផងដែរចំពោះ លោក ហ៊ីម ជា និង លោកស្រី សាយ សុម៉ាលី សមាជិកក្រុមការងារនៃ គម្រោងកុមារភាពផ្នែកបង្ការ និង លោកស្រី ស៊ីម សុជាតា ជាទីប្រឹក្សា ដែលបានចូលរួមក្នុងការបង្កើតសម្ភារនេះឡើងជាភាសាខ្មែរ ។

# មាតិកា


អារម្ភកថា ii

សារតា iv

គោលបំណងនៃកញ្ចប់ឧបករណ៍ស្តីពីវេទិកាពិភាក្សា v

របៀបប្រើប្រាស់ កញ្ចប់ឧបករណ៍ស្តីពីវេទិកាពិភាក្សា vi

ផ្នែកទី១៖ ការចាប់ផ្តើម 1

- តើអ្នកណាអាចសម្របសម្រួលវេទិកាពិភាក្សានេះបាន? 3
- តើអ្នកណា គួរចូលរួមក្នុងវេទិកាពិភាក្សានេះ? 3
- តើលទ្ធផលរំពឹងទុកពីវគ្គសិក្សានេះមានអ្វីខ្លះ? 5
- ដើម្បីរៀបចំវេទិកាពិភាក្សា តើត្រូវការអ្វីខ្លះ? 6
- តើគេត្រូវការពេលប៉ុន្មាន ដើម្បីដំណើរការវេទិកានេះ? 8
- គោលការណែនាំពិសេស សម្រាប់ការបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារ 10

ផ្នែកទី២៖ ការណែនាំតាមរយៈស្លាយ 13

ផ្នែកទី៣៖ ឧបសម្ព័ន្ធ 57

- ឧបសម្ព័ន្ធទី១៖ កាតយកតាមខ្លួន 59
- ឧបសម្ព័ន្ធទី២៖ ទម្រង់វត្តមានសម្រាប់អ្នកចូលរួម 72
- ឧបសម្ព័ន្ធទី៣៖ សំណួរមុនចូលមេរៀន 73
- ឧបសម្ព័ន្ធទី៤៖ សំណួរក្រោយមេរៀន 74
- ឧបសម្ព័ន្ធទី៥៖ កាតឆ្លើយតបចំពោះសំណួរមុនចូលមេរៀន និងក្រោយមេរៀន 75
- ឧបសម្ព័ន្ធទី៦៖ ទម្រង់គំរូវិភាគលើសំណួរមុនចូលមេរៀន និងក្រោយមេរៀន 76
- ឧបសម្ព័ន្ធទី៧៖ សេណារីយ៉ូករណីសិក្សានៃអ្នកតំណាងសហគមន៍ 77
- ឧបសម្ព័ន្ធទី៨៖ ទម្រង់ស្តីពីទស្សនៈរបស់ខ្ញុំ 80
- ឧបសម្ព័ន្ធទី៩៖ ទម្រង់គំរូរបាយណ៍ក្រោយការបណ្តុះបណ្តាល 82

# អារម្ភកថា



វិស័យទេសចរណ៍នៅប្រទេសកម្ពុជា មានការរីកចម្រើនជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស។ នៅឆ្នាំ២០១៣ ប្រទេសកម្ពុជាបានទទួលស្វាគមន៍ដំណើរកំសាន្តរបស់ភ្ញៀវទេសចរអន្តរជាតិចំនួន ៤.២លាននាក់ ដោយចំនួននេះ បានកើនឡើង ១៧%ធៀបនឹងឆ្នាំ២០១២។ ការអភិវឌ្ឍន៍វិស័យទេសចរណ៍ កំពុងនាំមកនូវឱកាសជាច្រើនសម្រាប់ ប្រទេសកម្ពុជា និងសហគមន៍នានា។

ក្នុងពេលជាមួយគ្នានេះ យើងក៏បានសង្កេតឃើញនូវចំណុចអវិជ្ជមាននៃទំនាក់ទំនងរវាងវិស័យទេសចរណ៍ និងការកេងប្រវ័ញ្ចលើកុមារ។ នៅក្នុងប្រទេសកម្ពុជា យើងបានឃើញកុមារងាយរងគ្រោះ និងក្រុមគ្រួសាររបស់កុមារទាំងនោះ ត្រូវបានទាក់ទាញឲ្យចូលទៅកាន់ទីកន្លែងគោលដៅទេសចរណ៍ ដើម្បីរកប្រាក់ចំណូល។ កុមារា និងកុមារី អាចធ្វើការនៅក្នុងឧស្សាហកម្មទេសចរណ៍ នៅក្នុងលក្ខខណ្ឌ ដែលមិនអំណោយផលដល់សុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។ កុមារដែលរកប្រាក់ចំណូលបានពីភ្ញៀវទេសចរ តាមរយៈការ លក់វត្ថុអនុស្សាវរីយ៍ ឬការខាត់ស្បែកជើង ទំនងជាមិនសូវបានទៅសាលារៀនឡើយ។ កុមារទាំងនេះ ត្រូវប្រឈមមុខនឹងភាពងាយរងគ្រោះក្នុងកម្រិតខ្ពស់ នៅក្នុងការរំលោភបំពានលើរាងកាយ  អារម្មណ៍ និងផ្លូវភេទ។

នៅក្នុងអនុតំបន់ទន្លេមេគង្គ ទាំងកុមារា ទាំងកុមារី គឺជារឿយៗបានក្លាយខ្លួនជាជនរងគ្រោះដោយការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ រួមទាំងក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ កុមារដែលធ្វើការនៅតាមចិញ្ចើមថ្នល់ ឬក្នុងវិស័យក្រៅប្រព័ន្ធ គឺជាគោលដៅរបស់អ្នករំលោភបំពានផ្លូវភេទកុមារ។ ក្រៅពីនេះ អ្នករំលោភបំពានអាចនឹងតម្រង់ឆ្ពោះទិសទៅរកកុមារងាយរងគ្រោះ តាមរយៈការបរើការងារនៅក្នុងសាលារៀន ឬសេវាថែទាំកុមារ តាមមណ្ឌលនានា។

ក្នុងនាមជារដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការនៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ខ្ញុំសូមទទួលស្គាល់ និងឲ្យតម្លៃយ៉ាងខ្ពស់ចំពោះគម្រោងកុមារភាព ដែលរដ្ឋាភិបាលអូស្ត្រាលីបានបង្កើតឲ្យមានការវិនិយោគមួយយ៉ាងសំខាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងទម្រង់នៃការកេងប្រវ័ញ្ចដ៏ជាក់លាក់នេះនៅក្នុងអនុតំបន់ទន្លេមេគង្គ។ គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដែលបានចំណាយប្រាក់ ៧.៥ លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរក្នុងអនុតំបន់ទន្លេមេគង្គ (២០១១-២០១៤)។ គម្រោងកុមារភាពនេះ ពឹងផ្អែកលើការជួយឧបត្ថម្ភក្នុងរយៈពេលវែងរបស់ប្រទេសអូស្ត្រាលីសម្រាប់កម្មវិធីនានាដើម្បីបង្ការ និងការពារ ការរំលោភបំពានមកលើកុមារឲ្យបានកាន់តែប្រសើរឡើង។

គម្រោងកុមារភាព បាននាំមកនូវកិច្ចសហប្រតិបត្តិការគ្នា រវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម ដើម្បីឆ្លើយតបទៅនឹងបញ្ហាដ៏ធ្ងន់ធ្ងរនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍។ គម្រោងនេះដំណើរការនៅក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម។ គម្រោងនេះ ប្រើប្រាស់ទាំងវិធីបង្ការ និងការពារ។

នៅក្នុង ប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោក កំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍នានា និងរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា ដើម្បីការពារកុមារា និងកុមារីឲ្យរួចផុតពីការការក្លាយខ្លួនជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទ ទាំងនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។

តាមការស្រាវជ្រាវរបស់អង្គការទស្សនៈពិភពលោកបានបង្ហាញថា មានកង្វះខាតយ៉ាងខ្លាំងផ្នែកចំណេះដឹង និងការយល់ដឹងនៅកម្រិតសហគមន៍ពាក់ព័ន្ធទៅនឹងប្រធានបទ "អ្វីជាការរំលោភបំពានផ្លូវភេទ ហើយតើវាអាចកើតឡើងដូចម្តេច ?"។  យើងដឹងថា អ្នករំលោភបំពានឆក់យកឱកាសទាញយកប្រយោជន៍ពីកង្វះខាតចំណេះដឹង និងការយល់ខុសទាំងនេះ ដើម្បីធ្វើការរំលោភបំពានលើកុមារា និងកុមារី។ វាចាំបាច់ណាស់ក្នុងការចែករំលែកព័ត៌មានច្បាស់លាស់ត្រឹមត្រូវ ទៅឲ្យសមាជិកសហគមន៍ អំពីការរំលោភបំពានផ្លូវភេទ និងវិធីការពារការរំលោភបំពានទាំង នេះ។ អ្នកតំណាងសហគមន៍មានតួនាទីមួយយ៉ាងសំខាន់ សម្រាប់បង្កើតបរិយាកាសមួយក្នុងសហគមន៍ដែលអាចថែរក្សាកុមារឲ្យមានសុវត្ថិភាពពីការរំលោភបំពាន និងដើម្បីការពារមិនឲ្យមានការកើតមានឡើង ឬការបន្តនូវការរំលោភបំពាន។ វាពិតជាមានសារៈសំខាន់ណាស់ដែលអ្នកតំណាងសហគមន៍ទាំងឡាយទទួលបាននូវព័ត៌មានច្បាស់លាស់ និងទាន់សភាពការណ៍ពីការរំលោភបំពានកុមារ ព្រមទាំងយល់ដឹងពីវិធីសាស្ត្រធ្វើការរួមគ្នាដើម្បីបង្កើតបរិយាកាសមួយប្រកបដោយសុវត្ថិភាពនៅក្នុងសហគមន៍ សាលារៀន សាលាឃុំ មន្ទីរពេទ្យ និងទីកន្លែងសាធារណៈផ្សេងទៀត។

ការទទួលខុសត្រូវក្នុងការការពារកុមារ ត្រូវតែចាត់ទុកជាអាទិភាពសំខាន់ជាងគេសម្រាប់មនុស្សពេញវ័យគ្រប់រូប។ កុមារមិនត្រូវទទួលការស្តីបន្ទោស ដោយការរំលោភបំពានមកលើខ្លួនឡើយ។ ក្នុងនាមជាសមាជិកសហគមន៍ ដែលស្ថិតក្នុងមុខដំណែងជារដ្ឋអំណាច ជាថ្នាក់ដឹកនាំ និងជាអ្នកមានឥទ្ធិពល  អ្នកតំណាងសហគមន៍ទាំងអស់ គឺស្ថិតក្នុងមុខតំណែងដ៏សំខាន់ក្នុងការឆ្លើយតប និងដាក់ចេញនូវវិធានការសុវត្ថិភាពឲ្យអនុវត្ត ដើម្បីការពារសិទ្ធិកុមារ ពីការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ។

ហេតុនេះហើយ រក្សាកុមារពីការរំលោភបំពានផ្លូវភេទ៖ កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍មានតម្លៃគួរត្រូវបោះពុម្ពមែន។ សៀវភៅនេះផ្តល់នូវការណែនាំងាយស្រួលអនុវត្តតាម និងសម្ភារឧបទេសផ្សេងៗដែលអាចឲ្យអ្នកសម្របសម្រួលប្រើប្រាស់ដើម្បីរៀបចំវេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍។ សៀវភៅនេះមានព័ត៌មាន ដែលអ្នកសម្របសម្រួលត្រូវការ ដើម្បីរៀបចំមេរៀនការប្រាស្រ័យទាក់ទងគ្នា ទាំងក្នុងបរិបទជាផ្លូវការ និងក្រៅផ្លូវការ ដោយប្រើប្រាស់សម្ភារតិចតួច ឬដោយប្រើបច្ចេកវិទ្យា។  គំនិតនានានៅក្នុងសៀវភៅណែនាំនេះ ត្រូវបានអង្គការនានា យកមកប្រើប្រាស់រួចហើយនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំសង្ឃឹមថា តាមរយៈការបោះពុម្ពផ្សព្វផ្សាយជាផ្លូវការនេះ សៀវភៅនេះនឹងផ្តល់ព័ត៌មានដល់មន្ត្រីរដ្ឋាភិបាល មេភូមិ មេឃុំ ប៉ូលីសឃុំ បុគ្គលិកបម្រើការសង្គម  បុគ្គលិកបម្រើការងារយុវជន មន្ត្រីអប់រំ និងសមាជិកក្នុងសហគមន៍នានាកាន់ច្រើនឡើងទូទាំងប្រទេសកម្ពុជា និងផ្តល់អំណាចឲ្យពួកគាត់ដើម្បីថែរក្សាការពារកុមារនៅក្នុងសហគមន៍របស់ពួកគាត់ឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទជាមិនខាន។

ខ្ញុំសូមលើកទឹកចិត្តឲ្យមានការប្រើប្រាស់ដ៏ទូលំទូលាយនូវអត្ថបទបោះពុម្ពនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលអូស្ត្រាលី និងអង្គការទស្សនៈពិភពលោកសម្រាប់ការវិនិយោគ និងការបំពេញការងារដ៏ល្អប្រពៃរបស់ខ្លួន។

**ហត្ថលេខា**

ជូ_ប៊ុនអេង

# សារតា

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភផ្លូវភេទក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរនៅប្រទេសកម្ពុជា ឡាវ ថៃ និង ប្រទេសវៀតណាម (២០១១-២០១៤)។ គម្រោងកុមារភាពនេះ បានមកនូវកិច្ចសហការរវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ គម្រោងនេះ ប្រើប្រាស់ទាំងវិធីសាស្ត្របង្ការ និងការពារ។

អង្គការទស្សនៈពិភពលោក បានសហការជាដៃគូជាមួយអាជ្ញាធរ និងសហគមន៍នានា ដើម្បីការពារកុមារមិនឲ្យក្លាយជាជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ តាមរយៈព័ត៌មាន ការអប់រំ និងការទំនាក់ទំនង អង្គការទស្សនៈពិភពលោក មានគោលដៅផ្តល់ជូននូវចំណេះដឹង និងជំនាញនានា ដល់សមាជិកសហគមន៍ ក្រុមហ៊ុនអាជីវកម្ម និងមន្ត្រីអាជ្ញាធរនានា ដើម្បីបង្កើតបរិស្ថានទេសចរណ៍មួយ ដែលកាន់តែមានសុវត្ថិភាពប្រសើរឡើងសម្រាប់កុមារ។

ដោយផ្អែកលើលទ្ធផលស្រាវជ្រាវ ស្តីពីការយល់ដឹងរបស់សហគមន៍ទៅលើការរំលោភបំពានផ្លូវភេទកុមារ ការអប់រំ និងការផ្សព្វផ្សាយរបស់គម្រោងកុមារភាពផ្អែកបង្ការ បានផ្តល់ព័ត៌មានថ្មី និងសមស្របទៅតាមទំនៀមទម្លាប់ ដើម្បីបំពេញកង្វះខាតចំណេះដឹង និងបើកបង្ហាញនូវអាថ៌កំបាំង និងការយល់ខុសនានា ពីការរំលោភបំពានផ្លូវភេទកុមារ ដែលអាចទុកឲ្យកុមារងាយនឹងត្រូវរងគ្រោះដោយសារការរំលោភបំពាន។ អ្នកតំណាងសហគមន៍ (អ្នកទទួលបន្ទុកនៅក្នុងសហគមន៍ដែលមានមុខងារ ជាអ្នកមានអំណាច ជាអ្នកដឹកនាំ និងជាអ្នកមានឥទ្ធិពល) មានតួនាទីយ៉ាងសំខាន់ ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពាន និងដើម្បីការពារមិនឲ្យការរំលោភបំពានកើតឡើង និង/ឬមានជាបន្តទៀត។ វាចាំបាច់ដែលត្រូវទទួលបានព័ត៌មានថ្មីៗនិងត្រឹមត្រូវ ស្តីពីការរំលោភបំពានផ្លូវភេទលើកុមារ។

# គោលបំណងនៃកញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សា

វេទិកាពិភាក្សាជាមួយតំណាងសហគមន៍ ជាម៉ោងសិក្សាខ្លីមួយ ហើយអាចកែសម្រួលបាន ដើម្បីធ្វើឲ្យអ្នកចូលរួមមានចំណេះដឹងនិងជំនាញ ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទនៅក្នុងសហគមន៍របស់ខ្លួន។ វេទិកាពិភាក្សានេះ អាចត្រូវបានរៀបចំ និងត្រូវដឹកនាំដោយនាយកដ្ឋានដែលពាក់ព័ន្ធនានារបស់រដ្ឋាភិបាល ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (ឬស្ថាប័នផ្សេងទៀតដែលមានអំណាចស្មើគ្នា) ឬតាមរយៈអង្គការសហគមន៍ដែលបានបង្កើតរួចហើយ និងមានទំនាក់ទំនងជាមួយសហគមន៍ដែលឆ្លងកាត់បទពិសោធន៍លើបញ្ហាការពារកុមារ។ កញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សានេះផ្តល់ការណែនាំ និងឧបករណ៍ងាយស្រួលដល់អ្នកសម្របសម្រួល ដើម្បីដំណើរការវេទិកាពិភាក្សាដែលមានរយៈពេលពីរឬបីម៉ោង ជាមួយអ្នកតំណាងសហគមន៍។ កញ្ចប់ឧបករណ៍នេះ មានព័ត៌មានទាំងអស់ដែលសំខាន់ និងចាំបាច់សម្រាប់ម៉ោងសិក្សា។ ខ្លឹមសារនៅក្នុងកញ្ចប់ឧបករណ៍នេះ មានអត្ថប្រយោជន៍សម្រាប់ទាំងការជួបជុំក្រៅផ្លូវការនានាក្នុងសហគមន៍ នៅថ្នាក់ភូមិឬថ្នាក់ស្រុក ព្រមទាំងក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈជាផ្លូវការនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ។ អ្នកសម្របសម្រួលគួរតែអានកញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សានេះឲ្យបានច្បាស់ មុននឹងចាប់ផ្តើមកម្មវិធីណាមួយ ហើយត្រូវប្រើសៀវភៅនេះ ដើម្បីជួយរៀបចំវេទិកាពិភាក្សានេះឲ្យបានល្អ។ កញ្ចប់ឧបករណ៍នេះ អាចមានការកែសម្រួល និងការបន្ថែម ដើម្បីផ្លាស់ប្តូរគំនិតទាំងនោះឲ្យសមស្របទៅនឹងអ្នកចូលរួម។ អ្នកអាចទាញយកឯកសារជាអេឡិចត្រូនិចនៃកញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សានេះបានពីគេហទំព័រ http://www.childsafetourism.org និងគេហទំព័រ http://wvi.org/asiapacific/childsafetourism។

# របៀបប្រើប្រាស់កញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សា

កញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សាមានបីផ្នែក ៖

## ផ្នែកទី១ ៖ ការចាប់ផ្តើម

ផ្នែកនេះ ផ្តល់អ្វីគ្រប់យ៉ាង ដែលអ្នកសម្របសម្រួលត្រូវដឹង និងរៀបចំជាចាំបាច់ មុននឹងរៀបចំធ្វើវេទិកាពិភាក្សានេះឡើង។ ផ្នែកនេះ មានយោបល់នានាដែលមានប្រយោជន៍ ស្តីអំពីការជ្រើសរើសអ្នកចូលរួម ការរៀបចំទីកន្លែង និងសម្ភារ ព្រមទាំងមានគំនិតទាក់ទងនឹងការណែនាំពិសេស សម្រាប់ដោះស្រាយបញ្ហាចាំបាច់នានាស្តីពីការរំលោភបំពានផ្លូវភេទលើកុមារ។

## ផ្នែកទី២៖ ការណែនាំតាមរយៈស្លាយ

ផ្នែកនេះ ផ្តល់ការណែនាំជាជំហានៗ ដើម្បីជួយដល់អ្នកសម្របសម្រួលក្នុងការផ្តល់គំនិតនៅក្នុងវេទិកាពិភាក្សា។ អ្នកអាចទាញយកបទបង្ហាញតាមផាវើរ៍ផ៉ញ ស្តីពីអ្នកតំណាងសហគមន៍ ពីគេហទំព័រ http://www.childsafetourism.org និងគេហទំព័រ http://wvi.org/asiapacific/childsafetourism ហើយគួរតែត្រួតពិនិត្យ និងកែសម្រួលឯកសារនេះឲ្យបានសមរម្យមុនពេលបើកវេទិកាពិភាក្សា ដើម្បីបញ្ចូលខ្លឹមសារដែលពាក់ព័ន្ធនៅក្នុងប្រទេស និង/ឬនៅថ្នាក់មូលដ្ឋាន។ បើគ្មានឧបករណ៍បញ្ចាំងស្លាយទេ ឬមិនអាចព្រីនចេញនូវស្លាយដែលនៅលើក្រដាសផ្ទាំងធំនោះបានទេ អ្នកសម្របសម្រួលអាចយកផ្នែកការណែនាំតាមរយៈស្លាយ នេះមកធ្វើជាកំណត់ត្រាសម្រាប់និយាយវិញ។ ការណែនាំតាមរយៈស្លាយ ក៏មានបញ្ចូលសកម្មភាពចូលរួមនានាទៅតាមសំណើដែរ ព្រមទាំងផ្តល់គន្លឹះផ្សេងៗដល់អ្នកសម្របសម្រួល ដើម្បីជំរុញការពិភាក្សា និង/ឬគំនិតឆ្លុះបញ្ចាំងរបស់អ្នកចូលរួមទៀតផង។

## ផ្នែកទី៣៖ ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទាំងនេះ មានបន្ថែមឧបករណ៍សម្រាប់ធ្វើវេទិកាពិភាក្សានេះ និងសម្រាប់វាយតម្លៃកម្មវិធីនោះ ដើម្បីជាការសិក្សាបន្ថែមទៀត។ ឧបសម្ព័ន្ធទាំងនេះ រួមមាន ៖

- កាតយកតាមខ្លួន
- ទម្រង់វត្តមានសម្រាប់អ្នកចូលរួម
- សំណួរមុនចូលមេរៀន និងសំណួរក្រោយមេរៀន
- កាតឆ្លើយតបចំពោះសំណួរមុនចូលមេរៀន និងសំណួរក្រោយមេរៀន
- ទម្រង់គំរូវិភាគលើសំណួរមុនចូលមេរៀន និងសំណួរក្រោយមេរៀន
- សេណារីយ៉ូករណីសិក្សាស្តីពីអ្នកតំណាងសហគមន៍
- ទម្រង់ទស្សនៈរបស់ខ្ញុំ
- ទម្រង់គំរូរបាយណ៍ក្រោយការបណ្តុះបណ្តាល

## ផ្នែកទី១៖

# ការចាប់ផ្តើម



# ការចាប់ផ្តើម

## តើនរណាអាចសម្របសម្រួលវេទិកាពិភាក្សានេះបាន ?

ដោយសារវេទិកាពិភាក្សានេះ លើកឡើងពីបញ្ហាចាំបាច់នានានៃការរំលោភបំពានផ្លូវភេទ អ្វីដែលសំខាន់ គឺត្រូវជ្រើសរើសអ្នកសម្របសម្រួលដោយយកចិត្តទុកដាក់ ដោយអ្នកសម្របសម្រួលទាំងនោះ ត្រូវមានសមត្ថភាពសមរម្យ និងមានជំនាញក្នុងការចែកចាយគំនិតនេះ។

គេរំពឹងថា អ្នកសម្របសម្រួលមានទាំងចំណេះដឹង និងជំនាញ ដូចខាងក្រោម ៖

- ជាអ្នកជំនាញដែលមានចំណេះដឹងពីបញ្ហាការពារកុមារ ដោយមានការយល់ដឹងពិសេស អំពីការរំលោភបំពានផ្លូវភេទកុមារ។
- មានបទពិសោធន៍ចាំបាច់លើការអប់រំសហគមន៍ សម្របសម្រួល បង្រៀន និង/ឬការបណ្តុះបណ្តាល
- មានសមត្ថភាពក្នុងការទំនាក់ទំនងបានច្បាស់លាស់ មានប្រសិទ្ធិភាព ព្រមទាំងសម្រេចបាននូវលទ្ធផលល្អក្នុងការរៀនសូត្រ តាមរយៈការប្រើប្រាស់វិធីសាស្ត្រដែលមានការចូលរួម។

អ្នកសម្របសម្រួល មិនត្រឹមតែត្រូវមានភាពងាយស្រួលក្នុងការពិភាក្សាពីប្រធានបទនៃការរំលោភបំពានលើកុមារជាពិសេសការរំលោភបំពានផ្លូវភេទប៉ុណ្ណោះទេ ពួកគាត់ថែមទាំងត្រូវតែអាចគ្រប់គ្រងបញ្ហាលំបាកផ្សេងៗដែលពាក់ព័ន្ធ និងដែលកើតឡើងនៅក្នុងការពិភាក្សាទាំងនេះទៀតផង។ បញ្ហាទាំងនេះ រួមមានបញ្ហាបច្ចេកទេស និងបញ្ហាមិនច្បាស់លាស់នានា ដែលអាចនឹងកើតមានចំពោះអ្នកចូលរួមនានា ដែលខ្លួនគាត់ផ្ទាល់ ប្រហែលជាបានទទួលរងនូវការរំលោភបំពានរួចទៅហើយនោះ។ បើគិតទៅលើបញ្ហាដែលត្រូវពិភាក្សានៅក្នុងវេទិកានេះ ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហាបំពានផ្លូវភេទ វានាំឲ្យមានការជាប់ទាក់ទងទៅនឹងទំនាក់ទំនងផ្លូវភេទរវាងមនុស្ស និងមនុស្ស ទោះដោយមានការព្រមព្រៀងគ្នាក្តី ឬមិនព្រមព្រៀងគ្នាក្តី។ ត្រូវមានការយកចិត្តទុកដាក់និងប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីធានាថា អ្នកសម្របសម្រួលពិតជាមិនប្រកាន់ឥរិយាបថ ឬគំនិតរើសអើងឡើយ ទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី រួមទាំងទាក់ទងនឹងទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ ការប្រកាន់នូវគំនិតរើសអើងដោយផ្អែកលើយេនឌ័រ ទំនោរផ្លូវភេទ ពូជសាសន៍។ល។ គឺមិនស្របទៅនឹងសិទ្ធិជាសាកលរបស់កុមារឡើយ ហើយវាក៏ជាការរួមចំណែកនៅក្នុងការធ្វើឲ្យមានភាពងាយរងគ្រោះនានា ដែលដាក់កុមារឲ្យស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរំលោភបំពានទៀតផង។ គោលការណ៍ណែនាំពិសេសអំពីការបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារ ត្រូវបានបញ្ចូលទៅក្នុងកញ្ចប់ឧបករណ៍សម្រាប់វេទិកាពិភាក្សានេះ។

## តើនរណាគួរចូលរួមក្នុងវេទិកាពិភាក្សា ?

វេទិកាពិភាក្សានេះ ត្រូវបានរៀបចំឡើងសម្រាប់អ្នកតំណាងសហគមន៍។ អ្នកតំណាងសហគមន៍ មានដូចជាបុគ្គលិករដ្ឋាភិបាលក្នុងសហគមន៍ ដែលមានមុខតំណែងមានសមត្ថកិច្ច ជាអ្នកដឹកនាំ និងជាអ្នកដែលមានឥទ្ធិពលជាពិសេសគឺទាក់ទងនឹងបញ្ហាកុមារ។ ហេតុនេះវេទិកាពិភាក្សានេះ គឺសក្តិសមបំផុតសម្រាប់មនុស្សដូចខាងក្រោម ( និងអ្នកផ្សេងទៀត )៖

- អ្នកដឹកនាំសហគមន៍
- គ្រូបង្រៀន
- អ្នកបំរើការងារផ្នែកសង្គមកិច្ច និងយុវជន

- អ្នកបំរើការងារផ្នែកសុខភាព វេជ្ជបណ្ឌិត គិលានុបដ្ឋាក គ្រូខ្មែរ
- អ្នកដឹកនាំសាសនា
- មន្ត្រីប៉ូលីសមូលដ្ឋាន
- ចាស់ព្រឹទ្ធាចារ្យ
- មន្ត្រី/អ្នកដឹកនាំភូមិ/ស្រុក/ឃុំ
- អ្នកតំណាងអង្គការសហគមន៍ដែលពាក់ព័ន្ធ
- អ្នកសារព័ត៌មាននៅមូលដ្ឋាន









# តើលទ្ធផលរំពឹងទុកពីវគ្គសិក្សានេះមានអ្វីខ្លះ ?

នៅចុងបញ្ចប់នៃការពិភាក្សា តំណាងសហគមន៍គួរតែអាច ៖

- យល់ពីអ្វីដែលហៅថា ការរំលោភបំពានផ្លូវភេទកុមារ។
- ស្គាល់ពីផលប៉ះពាល់ការរំលោភបំពានចំពោះកុមារ គ្រួសារ និងសហគមន៍ នៅក្នុងមូលដ្ឋានក្នុងប្រទេស តំបន់ និងថ្នាក់ជាតិ។
- យល់ថា កុមារដែលជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ មិនត្រូវទទួលរងនូវការស្ដីបន្ទោសសម្រាប់ការរំលោភបំពាននោះឡើយ។
- យល់បញ្ហាជាក់លាក់នៃការរំលោភបំពានផ្លូវភេទលើកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ
- ពិចារណាអំពីការទទួលខុសត្រូវរបស់ខ្លួន ក្នុងការលើកកំពស់សិទ្ធិកុមារក្នុងការទទួលបានកិច្ចការពារពីរាល់ទម្រង់នៃការរំលោភបំពាន និងកេងប្រវ័ញ្ចទាំងអស់។
- ស្គាល់សូចនាករទាំងឡាយដែលបញ្ជាក់ថា កុមារម្នាក់ប្រហែលជាកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ។
- កំណត់ព័ត៌មានដែលពួកគេធ្វើសកម្មភាពប្រសិនបើទទួលបានព័ត៌មានកុមារម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពាន ឬព័ត៌មានថា កុមារកំពុងត្រូវបានគេរំលោភបំពាន។
- ដឹងពីរបៀបចាប់ផ្ដើមបង្កើតយន្តការសំខាន់ៗ ដើម្បីជួយកុមារ និងគ្រួសារ ដែលបានក្លាយជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទហើយនេះ។



# ដើម្បីរៀបចំវេទិកាពិភាក្សា តើត្រូវការអ្វីខ្លះ ?

### អ្នកចូលរួម

- វេទិកាពិភាក្សា សក្តិសមបំផុតសម្រាប់អ្នកចូលរួមចំនួន២០-២៥ នាក់។ ចំនួននេះអនុញ្ញាតិឲ្យមានការពិភាក្សា និងការចែករំលែកបទពិសោធន៍ប្រកបដោយផ្លែផ្កា។
- ប្រសិនបើចំនួនអ្នកចូលរួមឡើងលើសពី៤០នាក់ ការពិភាក្សាជាក្រុម និងព័ត៌មានត្រឡប់វិញ អាចត្រូវចំណាយពេលយូរ ហើយត្រូវការពេលវេលាបន្ថែមទៀតសម្រាប់វេទិកាពិភាក្សានេះ។
- ជួនកាល វាជារឿងមួយចាំបាច់ ដែលត្រូវចុះទៅដល់ក្រុមតូចៗជាងនេះ ឬក្រុមធំៗជាងនេះ។ ចំណុចនេះអាចធ្វើបាន ហើយអ្នកសម្របសម្រួលនឹងត្រូវកែសម្រួលរបៀបបំផុសឲ្យមានការចូលរួមរបស់ក្រុមឲ្យកាន់តែមានប្រសិទ្ធិភាពឡើយ។
- បើតាមលក្ខណៈនៃខ្លឹមសារនេះ ចាំបាច់ត្រូវធានាថា អ្នកចូលរួមគឺជាមនុស្សដែលមានអំណាច មានភាពជាអ្នកដឹកនាំនិងមានឥទ្ធិពលនៅក្នុងសហគមន៍។
- អ្វីដែលសំខាន់ផងដែរនោះ គឺត្រូវធ្វើឲ្យមានតុល្យភាពយេនឌ័រ  (ទាំងបុរស និងស្រ្តី) នៅពេលអញ្ជើញអ្នកចូលរួមក្នុងវេទិកាពិក្សានេះ។
- **ឧបសម្ព័ន្ធទី២** រួមមាន ទម្រង់វត្តមានសម្រាប់អ្នកចូលរួម អាចត្រូវបានប្រើប្រាស់សម្រាប់កត់ត្រាព័ត៌មានលម្អិតរបស់អ្នកចូលរួម។

### ទីកន្លែង

- អ្នកសម្របសម្រួល គួរមានគោលដៅបង្កើតឲ្យមានបរិយាកាសមួយដែលអំណោយផលដល់ការសិក្សារៀនសូត្រ និងដែលស្ថិតនៅជិត និងមានផាសុកភាពចំពោះអ្នកចូលរួមតាមដែលអាចធ្វើទៅបាន។ គួរចាំថា ទីតាំងគឺជាកន្លែងដែលអ្នកចូលរួមធ្លាប់ស្គាល់ និងជាទីកន្លែងអព្យាក្រឹត្យ។ ឧទាហរណ៍៖ សាលាឆទានដែលនៅក្នុងមូលដ្ឋាន មណ្ឌលសហគមន៍។ល។ អ្នកសម្របសម្រួលគួរយកចិត្តទុកដាក់បំពេញតាមសេចក្តីត្រូវការពិសេសៗរបស់អ្នកចូលរួមដែលជាជនពិការ។
- ប្រសិនបើអាចធ្វើបាន គួររៀបចំទីកន្លែងក្នុងទម្រង់ជា "រង្វង់" ឬជា "អក្សរអ៊ុយ" តាមភាពងាយស្រួល។ ការរៀបចំបែបនេះ មានលក្ខណៈអំណោយផលដល់ការពិភាក្សាយ៉ាងសកម្ម។ មិនចាំបាច់ត្រូវមានតុ សម្រាប់វេទិកាជជែកពិភាក្សានេះទេ។ ក្នុងករណីមួយចំនួន អ្នកចូលរួមទាំងអស់អាចអង្គុយផ្ទាល់នៅលើឥដ្ឋ ឬនៅលើដី។
- ខ្លឹមសារនៃវេទិកាពិភាក្សានេះមានអត្ថប្រយោជន៍ ចំពោះកម្មវិធីបណ្តុះបណ្តាលជាផ្លូវការ ដែលនៅក្នុងនោះអ្នកចូលរួមគួរតែមានតុអង្គុយ និងជាការប្រសើរនៅកន្លែងដែលមានបម្រើភេសជ្ជៈផង។

**ទម្រង់ជា អក្សរអ៊ុយ**



ជាញឹកញាប់អ្នកសម្របសម្រួលប្រើទម្រង់នេះសម្រាប់វគ្គបណ្តុះបណ្តាល

**ទម្រង់ជា រង្វង់**



សក្តិសមសម្រាប់វគ្គបណ្តុះបណ្តាលមិនផ្លូវការ (គ្មានការរៀបចំតុ)

### សម្ភារ

- ការប្រើប្រាស់ជំនួយរូបភាព អាចជួយបង្កើនបទពិសោធន៍សិក្សារបស់អ្នកចូលរួម បានយ៉ាងច្រើន។ ដោយផ្អែកលើធនធានដែលមាន ជំនួយរូបភាពទាំងនោះអាចមានជាទម្រង់ផ្សេងៗ ។
- នៅកន្លែងដែលមានចរន្តអគ្គិសនី និងសម្ភារប្រើប្រាស់ អ្នកសម្របសម្រួលអាចប្រើឧបករណ៍បញ្ចាំងស្លាយ និងអេក្រង់ សម្រាប់ធ្វើបទបង្ហាញផៅវីដេអូ ស្តីពីអ្នកតំណាងសហគមន៍។ ករណីក្រៅពីនេះ វាជាការប្រសើរបំផុត និង/ឬគួរឲ្យទុកចិត្តបំផុតនោះ គឺប្រើប្រាស់សម្ភារដែលព្រីនចេញមក។

| | |
|---|---|
| | • ឧទាហរណ៍៖ បទបង្ហាញតាមរយៈផៅវើផ័ញ ស្តីពីអ្នកតំណាងសហគមន៍ ត្រូវព្រីនចេញលើក្រដាសផ្ទាំងធំ ឬបើមិនដូច្នេះទេ អ្នកសម្របសម្រួលអាចសរសេរសារសំខាន់ៗនៅលើក្រដាសធំក៏បាន។<br>• ក្រៅពីនេះ អ្នកសម្របសម្រួលអាចបើកវេទិកាពិភាក្សាបានដោយងាយ ដោយមិនប្រើរូបភាពជំនួយ។ |
| **ឯកសារសម្រាប់ចែកជូនអ្នកចូលរួម** | អាចរៀបចំឯកសារខាងក្រោមនេះ សម្រាប់ចែកជូនអ្នកចូលរួមនីមួយៗ ៖<br>• កាតយកតាមខ្លួន៖ **ឧបសម្ព័ន្ធទី១**<br>• កាតឆ្លើយសំណួរមុនចូលមេរៀន និងសំណួររំឭកមេរៀនសារឡើងវិញ៖ **ឧបសម្ព័ន្ធទី៣ និងទី៤** ( ជម្រើសមួយទៀត គឺអាចប្រើប្រាស់លំហាត់ដែលមានលក្ខណៈជាការប្រាស្រ័យទាក់ទងគ្នាដោយប្រើប្រាស់កាតឆ្លើយតបសំណួរមុនផ្តើមមេរៀន និងរំឭកមេរៀនឡើងវិញនៅក្នុងឧបសម្ព័ន្ធទី៥ )<br>• ទម្រង់បែបបទស្តីពីទស្សនៈរបស់ខ្ញុំ៖ **ឧបសម្ព័ន្ធទី៨** ( ជម្រើសមួយទៀត អាចនិយាយពិភាក្សាគ្នាបាន )។<br>• សេណារីយ៉ូករណីសិក្សានៃតំណាងសហគមន៍ **ឧបសម្ព័ន្ធទី៧** ( ជម្រើសមួយទៀត អាចនិយាយទំនាក់ទំនងគ្នាបាន )។<br>ឯកសារចែកជូន និង/ឬសកម្មភាពទាំងនេះ គួរត្រូវបានកែសម្រួលទៅតាមតម្រូវការដើម្បីធ្វើឲ្យអ្នកចូលរួមដែលមានសមត្ថភាពចម្រុះទាំងនោះ អាចចូលរួមបាន។ |
| **សម្ភារផ្សេងទៀត** | • ក្រដាសផ្ទាំងធំ ឬក្តាខៀនដីស<br>• ប៊ិចហ្វឺត ឬដីស និងកែបលុប<br>• បាល់ទន់ ( អាចជ្រើសរើសបាន ៖ សម្រាប់ណែនាំខ្លួនប្រាប់គ្នាទៅវិញទៅមក ) |



# តើត្រូវការរយៈពេលប៉ុន្មាន ដើម្បីដំណើរការវេទិកាពិភាក្សានេះ ?

វេទិកាពិភាក្សានេះ នឹងប្រព្រឹត្តទៅរយៈពេលបីម៉ោង ប៉ុន្តែបើត្រូវការចាំបាច់ អាចនឹងផ្តល់ការបណ្តុះបណ្តាលមួយដែលមានរយៈពេលយូរជាងនេះ គឺអាស្រ័យលើលំហាត់នានា និងវិធីចូលរួមដែលបានប្រើ។ កញ្ចប់ឧបករណ៍នេះ មានសកម្មភាពនានាដែលអាចជ្រើសរើសបាន និងដែលអាចប្រើប្រាស់សម្រាប់កម្មវិធីដែលមានរយៈពេលវែងជាងនេះ។

តារាងខាងក្រោមនេះ មានគោលដៅបង្ហាញពីផែនការពេលវេលាសម្រាប់ប្រធានបទ និងសកម្មភាពនីមួយៗ ហើយវាបង្ហាញជាគោលៗ នូវសកម្មភាពនានាដែលអាចជ្រើសរើសបាន ក្នុងករណីផែនការពេលវេលានោះ មានកំណត់។ នៅក្នុងការណែនាំតាមរយៈស្លាយ (ម៉ោងសិក្សាទី២) ស្លាយសំខាន់ៗ ក៏អាចត្រូវបានសម្គាល់ដោយអក្សរតេ។

| មេរៀន | ខ្លឹមសារមេរៀន | ភាពចាំបាច់ | អាចជ្រើសរើសបាន | រយៈពេល |
|---|---|---|---|---|
| **ការណែនាំខ្លួន** | ពិធីបើកកម្មវិធីពិភាក្សា | | ● | រហូត១ម៉ោង |
| | ការណែនាំខ្លួនពីអ្នកសម្របសម្រួល និងអ្នកចូលរួម៖ តើយើងមកទីនេះដើម្បីអ្វី ? | ● | | ១៥ នាទី |
| | សកម្មភាព៖ សំណួរមុនចូលមេរៀន | ● | | ១០ នាទី |
| **តើការរំលោភបំពានផ្លូវភេទកុមារគឺជាអ្វី ?** | តើអ្វីទៅជាការរំលោភបំពានលើកុមារ ? តើអ្វីទៅជាការរំលោភបំពានផ្លូវភេទកុមារ ? | ● | | រហូត ១៥ នាទី |
| | សំណួរសម្រាប់ឆ្លុះបញ្ចាំងពីគំនិត/ពិភាក្សា៖តើអ្នកធ្លាប់បានដឹងពីអ្វីខ្លះ ? | | ● | រហូត ១៥ នាទី |
| | ផលប៉ះពាល់នានា ដែលបណ្តាលមកពីការរំលោភបំពានផ្លូវភេទកុមារ | ● | | ៥ នាទី |
| **តើអ្នកតំណាងសហគមន៍ត្រូវដឹងព័ត៌មានអ្វីខ្លះ ?** | តើអ្នកណាខ្លះ គឺជាជនរងគ្រោះ ? | ● | | ៥ នាទី |
| | តើនរណា គឺជាអ្នករំលោភបំពាន ? តើអ្នកទាំងនោះ ប្រព្រឹត្តិដូចម្តេចខ្លះ ? | ● | | ២០ នាទី |
| | តើមានសញ្ញាអ្វីខ្លះ ដែលបង្ហាញឲ្យឃើញថាមានកុមារម្នាក់ អាចនឹងស្ថិតក្នុងគ្រោះថ្នាក់ ? | ● | | ២០ នាទី |
| | តើបច្ចេកវិជ្ជាឌីជីថល និងការរំលោភបំពានកុមារ មានទំនាក់ទំនងគ្នាដូចម្តេច ? | ● | | ១៥ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ គ្រោះថ្នាក់ដែលប៉ះពាល់ដល់សុវត្ថិភាពកុមារកើតឡើងដោសារបច្ចេកវិជ្ជាឌីជីថល។ | | ● | ៥ នាទី |
| | តើវិស័យទេសចរណ៍ មានទំនាក់ទំនងដូចម្តេចខ្លះ ជាមួយការរំលោភបំពានកុមារ ? | ● | | ១០ នាទី |
| | សំណួរបញ្ចាំង/ពិភាក្សា៖ គ្រោះថ្នាក់ដែលប៉ះពាល់ដល់សុវត្ថិភាពកុមារកើតឡើងដោយសារការរីកចម្រើននៃវិស័យទេសចរណ៍។ | | ● | ៥ នាទី |

| មេរៀន | ខ្លឹមសារមេរៀន | ភាពចាំបាច់ | អាចជ្រើសរើសបាន | រយៈពេល |
|---|---|---|---|---|
| **តើអ្នកតំណាងសហគមន៍ត្រូវមានការទទួលខុសត្រូវអ្វីខ្លះ ដែលត្រូវអនុវត្តទៅតាមច្បាប់ និងគោលនយោបាយ** | ច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធ | ● | | ១០ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ ផលប៉ះពាល់ទៅលើយុទ្ធសាស្ត្រ/ផែនការជាតិ | | ● | រហូត ១៥ នាទី |
| **តើយើងអាចត្រូវធ្វើសកម្មភាពអ្វីខ្លះដើម្បីការពារកុមារបានល្អ?** | សកម្មភាព៖ តើសហគមន៍របស់ខ្ញុំមានសុវត្ថិភាពកម្រិតណា? | | ● | រហូត ១០ នាទី |
| | បើកការពិភាក្សា និងការទំនាក់ទំនង | ● | | ១០ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ ឧទាហរណ៍ល្អៗ បង្ហាញពីការពិភាក្សាជាចំហ និងការទំនាក់ទំនង។ | | ● | រហូត ១៥ នាទី |
| | យុទ្ធសាស្ត្របង្ការ | ● | | ១០ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ ឧទាហរណ៍ល្អៗបង្ហាញពីយុទ្ធសាស្ត្របង្ការ | | ● | រហូត ១៥ នាទី |
| | ការការពារ | ● | | ៥ នាទី |
| | របៀបឆ្លើយតបទៅនឹងការប្រាប់ពីបញ្ហា | ● | | ១៥ នាទី |
| | សំណួរឆ្លុះបញ្ចាំង/ពិភាក្សា៖ និតិវិធីដែលត្រូវអនុវត្ត ប្រសិនបើកុមារម្នាក់ស្ថិតក្នុងគ្រោះថ្នាក់ | | ● | ៥ នាទី |
| | សកម្មភាព៖ សេណារីយ៉ូករណីសិក្សា | | ● | ២០ នាទី |
| | សកម្មភាព៖ការបង្កើតសហគមន៍មួយដែលធ្វើឲ្យមានសុវត្ថិភាពដល់កុមារ | | ● | ៣០ នាទី |
| **សន្និដ្ឋាន** | សកម្មភាព៖ ការវាយតម្លៃ | ● | | ១០ នាទី |
| | សកម្មភាព៖ សំណួរក្រោយមេរៀន | ● | | ១០ នាទី |
| | បញ្ចប់កម្មវិធី | ● | | ៥ នាទី |
| | ការបិទកម្មវិធី | | ● | រហូត ៣០ នាទី |

# គោលការណ៍ណែនាំពិសេសសម្រាប់ការបណ្តុះបណ្តាលស្តីពីការការពារកុមារ

## ត្រូវយកចិត្តទុកដាក់សម្របសម្រួលការពិភាក្សានេះឲ្យបានល្អ

ការរំលោភបំពានកុមារ ជាពិសេសការរំលោភបំពានផ្លូវភេទ គឺជាបញ្ហាមួយដែលងាយនឹងប៉ះពាល់ដល់អារម្មណ៍កុមារ ហើយត្រូវការជាចាំបាច់នូវការឆ្លុះបញ្ចាំង និងការពិចារណាពីសំណាក់អ្នកចូលរួម។ អ្នកចូលរួមគួរតែទទួលបានឱកាសឡើងមានយោបល់ ពីប្រធានបទនានា ដែលមិនមានលក្ខណៈប្រឈមមុខដាក់គ្នា ដូចដែលបានកំណត់នៅក្នុងការណែនាំតាមរយៈស្លាយ មុននឹងចាប់ផ្តើមការពិភាក្សាអំពីការរំលោភបំពានកុមារ។ តាមរយៈការធ្វើឲ្យអ្នកចូលរួម "បញ្ចេញមតិ" ក្នុងពេលធ្វើសកម្មភាពនានានៅពេលចាប់ផ្តើម ពួកគាត់នឹងមានអារម្មណ៍កាន់តែស្រួលក្នុងចិត្តក្នុងការនិយាយពីបញ្ហារំលោភបំពានកុមារ នៅពេលវេទិកាពិភាក្សានេះកំពុងមានដំណើរការ។

## ត្រូវរៀបចំជាស្រេចនូវព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង ដើម្បីផ្តល់សេវាពិគ្រោះយោបល់ប្រកបដោយវិជ្ជាជីវៈ ឬសេវាបញ្ជូន

អ្នកត្រូវដឹងថា អ្នកចូលរួមខ្លះអាចជាជនរងគ្រោះដោយសារការរំលោភបំពាន។ ដូច្នេះចាំបាច់ត្រូវចងចាំទុកក្នុងចិត្តថា មនុស្សផ្សេងគ្នាមានប្រតិកម្មខុសគ្នាចំពោះការរំលោភបំពាន។ ឧទាហរណ៍ មនុស្សខ្លះនឹងមិនបានគិតអំពីបញ្ហានេះទេពីមុន ឬក្នុងរយៈពេលយូរមកហើយ ហើយការពិភាក្សានេះ អាចនឹងនាំមកនូវការចងចាំដ៏សោកសៅ[១]។ ចាំបាច់ត្រូវយល់ពីអ្វីៗ ដែលអាចនឹង កើតឡើងបានគ្រប់ពេល។ បើអ្នកចូលរួមចង់និយាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ សូមឲ្យពួកគាត់និយាយនៅកន្លែងណាមួយដាច់ដោយឡែកពីគេ (នៅពេលសម្រាកឬនៅពេលបញ្ចប់ការពិភាក្សា)។ អ្នកសម្របសម្រួលគួរតែបានរៀបចំជាស្រេចនូវព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនង ដើម្បីផ្តល់សេវាពិគ្រោះយោបល់ប្រកបដោយវិជ្ជាជីវៈ ឬសេវាបញ្ជូនសម្រាប់អ្នកចូលរួមណាម្នាក់ ដែលចង់ពិភាក្សាលម្អិតពីស្ថានភាពរបស់ខ្លួន ។

## ត្រូវរាយការណ៍ជាបន្ទាន់ នូវការប្រាប់ការពិតអំពីកុមារម្នាក់ ដែលអាចឆ្លងកាត់បទពិសោធន៍នៃការរំលោភបំពាន

អ្នកចូលរួមខ្លះ ប្រហែលជាអាចនឹងចែករំលែកព័ត៌មានដែលបង្ហាញថា ក្នុងពេលនេះកុមារម្នាក់ អាចកំពុងជួបប្រទះការរំលោភបំពាននៅក្នុងគ្រួសាររបស់គេ សមាគមន៍ ឬនៅកន្លែងផ្សេងទៀត។ នៅពេលមានការលាតត្រដាងពីស្ថានភាពបែបនេះ អ្នកត្រូវតែយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ ដោយរក្សាការសម្ងាត់ និងចាត់វិធានការឲ្យបានទាន់ពេលវេលា ពីព្រោះកុមារម្នាក់កំពុងស្ថិតក្នុងគ្រោះថ្នាក់។ បើមានហេតុការណ៍ បែបនេះកើតឡើង ត្រូវជម្រាបដល់ទីភ្នាក់ងារមូលដ្ឋានដែលសមគួរ (រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានផង)។ អ្នកសម្របសម្រួលត្រូវស្គាល់ភ្នាក់ងារបញ្ជូននៅក្នុងមូលដ្ឋានដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតពីហេតុការណ៍ដែលបានបង្ហាញទាំងនេះ។ រាល់ហេតុការណ៍ដែលបានបង្ហាញត្រូវរាយការជាបន្ទាន់។

---

១. វាជាធម្មតាទេសម្រាប់មនុស្សដែលធ្លាប់រងការរំលោភបំពានផ្លូវភេទក្នុងការបំបាត់ការចងចាំរបស់ខ្លួនអំពីបទពិសោធន៍ជាយុទ្ធសាស្ត្រទប់ទល់មួយ

## ត្រូវចេះឆ្លើយតបនឹងសំណួរដែលពិបាក និង/ឬឥរិយាបថរំខាននានា

វាជាការចាំបាច់ក្នុងការគិតគូរ និងគោរពវប្បធម៌របស់អ្នកចូលរួម ប៉ុន្តែវប្បធម៌ មិនគួរប្រើជាលេសសម្រាប់ជាមូលហេតុសមស្របនៅក្នុងការរំលោភបំពានកុមារឡើយ។

ប្រហែលជាអាចមានសំណួរច្រើនពាក់ព័ន្ធនឹងទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ អ្នកសម្របសម្រួលគួរតែត្រៀមខ្លួនឲ្យរួចជាស្រេច ដើម្បីឆ្លើយតបនៅក្នុងការពិភាក្សាបែបនេះឲ្យបានច្បាស់លាស់និងត្រង់ទៅត្រង់មក។ អ្នកសម្របសម្រួលគួរតែសង្កត់ធ្ងន់ថា កុមារទាំងអស់មានសិទ្ធិទទួលបានកិច្ចការពារ ដោយមិនប្រកាន់ពីទំនោរផ្លូវភេទ និង/ឬ អត្តសញ្ញាណយេនឌ័រ ហើយភាពអាម៉ាស់ ការរើសអើង ឬការមិនអើពើ នឹងបញ្ហាទំនោរផ្លូវភេទ និង/ឬ អត្តសញ្ញាណយេនឌ័រ អាចជំរុញកុមារមួយចំនួន ឲ្យធ្លាក់ចូលទៅក្នុងស្ថានភាពងាយរងគ្រោះ ប្រសិនបើគ្មានអ្នកណានៅក្នុងសហគមន៍គាំទ្រពួកគាត់ទេ។

អ្នកសម្របសម្រួលគួរតែធ្វើឲ្យប្រាកដថា ការលើកឡើងជាយោបល់នានារបស់អ្នកចូលរួម ដែលមិនពិត ឬដែលមិនបង្ករឲ្យមានបរិយាកាសមានសុវត្ថិភាពសម្រាប់កុមារទេនោះ គួរតែត្រូវបានដោះស្រាយដោយប្រុងប្រយ័ត្ន។ ឧទាហរណ៍ ការផ្តល់យោបល់លើសម្លៀកបំពាក់របស់កុមារី គឺមិនពាក់ព័ន្ធទៅនឹងប្រធានបទនៅក្នុងការពិភាក្សាឡើយ ហើយអាចធ្វើឲ្យអ្នកដែលមានអាកប្បកិរិយាលម្អៀងផ្នែកយេនឌ័រ និងបន្តប្រកាន់គំនិតដែលស្តីបន្ទោសទៅលើជនរងគ្រោះ។ អ្នកសម្របសម្រួលមិនគួរជំរុញឲ្យមានការពិភាក្សាលើបញ្ហាទាំងនេះឡើយ តែផ្ទុយទៅវិញ គួរតែផ្តោតលើសារសំខាន់ៗ ដែលត្រូវបានលើកឡើងនៅក្នុងកញ្ចប់ឧបករណ៍នេះ។

ក្នុងកាលៈទេសៈខ្លះ អ្នកសម្រួលសម្រួលនឹងជួបអ្នកចូលរួមដែលសម្តែងឥរិយាបថរំខាន (ឈ្លោះប្រកែក និយាយឥតឈប់ អាកប្បកិរិយារំខាន ឬអ្នកដែលជឿថាខ្លួនដឹងអ្វីគ្រប់យ៉ាង)។ ដើម្បីធ្វើឲ្យរសាយនូវជម្លោះ ត្រូវលើកទឹកចិត្តឲ្យអ្នកចូលរួមផ្តល់យោបល់ក្នុងការរកដំណោះស្រាយបញ្ហា ដែលពួកគាត់បានលើកឡើង។ ចៀសវាងការមិនអើពើនឹងអ្នកចូលរួមផ្សេងទៀត ដោយសារតែឥរិយាបថរបស់អ្នកចូលរួមម្នាក់ឲ្យសោះ។

នៅពេលចាំបាច់ សូមរំឭកអ្នកចូលរួមថា កុមារមិនមែនជាអ្នកដែលគួរត្រូវស្តីបន្ទោស ចំពោះការដែលពួកគេក្លាយជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទនោះទេ។

# កំណត់ត្រា

# ផ្នែកទី២៖

# ការណែនាំតាមរយៈស្លាយ



# ការណែនាំតាមរយៈស្លាយ

ផ្នែកនេះ ផ្តល់ការណែនាំជាជំហានៗ ដើម្បីជួយអ្នកសម្របសម្រួលវេទិកាពិភាក្សានេះ។ អ្នកអាចទាញយកបទបង្ហាញតាមផៅវើផ័ញសំរាប់អ្នកតំណាងសហគមន៍ ពីគេហទំព័រ http://www.childsafetourism.org និងគេហទំព័រ http://wvi.org/asiapacific/childsafetourism ហើយត្រូវធ្វើការត្រួតពិនិត្យ និងកែសម្រួលបទបង្ហាញនេះ ដើម្បីបញ្ចូលខ្លឹមសារដែលពាក់ព័ន្ធនៅថ្នាក់ជាតិ និង/ឬថ្នាក់តំបន់។ បទបង្ហាញតាមផៅវើផ័ញនេះ គឺជាឧបករណ៍គាំទ្រដល់គោលបំណងវគ្គសិក្សា និងជួយអ្នកចូលរួមចងចាំសារសំខាន់ៗ នៅពេលដំណើរការវេទិកាពិភាក្សា។ ប្រសិនបើមិនអាចប្រើស្លាយទាំងនេះធ្វើជាឧបករណ៍រូបភាពបានទេ (ដូចជាបង្ហាញនៅលើឧបករណ៍បញ្ចាំងស្លាយ ឬព្រីនចេញនៅលើក្រដាសផ្ទាំងធំ) អ្នកសម្របសម្រួល អាចប្រើការណែនាំតាមរយៈស្លាយទៅជាសំណេរសម្រាប់ការពិភាក្សា។

អ្នកសម្របសម្រួលគួរតែព្យាយាមបង្កើតបរិយាកាសសិក្សាដែលមានការចូលរួម តាមរយៈការពន្យល់លម្អិតនៅលើស្លាយនីមួយៗ និងបញ្ចូលសកម្មភាពនៅចន្លោះប្រធានបទនីមួយៗ ដូចដែលបានណែនាំ។ នៅក្នុងការណែនាំតាមរយៈស្លាយ គួរតែបង្កើតជាសំណួរដែលអ្នកសម្របសម្រួលអាចប្រើ ដើម្បីជំរុញការពិភាក្សាក្នុងក្រុមទាំងមូល និង/ឬការឆ្លុះបញ្ចាំងផ្ទាល់ខ្លួនរបស់អ្នកចូលរួម និងពេលវេលា (ដូចបានដាក់សញ្ញាសម្គាល់ថា ជាសំណួរឆ្លុះបញ្ចាំង/ពិភាក្សា។ កាតយកតាមខ្លួន (ឧបសម្ព័ន្ធទី១) គួរតែចែកដល់អ្នកចូលរួមនៅមុនដំណើរការវេទិកាពិភាក្សា ហើយត្រូវយកធ្វើជាឯកសារយោងនៅក្នុងការពិភាក្សាទាំងមូល។ អ្នកសម្របសម្រួល គួរតែលើកទឹកចិត្តដល់ចូលរួមឲ្យប្រើប្រាស់កាតយកតាមខ្លួនទាំងនេះ ធ្វើជាឯកសារយោងដ៏មានប្រយោជន៍។ អ្នកចូលរួមអាចប្រើប្រាស់ កាតយកតាមខ្លួនទាំងនោះ ដើម្បីផ្សព្វផ្សាយព័ត៌មានបន្តដល់គ្រួសារ និងសហគមន៍របស់ខ្លួន ក្រោយពេលបញ្ចប់វេទិកាពិភាក្សានេះ។ ក្នុងករណីប្រើសំណួរចូលទៅកាន់មេរៀន ជាលក្ខណៈសរសេរ អ្នកសម្របសម្រួលក៏អាចជ្រើសរើសផ្តល់សំណួរចូលទៅកាន់មេរៀន (ឧបសម្ព័ន្ធទី៣) ក្នុងពេលតែមួយ ជាមួយនឹងកាតចែកជូននោះបានដែរ ហើយត្រូវហៅអ្នកចូលរួមឲ្យមកបំពេញសំណួរនៅចំណុចពាក់ព័ន្ធណាមួយ នៅក្នុងការពិភាក្សានេះ។

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **សេចក្តីផ្តើម** | | |
| **ស្លាយទី១**  | | • ស្លាយផ្តើមះអាចបញ្ចាំងបង្ហាញនៅពេលអ្នកចូលរួមកំពុងដើរចូលមកក្នុងវេទិកាពិភាក្សា<br>• សូមធ្វើឲ្យស្លាយនេះ មានលក្ខណ:ស៊ីនឹងបរិបទមូលដ្ឋាន តាមរយ:ការដាក់បន្ថែមឈ្មោះសហគមន៍ ឈ្មោះ សហ-អ្នកសម្របសម្រួលដែលមកពីអង្គការដៃគូហើយបើសមស្រប អាចដាក់បញ្ចូលស្លាកសញ្ញាអង្គការដៃគូផង។<br>• ក្នុងករណីមានប្រារព្ធពិធីបើកវគ្គ ដោយមានសន្ទរកថាបើកវគ្គជាផ្លូវការ ត្រូវមានស្លាយមួយបន្ថែមទៀតដើម្បីបង្ហាញត្រង់ចំណុចនេះ។ |
| **ស្លាយទី២**  | • អរុណសួស្តី/សាយ័ន្តសួស្តី<br>• ត្រូវថ្លែងអំណរគុណដល់គ្រប់គ្នាដែលបានចំណាយពេលមកចូលរួមក្នុងវេទិកាពិភាក្សា<br>• អ្នកសម្របសម្រួលចាប់ផ្តើមណែនាំខ្លួនឯង និងអ្នកដទៃទៀតដែលគាំទ្រដល់វេទិកាពិភាក្សា។ | • ដោយសារមានពេលវេលាតិចសម្រាប់វេទិកាជជែកពិភាក្សារបស់អ្នកតំណាងសហគមន៍ សូមធ្វើវគ្គសេចក្តីផ្តើមនេះឲ្យខ្លី។<br>• គោលបំណងនៃវគ្គសេចក្តីផ្តើម គឺដើម្បីធ្វើឲ្យអ្នកចូលរួមមានអារម្មណ៍ស្រួលចិត្តជាមួយប្រធានបទ និងផ្តល់ឱកាសឲ្យគាត់ណែនាំខ្លួនទៅ កាន់ក្រុម និងស្គាល់អ្នកចូលរួមដទៃទៀត មុនពេលចាប់ផ្តើមលើកឡើងពីបញ្ហារសើប ទាក់ទងនឹងការរំលោភបំពានផ្លូវភេទកុមារ នៅវគ្គបន្ទាប់។ |
| **ស្លាយទី៣**  | • សូមពន្យល់ថា សម្ភារអប់រំនេះ ត្រូវបានបង្កើតឡើងដោយអង្គការទស្សន:ពិភពលោក សម្រាប់គម្រោងកុមារភាព ផ្នែកបង្ការ និងជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងកិច្ចការពារមិនឲ្យមានការរំលោភបំពានផ្លូវភេទលើកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ។ | • អ្នកសម្របសម្រួលគួរតែធ្វើការបរិយាយដោយសង្ខេប ថាតើសហគមន៍មានទំនាក់ទំនងដូចម្តេច ជាមួយវិស័យទេសចរណ៍ (ឧទាហរណ៍៖ វាជាកន្លែងគោលដៅថ្មីមួយសម្រាប់ទេសចរណ៍ ជា កន្លែងគោលដៅទេសចរណ៍ ដែលកំពុងមានការរីកចម្រើន មានការធ្វើចំណាកស្រុកមកពីសហគមន៍ផ្សេង មកកាន់កន្លែងគោលដៅទេសចរណ៍ ។ល។ កត្តាបែបនេះ បង្កើតឲ្យមានមជ្ឈដ្ឋាន និងបរិបទសម្រាប់វេទិកាពិភាក្សានេះ។<br>• នៅពេលដែលអាច អ្នកសម្របសម្រួលគួរតែធ្វើឲ្យប្រាកដថា ការរំលោភបំពានផ្លូវភេទកុមារ ក៏កើតឡើង ក្នុងសហគមន៍ដែលពុំមែនជាទីគោលដៅទេសចរណ៍ដែរ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤** ●<br><br> | • ថ្ងៃនេះខ្ញុំចាត់ទុកថា លោក លោកស្រីគឺជាអ្នកតំណាងប្រកបដោយវិជ្ជាជីវៈមកពីសហគមន៍នេះ។<br>• លោក លោកស្រីមួយចំនួនស្គាល់គ្នារួចហើយ ប៉ុន្តែប្រហែលជានៅមានមនុស្សមួយចំនួនដែលលោក លោកស្រីមិនទាន់បានស្គាល់នៅឡើយ។ ហេតុនេះ ដើម្បីឲ្យយើងអាចស្គាល់គ្នាបាន ខ្ញុំសូមអញ្ជើញអ្នកទាំងអស់គ្នាណែនាំខ្លួន តាមរយៈការឆ្លើយសំណួរងាយៗចំនួនពីរ៖<br>– តើអ្នកឈ្មោះអ្វី ?<br>– តើអ្នកធ្វើការនៅឯណា ?<br>• បន្ទាប់ពីការណែនាំខ្លួនចប់៖<br>– គោរពចំពោះបទពិសោធន៍ និងវិជ្ជាជីវៈកម្រិតខ្ពស់ ដែលមាននៅក្នុងបន្ទប់។<br>– ទទួលស្គាល់វិស័យខុសៗគ្នា ដែលមានតំណាងនៅក្នុងវេទិកា និងគុណតម្លៃនៃបទពិសោធន៍របស់ពួកគេ។<br>– លើកទឹកចិត្តអ្នកចូលរួមឲ្យចែករំលែកបទពិសោធន៍ ក្នុងពេលពិភាក្សា។<br>– ជម្រាបអ្នកចូលរួមថា វេទិកាពិភាក្សាជាឱកាសដែលអាចជួយអ្នកចូលរួមក្នុងការងាររបស់ពួកគេ។<br>– ពន្យល់ប្រាប់ថា វេទិកាពិភាក្សា នឹងជួយបង្កើនចំណេះដឹង និងជំនាញរបស់គេក្នុងកិច្ចការពារកុមារ ឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។<br>– សូមពន្យល់ថា វេទិកាពិភាក្សានេះ ក៏នឹងផ្តល់ឱកាសដល់អ្នកចូលរួមធ្វើការសហការគ្នាបានកាន់តែល្អប្រសើរឡើង។ | • ដើម្បីធ្វើឲ្យវគ្គនេះ កាន់តែមានភាពរស់រវើក និងមានការចូលរួម សូមចាប់ផ្តើមការណែនាំខ្លួន ដោយការបោះបាល់កៅស៊ូទៅឲ្យអ្នកចូលរួមណាម្នាក់។ បន្ទាប់ពីគាត់បានណែនាំខ្លួនឯងរួចហើយ គាត់អាចជ្រើសរើសអ្នកចូលរួមម្នាក់ទៀត តាមរយៈការបោះបាល់ទៅអ្នកនោះ។ សូមលើកទឹកចិត្តអ្នកចូលរួមឲ្យបោះបាល់ទៅនរណាដែលពួកគាត់មិនធ្លាប់បានជួបពីមុនមក។<br>• ក្នុងពេលណែនាំខ្លួន អ្នកសម្របសម្រួលគួរអរគុណបុគ្គលម្នាក់ៗ ហើយកត់ត្រាទុកអំពីវិស័យផ្សេងៗគ្នា ដែលពួកគាត់តំណាង (ឧ. អប់រំ សុខាភិបាល ជម្រុញការអនុវត្តច្បាប់ អង្គការ សាសនា។ល។)<br>• វាជាការល្អបំផុតនោះ គឺត្រូវកត់សម្គាល់ និងត្រូវដឹងថាតើអ្នកចូលរួមស្គាល់គ្នាឬអត់ និងថា តើអ្នកចូលរួមម្នាក់ៗ យល់ពីតួនាទី និងការទទួលខុសត្រូវចំពោះខ្លួនឯង និងចំពោះគ្នាទៅវិញទៅមកឬទេ។ ការយល់ពីគ្នាទៅវិញកាន់តែច្បាស់ ជួយឲ្យពួកគាត់សហការគ្នាដើម្បីការពារកុមារ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥** ●   | **តើយើងមកទីនេះដើម្បីអ្វី?**<br>• ក្នុងនាមជាអ្នកតំណាងសហគមន៍ ដែលធ្វើការដោយផ្ទាល់ជាមួយកុមារ អ្នកមានតួនាទីសំខាន់ក្នុងកិច្ចការពារកុមារ ឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។<br>• តាមរយៈតួនាទីផ្នែកវិជ្ជាជីវៈរបស់អ្នកជារឿយៗ<br>– អ្នកគឺជាជនដំបូងដែលបានឃើញ ឬធ្វើការកំណត់សញ្ញាផ្សេងៗដែលបង្ហាញថា កុមារកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ<br>– អ្នកត្រូវសាកសួរ និងរាយការបញ្ជូនព័ត៌មានតាមការចាំបាច់ និង<br>– អ្នកអាចផ្សព្វផ្សាយព័ត៌មាន និងជួយអប់រំសមាជិកសហគមន៍ ឲ្យព្យាយាមបង្ការមិនឲ្យមានការរំលោភបំពានកើតមានឡើង។<br>• ក្នុងនាមជាអ្នកតំណាងសហគមន៍ លោក លោកស្រីម្នាក់ៗ គឺជា "អ្នកមានតួនាទី" ដែលមានកាតព្វកិច្ចចែងយ៉ាងច្បាស់នៅក្នុងច្បាប់។<br>• បើទោះបីជាលោក លោកស្រីសុទ្ធតែមានវិជ្ជាជីវៈខ្ពស់នៅក្នុងវិស័យរបស់ខ្លួនក្តី ប៉ុន្តែយើងដឹងថាលោក លោកស្រី អាចនឹងមានការលំបាកក្នុងការនិយាយពីបញ្ហាផ្លូវភេទ។ ថ្ងៃនេះ ប្រហែលជាលើកទីមួយដែលលោក លោកស្រី ជជែកអំពីបញ្ហាទាំងអស់នេះ។<br>• ប៉ុន្តែដើម្បីឲ្យកុមាររបស់យើងមានសុវត្ថិភាព វាជាការសំខាន់ណាស់ដែលយើងត្រូវទទួលបានព័ត៌មានអំពីបញ្ហានេះ ហើយយើងមិនត្រូវនៅស្ងៀមស្ងាត់ចំពោះប្រធានបទស្តីពីការរំលោភបំពានផ្លូវភេទកុមារឡើយ។<br>• គ្រាន់តែតាមរយៈការចូលរួមក្នុងវេទិកាពិភាក្សានេះ លោក លោកស្រីបានឈានជំហានយ៉ាងសកម្មមួយ ដើម្បីការពារកុមារក្នុងសហគមន៍របស់លោក លោកស្រី ពីការរំលោភបំពានផ្លូវភេទ។ | យោងលើ **កាតយកតាមខ្លួនលេខ១ (រក្សាកុមារឲ្យមានសុវត្ថិភាព រួចផុតពីការរំលោភបំពានផ្លូវភេទ)**<br>  |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | សំណូមពរមួយចំនួន៖<br>• ខ្ញុំដឹងថា អ្នកទាំងអស់គ្នាមានការមមាញឹកនឹងកិច្ចការរបស់ខ្លួន ប៉ុន្តែដោយសារថ្ងៃនេះយើងមានពេលវេលាតិច សូមបិទសម្លេងពេទីក្នុងទូរស័ព្ទដៃរបស់លោក លោកស្រី ឬសូមដើរចេញទៅក្រៅ/ឲ្យឆ្ងាយ បើមានការទូរស័ព្ទមកក្នុងករណីចាំបាច់។<br>• ការចូលរួមវិភាគទានរបស់លោក លោកស្រីទាំងអស់គ្នាលើប្រធានបទនេះ គឺមានតម្លៃណាស់។<br>• ប្រសិនបើមានចំណុចណាមួយមិនយល់ សូមលើកឡើង។ អ្នកដទៃក៏ ទំនងជាមិនយល់ដែរ។ បើចង់ឲ្យមាន ភាពងាយស្រួលជាងនេះនោះ អ្នកក៏ អាចជួបខ្ញុំក្រោយពេលបញ្ចប់វេទិកាពិភាក្សានេះ។<br>• បើសិនជាអ្នកមានការព្រួយបារម្ភដែលកុមារនាពេលបច្ចុប្បន្នអាចទទួលរងគ្រោះនៃការរំលោភបំពាន សូមប្រាប់ឲ្យពួកយើងដឹងបន្ទាប់ពីវេទិកាពិភាក្សានេះ។ ពួកយើងនឹងធ្វើសកម្មភាពដើម្បីការពារកុមារទាំងនោះ។ | |
| **ស្លាយទី៦** •<br> | **សកម្មភាព៖ សំណួរមុនចូលមេរៀន**<br>លោក លោកស្រីមួយចំនួន បានដឹងរួចហើយពីការរំលោភបំពានកុមារ ប៉ុន្តែសម្រាប់លោក លោកស្រីខ្លះ នេះគឺជាព័ត៌មានថ្មី។ ដើម្បីឲ្យកាន់ច្បាស់ពីព័ត៌មានដែលពួកយើងផ្តល់ជូនថាវាសមស្របបំផុតសម្រាប់អ្នកដែលពាក់ព័ន្ធឬទេ ពួកយើងចង់សួរសំណួរមួយចំនួន។<br>សូមប្រាប់អ្នកចូលរួមឲ្យពិនិត្យមើលនៅក្នុងទម្រង់ឯកសារសំណួរមុនចូលមេរៀនរបស់ខ្លួនហើយចំណាយពេលពី៣ទៅ៥នាទីដើម្បីបំពេញទម្រង់ទាំងនោះបន្ទាប់មកទើបប្រមូលទុក។<br>អាស្រ័យលើប្រភេទអ្នកចូលរួម អ្នកសម្របសម្រួលអាចប្រើសំណួរមុនចូលមេរៀន ជាសកម្មភាពប្រាស្រ័យទាក់ទងងាយៗ ដែលមានបង្ហាញនៅក្នុង កំណត់ត្រាគាំទ្រ (ជួរឈរខាងស្តាំ)។ | សំណួរមុនចូលមេរៀន មាននៅក្នុង **ឧបសម្ព័ន្ធទី៣**។<br>សំណួរមុនចូលមេរៀន៖ សកម្មភាពប្រាស្រ័យទាក់ទងគ្នា ដែលអាចជ្រើសរើសបាន។<br>១. ចែកឈុតប័ណ្ណឆ្លើយតបទៅនឹងសំណួរផ្តើមមេរៀន និងសំណួររំឭកមេរៀនសារឡើងវិញ (ឧបសម្ព័ន្ធទី ៥) ដល់អ្នកចូលរួមម្នាក់ៗ។ អ្នកចូលរួមត្រូវលើកប័ណ្ណដែលគូសសញ្ញាធីក (✓) ប្រសិនបើពួកគាត់ឆ្លើយ "បាទ/ចាស" និងលើកសញ្ញាខ្វែង(x) បើពួកគាត់ឆ្លើយថា "ទេ" ហើយត្រូវលើកប័ណ្ណដែលមានសញ្ញាសួរ (?) ក្នុងករណីពួកគាត់មិនដឹងចម្លើយចំពោះសំណួរនីមួយៗនៅក្នុងកម្រងសំណួរចូលទៅកាន់មេរៀន។ អ្នកសម្របសម្រួល(ឬជំនួយការ)នឹងត្រូវកត់ត្រាចំនួនសញ្ញាធីក (✓) សញ្ញាខ្វែង (x) និងសញ្ញាសួរ (?) ឲ្យបានត្រឹមត្រូវសម្រាប់សំណួរនីមួយៗ នៅក្នុងទម្រង់ជាគំរូ ដែលមានស្រាប់នៅក្នុង **ឧបសម្ព័ន្ធទី ៦**។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | | ២. មានជម្រើមួយងាយស្រួលក្នុងការផ្តល់ចម្លើយជាសញ្ញាធីក(✓) សញ្ញាខ្វែង(x) និងសញ្ញាសួរ(?) គឺត្រូវបែងចែកបន្ទប់ជាបីផ្នែក។ ផ្នែកទី១សម្រាប់អ្នកមានសញ្ញាធីក(✓) ទី២ដាក់អ្នកមានសញ្ញាខ្វែង(x) និងទី៣ដាក់សញ្ញាសួរ(?)។ សូមប្រាប់អ្នកចូលរួមឲ្យចូលទៅកាន់កន្លែងដែលមានសញ្ញាផ្អែកលើចម្លើយរបស់ខ្លួន គឺថាតើខ្លួនឆ្លើយ "បាទ/ចាស" ប្រើសញ្ញាធីក(✓) ឆ្លើយ "ទេ" ប្រើសញ្ញាខ្វែង(x) ឬឆ្លើយ "មិនដឹង" ប្រើសញ្ញាសួរ (?)។ |
| **តើការរំលោភបំពានផ្លូវភេទកុមារ គឺជាអ្វី?** | | |
| **ស្លាយទី៧** •<br><br> | មុននឹងពិភាក្សាអំពី "ការរំលោភបំពានផ្លូវភេទលើកុមារ" យើងត្រូវយល់ពី "ការរំលោភបំពានលើកុមារ" ជាមុនសិន។ | |
| **ស្លាយទី៨** •<br><br> | • ការរំលោភបំពានកុមារ គឺជាសកម្មភាពមួយ(ឬមិនមែនសកម្មភាព)ដែលពុំមែនកើតឡើងដោយចៃដន្យ ហើយធ្វើឲ្យកុមារឈឺចាប់ឬទុកឲ្យកុមារស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់។<br>• ការរំលោភបំពានកុមារ អាចនាំឲ្យមានគ្រោះថ្នាក់ជាក់ស្តែង ឬគ្រោះថ្នាក់ដែលអាចនឹងកើតឡើងចំពោះសុខភាព ការរស់រានមានជីវិត ការអភិវឌ្ឍន៍ និងសេចក្តីថ្លៃថ្នូររបស់កុមារ។ | សូមមើល **កាតយកតាមខ្លួន** (តើការរំលោភបំពានកុមារជាអ្វី)<br>អ្នកសម្របសម្រួលគួរតែមើលនិយមន័យ និងផ្អែកដែលពាក់ព័ន្ធនៅក្នុងច្បាប់ជាតិតាមការគួរ<br><br> |
| **ស្លាយទី៩** •<br> | ការរំលោភបំពានកុមារមានបួនទម្រង់សំខាន់ៗ ប៉ុន្តែជារឿយៗ មានចំណុចដូចគ្នាខ្លះ៖<br>**ការរំលោភបំពានលើរាងកាយ**<br>• ការរំលោភបំពានលើរាងកាយ កើតឡើងនៅពេលមនុស្សម្នាក់ មានចេតនាធ្វើឲ្យឈឺ ឬគំរាមកំហែងធ្វើឲ្យឈឺដល់កុមារម្នាក់។<br>• ចំណុចនេះរួមមាន ការវាយដំ ការក្តិច ការចាប់រលាក់ ការទាត់ជាក់ ការធ្វើឲ្យរលាក ការប្រាន ការធ្វើឲ្យថប់ដង្ហើម ការចាប់/ចង ការបំពុល ឬការហាមឃាត់មិនឲ្យកុមារកម្រើក។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | **ការរំលោភបំពានផ្លូវចិត្ត**<br>• ការរំលោភបំពានផ្លូវចិត្ត គឺតែងតែកើតមាន ហើយធ្វើឲ្យរបួសធ្ងន់ធ្ងរដល់សតិអារម្មណ៍ ។<br>• ការរំលោភបំពានផ្លូវចិត្ត គឺជាការវាយប្រហារទៅលើការជឿជាក់លើខ្លួនឯងរបស់កុមារ។<br>• វាកើតឡើងក្នុងទម្រង់ ជាការដាក់ងារដែលធ្វើឲ្យកុមារឈឺចាប់ ឬជាការមើលងាយដល់កុមារ ការគំរាមកំហែង ការចំអក ការបំភិតបំភ័យ ឬការទុកឲ្យកុមារឲ្យនៅដាច់តែឯងជាដើម។<br>• រាល់ទម្រង់នៃការរំលោភបំពានកុមារ គឺមានផលប៉ះពាល់ផ្នែកសតិអារម្មណ៍ទៅលើកុមារ។<br>**ការមិនអើពើ**<br>• ការមិនអើពើ គឺជាការខកខានមួយយ៉ាងធ្ងន់ធ្ងរ ក្នុងការផ្តល់ការថែទាំសំខាន់ៗដល់កុមារ។<br>• ឧទាហរណ៍៖ កិច្ចការពាកុមារឲ្យរួចផុតពីមជ្ឈដ្ឋានគ្រោះថ្នាក់ ឬការមិនព្រមផ្តល់ការយកចិត្តទុកដាក់ថែទាំសុខភាព ឬតម្រូវការចាំបាច់របស់កុមារ (ដូចជាចំណីអាហារ សម្លៀកបំពាក់ ទីជម្រក ឬការថែទាំផ្នែកសតិអារម្មណ៍)។<br>**ការរំលោភបំពានផ្លូវភេទ**<br>• ការរំលោភបំពានផ្លូវភេទ កើតឡើងនៅពេលជនណាម្នាក់ នាំកុមារធ្វើសកម្មភាពផ្លូវភេទ ដោយប្រើកម្លាំងរបស់ខ្លួនទៅលើកុមារនោះ ឬឆក់ឱកាសទាញយកប្រយោជន៍ ពីទំនុកចិត្តរបស់កុមារនោះ។<br>• ការរំលោភបំពានផ្លូវភេទកុមារ មានគ្រប់រូបភាពនៃឥរិយាបថផ្លូវភេទដែលកុមារមិនត្រូវការ។ ការបំពាននេះ រាប់ទាំងការការប៉ះ ឬសូម្បីតែមិនប៉ះក៏ដោយ។<br>• ការរំលោភបំពានផ្លូវភេទកុមារ រួមមាន ៖<br>– បង្កើតជារូបភាព/រូបថត/វីដេអូរំលោភបំពានកុមារ<br>– បង្ខំកុមារឲ្យមើល ឬចូលរួមធ្វើសកម្មភាពផ្លូវភេទ ឬ<br>– បង្ខំ/លួងលោមកុមារឲ្យរួមភេទ ឬពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ ជាមួយកុមារ ឬមនុស្សពេញវ័យដទៃទៀត។<br>ថ្ងៃនេះ យើងផ្តោតលើការរំលោភបំពានប្រភេទ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | ទី៤ គឺការរំលោភបំពានផ្លូវភេទកុមារ។ ទោះជាយ៉ាងណាក៏ដោយចាំបាច់ត្រូវដឹងថាការរំលោភបំពានទាំងបួនប្រភេទនេះ ជារឿយៗ មានការជាប់ពាក់ព័ន្ធគ្នា ហើយមិនកើតឡើងដាច់តែឯងឡើយ។ ឧទាហរណ៍៖ កុមារដែលទទួលរងការរំលោភបំពានផ្លូវចិត្ត និងផ្នែកសតិអារម្មណ៍ ជារឿយៗ មិនបានទទួលការយកចិត្តទុកដាក់ទេ។ | |
| **ស្លាយទី១០** ●   | • ពុំមានស្ថិតិជាក់លាក់ណាមួយដែលបង្ហាញតួលេខនៃចំនួនកុមារ ដែលទទួលរងការរំលោភបំពានផ្លូវភេទឡើយ។<br>• យើងពិបាកដឹងពីចំនួននេះណាស់ ព្រោះថាជារឿយៗ មនុស្សមិនរាយការករណី បែបនេះឡើយ ហើយជាញឹកញាប់គេមិនរាប់ចំនួនករណីទាំងនេះឡើយ។<br>• ប៉ុន្តែ គេប៉ាន់ស្មានថាមានដល់រាប់លានករណី<br>• កុមារទាំងនេះមានប្រភពមកពីគ្រប់ស្រទាប់វណ្ណៈសេដ្ឋកិច្ច-សង្គម គ្រប់វ័យ គ្រប់សាសនា និងគ្រប់វប្បធម៌ទាំងអស់។<br>• ការរំលោភបំពានកុមារគឺមិនមែនតែក្នុងតំបន់នេះទេ។ បញ្ហាទាំងនេះកើតឡើងគ្រប់ប្រទេសនៅលើពិភពលោក។<br>• វាគឺជារឿងធម្មតាដែលកុមារមានបទពិសោធន៍រងការរំលោភបំពានជាច្រើនរូបភាពជាងតែមួយប្រភេទនៃករណីរំលោភបំពាន។ ឧទាហរណ៍ កុមារអាចត្រូវ ឪពុកម្តាយមិនយកចិត្តទុកដាក់ និងផ្លាស់ទីរស់នៅតាមចិញ្ចើមថ្នល់ ហើយពួកគេអាចក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវកាយ និងការរំលោភបំពានផ្លូវចិត្ត និង/ឬការរំលោភបំពានផ្លូវភេទ។ | តាមទស្សនៈវិស័យមួយនៅក្នុងតំបន់ របាយការណ៍ស្រាវជ្រាវឆ្នាំ២០១២ របស់អង្គការយូនីសេហ្វ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក បានរកឃើញថា៖<br>• ការរីករាលដាលនៃការរំលោភបំពានធ្ងន់ធ្ងរលើរាងកាយ បានកើនឡើងចំពោះកុមារនៅក្នុងតំបន់នេះ ពី៩% ទៅ២៥%។<br>• គេរកឃើញថា កុមារា និងកុមារី ពី១៤% ទៅ ៣០% បានជួបប្រទះ នឹងបញ្ហារួមភេទដោយការបង្ខិតបង្ខំនៅក្នុងឆាកជីវិតរបស់ពួកគេ។<br>• ក្មេងជំទង់ និងមនុស្សពេញវ័យ ដែលធ្លាប់ឆ្លងកាត់ការរំលោភបំពានផ្លូវភេទ និង/ឬ ការរំលោភបំពានលើរាងកាយ ពេលខ្លួននៅជាកុមារ គឺទំនងជាគិតដល់ ឬប៉ុនប៉ងធ្វើអត្តឃាតដល់ទៅបួនដងច្រើនជាងអ្នកដែលមិនធ្លាប់មានប្រវត្តិរងការរំលោភបំពាន ។<br>(ប្រភព: យូនីសេហ្វ ការធ្វើទុក្ខទោសកុមារ ប្រេវ៉ាឡង់ ឧប្បត្តិហេតុ និងផលវិបាកនៅ តំបន់អាស៊ីខាងកើត និងបាស៊ីហ្វិច ឆ្នាំ២០១២) |
| **ស្លាយទី១១**   | *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា (អាចជ្រើសរើស)*<br>• សូមសួរអ្នកចូលរួមថា តើពួកគាត់ធ្លាប់បានឃើញ ឬបានលឺអ្វីខ្លះនៅកន្លែងធ្វើការរបស់ខ្លួន នៅជុំវិញកន្លែងរស់នៅ ក្នុងសហគមន៍ និងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ទាក់ទងនឹងការរំលោភបំពានផ្លូវភេទលើកុមារឬទេ។ | • ផ្នែកនេះមានគោលបំណងចាប់ផ្តើមការសន្ទនា អំពីការយល់ដឹងលើការរំលោភបំពានផ្លូវភេទកុមារ។ ផ្នែកនេះ ក៏ជួយឲ្យអ្នកសម្របសម្រួលយល់ដឹងថែមទៀតពីបញ្ហានៅក្នុងមូលដ្ឋាន ព្រមទាំងកម្រិតនៃការយល់ដឹងនៅក្នុងក្រុម។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
| --- | --- | --- |
| | • វាជាការសំខាន់ណាស់ ដែលត្រូវសុំឲ្យអ្នកចូលរួមចែករំលែករឿងរ៉ាវទាំងនេះដោយមិនចាំបាច់បញ្ជាក់ឈ្មោះ ឬបង្ហាញព័ត៌មានលម្អិតពីអត្តសញ្ញាណរបស់ជនរងគ្រោះ ឬជនល្មើសឡើយ។<br>• តាមរយៈរឿងដែលអ្នកចូលរួមចែករំលែក សូមលើកឡើងនូវព័ត៌មានបឋមមួយចំនួនពីអ្វីដែលអ្នកតំណាងសហគមន៍បានកន្លងមក ដើម្បីការពារកុមាររបស់ខ្លួនពីការរំលោភបំពានផ្លូវភេទ។<br>• ដើម្បីសង្កត់ធ្ងន់លើភាពពាក់ព័ន្ធ បរិបទ និងតថភាពក្នុងមូលដ្ឋាន អ្នកសម្របសម្រួលគួរផ្តល់ឧទាហរណ៍ទាញចេញពីប្រព័ន្ធផ្សព្វផ្សាយដែលលើកឡើងពីករណីរំលោភបំពានផ្លូវភេទលើកុមារនៅថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ។ ទិដ្ឋភាពជាក់លាក់នៃករណីសិក្សាអាចត្រូវបានបង្ហាញដែលអាចជួយលុបបំបាត់រឿងរ៉ាវដែលមិនពិតពីការរំលោភបំពានផ្លូវភេទដែលបានកើតឡើង។ឧ. អ្នករំលោភបំពានគឺជាមនុស្សម្នាក់ដែលត្រូវបានគេជឿទុកចិត្តជនរងគ្រោះជាកុមារ។<br>• វាអាចជាជំនួយផងដែរសម្រាប់អ្នកសម្របសម្រួលក្នុងការចែករំលែកទិន្នន័យថ្នាក់ជាតិ ឬទិន្នាការ ដូច្នេះ អ្នកចូលរួមអាចមើលឃើញរូបភាពទូលំទូលាយ ពីអ្វីដែលអ្នកជំនាញការថ្នាក់ជាតិ ឬមន្ត្រីរដ្ឋាភិបាលកំពុងនិយាយលើប្រធានបទនេះ។ | • ការពិភាក្សា មិនគួរធ្វើឡើងដោយបង្ខំឡើយ ប្រសិនបើអ្នកចូលរួមមិនទាន់បានត្រៀមខ្លួនរួចរាល់ ឬនៅអៀនប្រៀននៅឡើយ។<br>• អនុញ្ញាតិឲ្យអ្នកចូលរួមចែករំលែករឿងពីរ ឬបី។<br>• ស្តាប់រឿងទាំងនោះ។ ប្រសិនបើរឿងនោះចង្អុលបង្ហាញថា កុមារណាម្នាក់កំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពាន សូមប្រាប់ទៅក្រុមថានេះគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ និងបញ្ជាក់ថា អ្នកនឹងសុំនិយាយជាមួយអ្នកចូលរួមរូបនោះ នៅពេលសម្រាក (ឬពេលសរុបលទ្ធផលនៃវេទិកាពិភាក្សា) ដើម្បីទទួលបានព័ត៌មានក្បោះក្បាយ ក្នុងគោលដៅតាមដានករណីនោះបន្តទៀត។<br>• សូមកត់ត្រានូវរាល់ព័ត៌មានពីសកម្មភាព និងអាកប្បកិរិយាដែលអ្នកតំណាងសហគមន៍ត្រូវតែការពារកុមារក្នុងសហគមន៍របស់ពួកគេ ពីការរំលោភបំពានផ្លូវភេទ។ ចំណុចនេះអាចលើកឡើងនៅពេលក្រោយ នៅពេលមានការពិភាក្សាពីការឆ្លើយតប។ |
| **ស្លាយទី១២** •<br> | • ការរំលោភបំពានផ្លូវភេទកុមារ មានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើកុមារ។<br>• ការរំលោភបំពានអាចនាំឲ្យមានក្តីអន្តរាយក្នុងរយៈពេលខ្លី និងរយៈពេលវែង។<br>• ផលប៉ះពាល់ លើកុមារមានដូចជា៖<br>– ផ្លូវកាយ (របួស ការចម្លងជម្ងឺកាមរោគ ការប្រើប្រាស់សារជាតុញៀន)<br>– ផ្លូវចិត្ត (បញ្ហាសុខភាពផ្លូវចិត្ត និងអារម្មណ៍ រួមមានភាពតានតឹង ភ័យបារម្ភ ធ្វើអត្តឃាត ធ្វើឲ្យខ្លួនឯងរបួស)<br>– ការស្តីបន្ទោសទៅលើជនរងគ្រោះ ជាជាងអ្នករំលោភបំពាន។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | – បញ្ហាសង្គម (បញ្ហាទំនុកចិត្ត អារម្មណ៍មិនមូល ឬអារម្មណ៍គ្មានមិត្តភក្តិ មិនអាចចុះចំណោមគេបាន ឬមិនអាចរកបានការងារធ្វើ)។<br>– ផលវិបាកក្នុងរយៈពេលយូរ មានដូចជាការចូលទៅរកស្ថានភាពកេងប្រវ័ញ្ច ឬ "ការងារ" ដែលមិនចង់ធ្វើ។<br>– ផលប៉ះពាល់ពីជំនាន់មួយទៅជំនាន់មួយលើកុមារ ដែលកើតឡើងពីទំនាក់ទំនងប្រកបដោយការរំលោភបំពាន ឬក្រោយពេលមានទំនាក់ទំនងដោយការរំលោភបំពាន។<br>• ផលប៉ះពាល់ពីការរំលោភបំពាន ក៏ជះឥទ្ធិពលដល់មនុស្សផ្សេងទៀត ក្រៅពីជនរងគ្រោះ និងប៉ះពាល់ទៅលើគ្រួសារ និងសហគមន៍ពីមួយជំនាន់ទៅមួយជំនាន់។<br>– ភាពអាម៉ាស់ចំពោះគ្រួសារ<br>– សហគមន៍ឲ្យតម្លៃតិចតួច ឬបដិសេធន៍ក្រុមគ្រួសារនោះ<br>– ខូចកេរ្តិ៍ឈ្មោះគ្រួសារ<br>– មានគំនិតភ័យខ្លាច និងមិនទុកចិត្ត<br>– បន្ទុកចំណាយកើនឡើង ដោយសារភាពចាំបាច់ត្រូវថែទាំជនរងគ្រោះដោយសារការរំលោភបំពាន។<br>– មានអារម្មណ៍ស៊ាំនឹងការរំលោភបំពាន<br>• អាចមានផលប៉ះចំពោះសហគមន៍នានាដូចជា៖<br>– កេរ្តិ៍ឈ្មោះមិនល្អ<br>– បរិយាកាសភ័យខ្លាច<br>– បញ្ហាសង្គមមានការកើនឡើង<br>– ផលប៉ះពាល់មិនល្អទៅលើសេដ្ឋកិច្ច<br>– ទាក់ទាញអ្នករំលោភបំពានដទៃទៀតឲ្យចូលមកកាន់សហគមន៍។<br>– ធ្វើឲ្យវប្បធម៌ ប្រពៃណី មានភាពអន់ថយ<br>កុមារមិនគួរទទួលរងនូវការស្តីបន្ទោសដោយសារការរំលោភបំពាន ដែលខ្លួនបានឆ្លងកាត់ ឬដោយសារផលប៉ះពាល់ដែលកើតឡើងចំពោះគ្រួសារ និងសហគមន៍ឡើយ។ កុមារណាម្នាក់ ដែលបានជួបប្រទះការរំលោភបំពានគួរទទួលបានការធានាយ៉ាងច្បាស់ថា នោះមិនមែនជាកំហុសរបស់ពួកគេឡើយ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **តើអ្នកតំណាងសហគមន៍ ត្រូវដឹងព័ត៌មានអ្វីខ្លះ ?** | | |
| **ស្លាយទី១៣** ●  | • តើយើងត្រូវដឹងព័ត៌មានអ្វីខ្លះអំពីការរំលោភបំពានផ្លូវភេទកុមារ ? ( ទៅកាន់ស្លាយបន្ទាប់ ) | |
| **ស្លាយទី១៤** ●  | **តើនរណាជាជនរងគ្រោះ ?**<br>• ការរំលោភបំពានផ្លូវភេទកុមារ អាចកើតឡើងចំពោះកុមារដែលមានប្រវត្តិគ្រប់ប្រភេទទាំងអស់។<br>• ជនរងគ្រោះអាចជាកុមារី ឬជាកុមារា<br>• យោងតាមច្បាប់កុមារគឺជាមនុស្សទាំងឡាយដែលមានអាយុក្រោម១៨ឆ្នាំ។ ជនរងគ្រោះអាចស្ថិតក្នុងអាយុណាមួយរវាង០-១៧ ឆ្នាំ ពួកគេអាចជាទារកក្មេងតូច ឬក្មេងវ័យជំទង់។<br>• ពេលខ្លះ ជនរងគ្រោះជាកុមារមកពីស្ថានភាពលំបាក។ ពួកគេអាចមានជីវភាពក្រីក្រ រស់នៅតាមចិញ្ចើមថ្នល់/ឆ្នេរសមុទ្រ មិនបានទៅសាលារៀន ជាកុមារជនជាតិដើមភាគតិច ឬមកពីគ្រួសារដែលបែកបាក់គ្នា។ ម្យ៉ាងទៀត ជនរងគ្រោះច្រើនតែជួបការរំលោភបំពានក្នុងទម្រង់ដទៃទៀត នៅផ្ទះ ឬនៅតាមចិញ្ចើមថ្នល់។<br>• ទោះយ៉ាងណាក្តី ជនរងគ្រោះក៏អាចជាមនុស្សស្ថិតក្នុងគ្រួសារដែលមានជីវភាពមធ្យម និងជីវភាពខ្ពង់ខ្ពស់ផងដែរ។ ពួកគេប្រហែលជារងឥទ្ធិពលពីសម្ភារៈនិយម ( ជារឿយៗ ច្រើនតែពាក់ព័ន្ធនឹងការអូសទាញពីមិត្តភក្តិ )។ ពួកគេប្រហែលជាមិនបានដឹងអំពីគ្រោះថ្នាក់ទាក់ទងនឹងស្ថានភាពរបស់ពួកគេឡើយ។ | • អ្នកសម្របសម្រួល គួរតែប្រមូលព័ត៌មាន និងផ្តល់ឧទាហរណ៍បញ្ជាក់ពីព័ត៌មានផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ដោយផ្អែកលើអាយុ យេនឌ័រ ទីតាំង។ល។<br>• ឧទាហរណ៍ទាំងឡាយណាដែលបានមកពីប្រព័ន្ធផ្សព្វផ្សាយ ( ដោយមិនបង្ហាញអត្តសញ្ញាណ របស់ជនរងគ្រោះ ) អាចមានប្រយោជន៍សម្រាប់ចំណុចនេះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | • កុមារដែលមានពិការភាព (ពិការភាពគ្រប់ប្រភេទ) ក៏អាចស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពានដែរ ដូច្នេះគួរមានការថែទាំ និងយកចិត្តទុកដាក់ពិសេស ដើម្បីការពារកុមារទាំងនេះ។ កត្តានេះ ត្រូវរាប់បញ្ចូលទាំងបុគ្គលដែលមានពិការភាពគ្រប់ប្រភេទ ដូចជាពិការភាពផ្លូវកាយ ពិការភាពខាងវិញ្ញាណ (ដូចជាកំសោយខាងការស្តាប់ ឬការមើលឃើញ) ពិការភាពផ្នែកសតិបញ្ញា និងពិការភាពផ្នែកចិត្តវិកល។<br>• មិនត្រូវស្តីបន្ទោសកុមារចំពោះការរំលោភបំពានដែលកើតឡើងចំពោះពួកគេជាដាច់ខាត។ មនុស្សពេញវ័យ ជាអ្នកត្រូវទទួលខុសត្រូវការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។ ជួនកាល មានការស្តីបន្ទោសដោយផ្ទាល់ ឬដោយប្រយោល។ កុមារណាក៏ដោយដែលជាជនរងគ្រោះនៅក្នុងការរំលោភបំពាន គួរតែទទួលបានការធានាយ៉ាងច្បាស់លាស់ថា ពួកគាត់នឹងមិនត្រូវគេស្តីបន្ទោសជាដាច់ខាតចំពោះអ្វីដែលបានកើតឡើងលើពួកគេឡើយ។ | ត្រូវយកចិត្តទុកដាក់ឲ្យបានច្រើនបំផុត ចំពោះការប្រកាន់វណ្ណៈ ឬអាកប្បកិរិយារើសអើងដែលអាចនឹងរីករាលដាល ដើម្បីធានាធ្វើយ៉ាងណាឲ្យមានភាពស្មើគ្នាសម្រាប់កុមារទាំងអស់។ ការយកចិត្តទុកដាក់ និងការថែទាំច្រើនបំផុតគឺត្រូវការជាចាំបាច់ ដើម្បីធានាថា អ្នកសម្របសម្រួលមិនបន្តអាកប្បកិរិយា ឬ ទស្សនៈរើសអើងឡើយ ទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី បូករួមទាំងអាកប្បកិរិយាពាក់ព័ន្ធនឹងទំនោរផ្លូវភេទ និងអត្តសញ្ញាណយេនឌ័រ។ ការបន្តនូវគំនិតរើសអើង ដែលផ្អែកលើភេទ ទំនោរផ្លូវភេទ ពូជសាសន៍។ល។ គឺមិនអនុលោមទៅតាមសិទ្ធិកុមារអន្តរជាតិឡើយ ហើយចូលរួមចំណែកធ្វើឲ្យមានភាពងាយរងគ្រោះ ដែលដាក់កុមារឲ្យស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរំលោភបំពាន។ |
| **ស្លាយទី១៥** •<br> | • ជារឿយៗ មានការយល់ច្រឡំថា កុមារាមិនអាចជាជនរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទទេ។<br>• ហេតុនេះ ជានិច្ចជាកាល សហគមន៍ការពារកុមារីច្រើនជាងកុមារា។<br>• កត្តាបែបនេះ បានធ្វើឲ្យកុមារា ស្ថិតក្នុងភាពងាយរងគ្រោះដោយសារការរំលោភបំពានកាន់តែច្រើនឡើង។<br>• កត្តាបែបនេះ ក៏ធ្វើឲ្យកុមារាមានការលំបាកក្នុងការលាតត្រដាងប្រាប់អ្នកណាម្នាក់ អំពីការរំលោភបំពានដោយសារតែភាពអាម៉ាស់នៅក្នុងសង្គម និងការយល់ខុសដែលពាក់ព័ន្ធនានា។ | ការស្រាវជ្រាវបានបង្ហាញថា ជារឿយៗ សហគមន៍មិនជឿថាកុមារាអាចជាគោលដៅនៃការរំលោភបំពានផ្លូវភេទឡើយ។ កត្តានេះធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសុខុមាលភាពកុមារាផងដែរ ហើយក៏មានន័យថា សហគមន៍មិនអាចប្រើប្រាស់យន្តការការពារឲ្យបានម៉ត់ហ្មត់ចត់ចំពោះកុមារាទេ ធៀបជាមួយនឹងយន្តការដែលប្រើចំពោះកុមារីនោះ។ ឧទាហរណ៍៖ គេបានរកឃើញថា នៅក្នុងប្រទេសមួយចំនួន កុមារាគឺជាជនងាយរងគ្រោះចំពោះការជួញដូរមនុស្សសម្រាប់កេងប្រវ័ញ្ចផ្លូវភេទ ព្រោះឪពុកម្តាយមានបំណងឲ្យកូនប្រុសខ្លួន ធ្វើចំណាកស្រុកទាំងប្រថុយនឹងគ្រោះថ្នាក់ដែលជាការខុសស្រឡះពីកូនស្រី។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៦** ●<br> | តើអ្នករំលោភបំពាន ជានរណា?<br>អ្នករំលោភបំពានលើកុមារ អាចជានរណាក៏បាន៖<br>• បុរស ឬស្ត្រី<br>• សមាជិកគ្រួសារ (ឪពុក ម្តាយ បងប្អូន ជីដូនមួយ ជីតា ឬសាច់ញាតិជាស្ត្រី)<br>• អ្នកជិតខាង មិត្តភក្តិ ឬមនុស្សដែលគេជឿទុកចិត្ត (គ្រូបង្រៀន អ្នកធ្វើការនៅក្លឹបកីឡា បុគ្គលិកវេជ្ជសាស្ត្រ។ល។) សូមចងចាំថា កុមារភាគច្រើនត្រូវបានមនុស្សដែលពួកគេស្គាល់រំលោភបំពាន។<br>• មនុស្សប្លែកមុខ<br>• កុមារ និងយុវវ័យដទៃទៀត។ ចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើការរំលោភបំពានផ្លូវភេទ ដែលជួនកាលគឺជាទង្វើរបស់កុមារដទៃទៀត ដែលមានអាយុច្រើនជាង។<br>• មនុស្សមកពីសហគមន៍ ឬប្រទេសណាមួយ ក្នុងវ័យអាជីព ឬកាន់សាសនាអ្វីក៏ដោយ។<br>ថ្វីបើគេមិនអាចកំណត់អត្តសញ្ញាណអ្នករំលោភបំពានផ្លូវភេទកុមារ តាមរយៈការមើលតែរូបរាងខាងក្រៅរបស់ពួកគេក្តី គេអាចដឹងបានពីអាកប្បកិរិយាគួរឲ្យសង្ស័យដែលបង្ហាញចេញ។ | អ្នកសម្របសម្រួលអាចលម្អិតទៅលើព័ត៌មានដែលបានមកពីករណីសិក្សានៅមូលដ្ឋាន/ក្នុងប្រទេស/អន្តរជាតិ។ ករណីសិក្សាគួរតែត្រូវបានប្រើប្រាស់សម្រាប់បង្ហាញពីព័ត៌មានផ្ទាល់ខ្លួននានា របស់អ្នករំលោភបំពានទាំងឡាយដែលត្រូវបានចាប់ខ្លួននៅក្នុងប្រទេស។<br>ជាថ្មីម្តងទៀត ជាការចាំបាច់ដែលត្រូវយកចិត្តទុកដាក់ទៅលើផ្នត់គំនិតយេនឌ័រ ដែលកើតមាន អំពីអ្នករំលោភបំពាន។ ទោះបីជាករណីដែលគេរាយការមកនោះ បង្ហាញថាអ្នករំលោភបំពាន ជាទូទៅគឺជាបុរសនោះក៏មានការយល់ដឹងកាន់តែច្រើនថា មនុស្សស្រីក៏ប្រព្រឹត្តទង្វើរំលោភបំពានផ្លូវភេទលើកុមារផងដែរ ហើយផលប៉ះពាល់មកលើកុមារគឺមានសភាពធ្ងន់ធ្ងរដូចគ្នា។<br>ត្រូវបង្ហាញថា ការរំលោភបំពានផ្លូវភេទជាច្រើនករណីត្រូវបានគេរាយការថា កើតឡើងដោយសារមូលហេតុផ្សេងៗគ្នាជាច្រើន ដូច្នេះបញ្ហានេះមានរូបភាពមិនច្បាស់លាស់ទេ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៧ ●**<br> | **តើអ្នកបំពានផ្លូវភេទលើកុមារ ប្រព្រឹត្តអំពើទាំងនេះដូចម្តេច?**<br>• អ្នករំលោភបំពាន ចូលទៅរកកុមារ ហើយប្រព្រឹត្តអំពើរំលោភបំពានតាមវិធីផ្សេងៗ។<br>• មនុស្សជាច្រើនតែងតែគិតថា ការរំលោភបំពានផ្លូវភេទកុមារ កើតឡើងជាទង្វើពាសវាលពាសកាលរបស់មនុស្សប្លែកមុខ។<br>• ជាក់ស្តែង វាជាការធម្មតាដែលអ្នករំលោភបំពានកុមារ/មេអណ្តើកនឹងចំណាយពេលដើម្បីកសាងទំនាក់ទំនងជាមួយកុមារ (និងជួនកាលជាមួយគ្រួសារកុមារ)។ | សូមមើល **កាតយកតាមខ្លួន (តើអ្នកបំពានផ្លូវភេទលើកុមារ ប្រព្រឹត្តអំពើទាំងនេះដូចម្តេច?)**<br><br>តាមរយៈការសិក្សាពីឥរិយាបថរបស់អ្នករំលោភបំពានផ្លូវភេទកុមារ ដែលតុលាការបានប្រកាសសាលក្រមផ្តន្ទាទោសនោះ អ្នកស្រាវជ្រាវអាចបានឃើញទម្រង់ និងភាពស្រដៀងគ្នាយ៉ាងច្បាស់លាស់ ពីរបៀបដែលអ្នករំលោភបំពានប្រព្រឹត្ត។ ព័ត៌មាននេះភាគច្រើន គឺផ្អែកទៅលើទិន្នន័យដែលបានមកពីបច្ចិមប្រទេស របៀបដែលជនល្មើសរំលោភបំពានលើកុមារនៅទ្វីបអាស៊ី។ |
| **ស្លាយទី១៨●**<br> | • ដំណើរការនៃការកសាងទំនាក់ទំនងជាមួយកុមារ និង/ឬក្រុមគ្រួសារកុមារ ត្រូវបានដឹងថាជា "ការល្បួង" ហើយពាក់ព័ន្ធមួយជំហានម្តងៗ។<br>• ដំបូង អ្នករំលោភបំពានសង្កេត និងកំណត់គោលដៅកុមារ។ ជារឿយៗ ពួកគេច្រើនតែជ្រើសយកកុមារដែលងាយរងគ្រោះ។<br>• កុមារងាយរងគ្រោះ គឺជាក្មេងដែលប្រហែលជាមិនអាចនិយាយអ្វីដែលខ្លួនមិនពេញចិត្តបាន គឺជាជនដែលត្រូវគេមិនយកចិត្តទុកដាក់ ឬផ្តាច់ទំនាក់ទំនងពីមនុស្សពេញវ័យដែលអាចទុកចិត្តបាន ឬត្រូវសហគមន៍ផាត់ចោល។ ឧទាហរណ៍ ឪពុក ឬម្តាយម្នាក់ រស់នៅជាមួយកូនច្រើននាក់ កូនដែលរស់នៅឆ្ងាយពីគ្រួសារ កូនដែលមានពិការភាព កូនដែលមានបញ្ហាសតិអារម្មណ៍នៅក្នុងជីវិត កូនដែលប្រឈមមុខជាមួយអំពើហិង្សាក្នុងគ្រួសារ។ល។ | នៅក្នុងប្រទេសខ្លះ "ការល្បួង" គឺជាបទល្មើសឧក្រិដ្ឋ ពីព្រោះគេជឿថាវាជាទង្វើដែលធ្វើឲ្យកុមារមានគ្រោះថ្នាក់។ សូមដាក់បញ្ចូលច្បាប់ជាតិដែលពាក់ព័ន្ធ ប្រសិនបើមាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី១៩** •   | • បន្ទាប់មក អ្នករំលោភបំពានកសាងការទុកចិត្តរបស់កុមារតាមរយៈការចែករំលែកចំណាប់អារម្មណ៍របស់ពួកគេ ផ្តល់ការយកចិត្តទុកដាក់ខ្លាំងដល់កុមារ ផ្តល់ជាអំណោយដល់កុមារ និងធ្វើជាមិត្តរបស់កុមារ។ ពេលខ្លះអ្នករំលោភបំពានក៏ចូលមកធ្វើសិទ្ធស្នាលជាមួយគ្រួសារផងដែរ។ ឧទាហរណ៍៖ អ្នករំលោភបំពានម្នាក់ អាចធ្វើជាមិត្តម្នាក់របស់ម្តាយដែលនៅលីវ ដើម្បីទទួលបានសេចក្តីទុកចិត្តពីម្តាយរូបនោះ និងចូលទៅរំលោភបំពានកុមារ។ សកម្មភាពនេះ អាចរួមមានដូចជា ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រួសារ រស់នៅជាមួយគ្រួសារ នោះ ដោយផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់កុមារ (សម្រាប់ឲ្យកុមារទៅសាលារៀន ឬសម្រាប់តម្រូវការដទៃទៀតរបស់កុមារ)។<br>• ក្នុងករណីភាគច្រើន អ្នករំលោភបំពានមានអំណាចមួយចំនួនលើកុមារ អាស្រ័យដោយអាយុ ភាពចាស់ទុំ កម្លាំងបាយ ឬតួនាទីនៃអំណាច ឬការគ្រប់គ្រងរបស់ពួកគេ។ | |
| **ស្លាយទី២០** •   | • នៅពេលដែលអ្នករំលោភបំពានសាងទំនាក់ទំនងជាមួយកុមារ ពួកគេចាប់ផ្តើមបង្កើតការសម្ងាត់ជាមួយកុមារ ដើម្បីធានាឲ្យបានថា កុមារនឹងមិនលាតត្រដាងការពិតពីការរំលោភបំពាន។<br>• ជារឿយៗរឿងសម្ងាត់ពាក់ព័ន្ធនឹងការសន្យា ការគំរាម កំហែង ការបង្ខិតបង្ខំ ជួនកាលអ្នករំលោភបំពាន ហៅរឿងបែបនេះថាជា "ទំនាក់ទំនងពិសេសរបស់ខ្លួន ជាមួយកុមារ"។ ជាធម្មតា កុមារត្រូវរងការរំលោភបំពានផ្នែកអារម្មណ៍ ហើយត្រូវទទួលរងការគាបសង្កត់ពីអ្នកបំពាន។<br>• ឧទាហរណ៍៖ កុមារអាចនឹងមានអារម្មណ៍ថា អ្នករំលោភបំពាន គឺជាមនុស្សតែម្នាក់គត់ ដែលយល់ពីគាត់ឬនាង ហើយក្លាយទៅជាមនុស្សដែលគាត់ទុកចិត្ត។<br>• ជារឿយៗ ពេលកុមារមានបញ្ហា កុមារមានអារម្មណ៍ថា មនុស្សពេញវ័យមិនយល់ពីបញ្ហានោះឡើយ។ ហេតុនេះ កុមារអាចទទួលរងឥទ្ធិពលដោយងាយ នៅពេលពួកគប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យម្នាក់ ដែលយល់ច្បាស់ពីខ្លួន។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី២១**<br><br> | • ពេលវេលាអាចប្រែប្រួលប៉ុន្តែអ្នករំលោភបំពាន អាចធ្វើអោយរឹតតែកាន់ឡើងនូវទំនាក់ទំនង ផ្លូវភេទ។ នេះរាប់បញ្ចូលការផ្សព្វផ្សាយសម្ភារ ផ្លូវភេទ ដូច្នេះកុមារអាចមិនងាយរំភើប ឬមិន សូវមានអារម្មណ៍តក់ស្លុត ឬពិបាកចិត្តឡើយ។<br>• ឧទាហរណ៍៖ អ្នកបំពានអាចចាប់ផ្តើមប៉ះពាល់ លើកុមារ ឬបង្ហាញកុមារនោះ នូវរូបភាព មួយចំនួន ដែលជំរុញអារម្មណ៍ផ្លូវភេទ។ ក្រៅពីនេះ អ្នករំលោភបំពានអាចនឹងចាប់ ផ្តើមជជែកជាមួយកុមារអំពីសកម្មភាព ផ្លូវភេទតែម្តង។ | |
| **ស្លាយទី២២**<br><br> | • អ្នករំលោភបំពានពង្រីកកាន់តែធំនូវការប៉ះ ពាល់ផ្លូវភេទ និងឥរិយាបថរំលោភបំពាន ផ្លូវភេទផ្សេងៗ។<br>• សូមចងចាំថា ការរំលោភបំពានកុមារមិន មែនមានន័យថាតែជាការរំលោភតាមរយៈ ការស៊កបញ្ចូលប្រដាប់ភេទផ្លូវភេទនោះ ទេ។ វាអាចពាក់ព័ន្ធនឹងសកម្មភាពផ្លូវភេទ ដទៃទៀត ដោយរាប់បញ្ចូលទាំងការប៉ះពាល់ ឬសូម្បីតែមិនបានប៉ះសោះក៏ដោយ (ជាមួយនឹងអវៈយវៈភេទ)។<br>• យូរៗទៅ ការរំលោភបំពានអាចរីករាល ដាលកាន់តែធំឡើង ដោយចាប់ផ្តើមពី រឿងតូចតាចទៅ។<br>• រឿងនេះអាចនឹងកើតឡើងក្នុងពេលវេលា មួយរយៈកាល ប៉ុន្តែនៅមានឱកាសក្នុងការ ទប់ស្កាត់ការរំលោភបំពាននេះមិនឲ្យមាន ភាពកាន់តែធ្ងន់ធ្ងរទៅ ប្រសិនបើយើងអាច ធ្វើការកំណត់ពីការរំលោភបំពាននៅក្នុង ដំណាក់កាលនេះ។<br>• ខណៈពេលនេះ កុមារក៏ត្រូវបានគេ "លួង" ឲ្យមានអារម្មណ៍ផ្លូវភេទ យ៉ាងល្អួចទៅ ហើយ និងស្ថិតនៅក្រោមការគ្រប់គ្រង របស់អ្នកបំពានទៀតផង។<br>• ល្បិចលួងលោមអាចកើតមាន នៅក្រោម ការកំណត់គោលដៅផ្សេងៗ (ឧ. ផ្ទះ សាលារៀន ក្លឹបកីឡា សួនឧទ្យាន បន្ទប់ ជជែកលើប្រព័ន្ធអីនធើណេត)។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៣** ●  | **ការវាយប្រហារភ្លាមៗ**<br>• អ្នករំលោភបំពានមិនមែនប្រើតែបច្ចេកទេសលួងលោមទេ។ វិធីផ្សេងទៀត ដែលអ្នករំលោភបំពានម្នាក់អាចចូលទៅរកកុមារបាន គឺការចាប់ផ្តើមធ្វើសកម្មភាពរំលោភបំពានភ្លាមៗតែម្តង។<br>• អ្នករំលោភបំពាន អាចបំពានលើកុមារភ្លាម នៅពេលដែលឱកាសល្អហុចឲ្យ។ | |
| **ស្លាយទី២៤** ●  | **ការបញ្ចុះបញ្ចូល**<br>• អ្នកបំពានអាចចំណាយប្រាក់ជួលអ្នកណាម្នាក់ឲ្យរកកុមារណាម្នាក់ ដើម្បីធ្វើការរំលោភបំពាន។<br>• នៅពេលនោះ មេខ្យល់នឹងសំដៅទៅរកកុមារនោះ ឬគ្រួសាររបស់កុមារនោះ។<br>• ឧទាហរណ៍៖ ប្រសិនបើអ្នករំលោភបំពានមកពីក្រៅសហគមន៍ ពួកគេអាចនឹងប្រើបណ្តាញក្នុងមូលដ្ឋានឬមេខ្យល់ ដើម្បីជួយខ្លួនស្វែងរក និងរំលោភបំពានលើកុមារ។ | អ្នកសម្របសម្រួល អាចលម្អិតព័ត៌មានបានមកពីករណីសិក្សាតាមពីមូលដ្ឋាន/ប្រទេស/អន្តរជាតិ។<br>ឧទាហរណ៍មួយចំនួនរួមមាន៖<br>• ករណីមានការរាយការណ៍ពីសំណាក់អ្នកបើកបរតាក់ស៊ី ឬអ្នករត់ម៉ូតូឌុបដែលនាំអ្នករំលោភបំពាន ទៅកាន់ផ្ទះបន ឬកន្លែងផ្សេងទៀត ជាកន្លែងដែលកុមាររងនូវការកេងប្រវ័ញ្ច។ បើមិនដូច្នេះទេ អ្នកបើកបរនៅ មូលដ្ឋានបាននាំកុមារទៅឲ្យអ្នករំលោភបំពានតាមសំណើររបស់គេ ដើម្បីទទួលបានប្រាក់កម្រៃ។<br>• ជាមួយគ្នានេះ ក៏មានរបាយការណ៍ស្តីពីបណ្តាញដែល បានរៀបចំទុកមុន និងការជួញដូរមនុស្ស ជាកន្លែងដែលកុមារត្រូវគេនាំទៅនៅក្នុងប្រទេស ឬឆ្លងកាត់តាមព្រំដែន ដើម្បីកេងប្រវ័ញ្ចផ្លូវភេទ។<br>• មានករណីច្រើនស្តីពីកុមារ ដែលជាជនរងគ្រោះដោយការរំលោភបំពានផ្លូវភេទខ្លួនឯងផ្ទាល់ ហើយបាននាំក្មេងដទៃទៀតទៅឲ្យអ្នកដែលធ្លាប់បានរំលោភបំពានមកលើខ្លួន។<br>ឧទាហរណ៍ថ្មីៗក្នុងប្រទេសមួយចំនួនបើមាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៥ •**<br><br> | **តាមរយៈការឆបោក និងការបោកបញ្ឆោត**<br>• ពាក់ព័ន្ធនឹងការលួងលោម អ្នករំលោភបំពាន ឬមេខ្យល់ អាចបោកប្រាស់ ឬបោកបញ្ឆោតកុមារ ឬគ្រួសាររបស់កុមាររូបនោះ។ នេះគឺជាគ្រោះថ្នាក់ជាក់លាក់មួយ ដែលនៅក្នុងនោះ កុមារឬគ្រួសារគាត់ គឺស្ថិតនៅក្នុងស្ថានភាពមួយដ៏លំបាក។<br>**តាមរយៈការបង្ខិតបង្ខំ**<br>• កត្តានេះ ជាប់ទាក់ទងទៅនឹងវិធីនានាដែលបានរៀបរាប់រួចមកហើយ ប៉ុន្តែក៏អាចមានការជំរិតទារប្រាក់ ការគំរាមកំហែង និងទម្រង់នៃការរំលោភបំពានផ្សេងទៀត។ | |
| **ស្លាយទី២៦ •**<br><br> | **តើអ្នកណាខ្លះទៀតដែលពាក់ព័ន្ធ ?**<br>• នៅពេលយើងមើលទៅមធ្យោបាយផ្សេងៗ ដែលអ្នករំលោភបំពានប្រើប្រាស់នោះ គឺច្បាស់ណាស់ថា ជារឿយៗអ្នករំលោភបំពាន មិនមែនប្រព្រឹត្តអំពើនេះបានតែម្នាក់ឯងឡើយ។<br>• អ្នករំលោភបំពាន អាចមានជំនួយ ឬការជ្រោមជ្រែងពីមនុស្សម្នាក់ ឬមនុស្សផ្សេងទៀតដែលជួយដល់ខ្លួន ដើម្បីទៅរកកុមារ ហើយក៏ប្រព្រឹត្តអំពើរំលោភបំពាន។<br>• ក្នុងនេះ អាចមានអ្នកជំនួយការមេអណ្តើក ភ្នាក់ងារ អន្តរការី និងមេអណ្តើកជាដើម។<br>• ឧទាហរណ៍ នៅក្នុងករណីជាច្រើនដែលគេបានដឹង អ្នករំលោភបំពានជាបុរស នឹងប្រើមិត្តស្រីរបស់ខ្លួន ឲ្យជួយបញ្ចុះបញ្ចូល និងបោកបញ្ឆោតកុមារ ព្រោះកុមារមានទំនោរទុកចិត្តមនុស្សស្រីច្រើនជាង។ មានករណីជាច្រើន ដែលមនុស្សស្រីបានជួយជ្រោមជ្រែងជនល្មើសដែលជាមនុស្សប្រុស ដើម្បីបានរំលោភបំពានលើកុមារ ឧទាហរណ៍ ដូចជាមិត្តភក្តិ មិត្តស្រី ម្ចាស់ផ្ទះបនពេស្យា ឬជាស្ត្រីរកស៊ីផ្លូវភេទ។ | អាស្រ័យលើពាក់ព័ន្ធ អ្នកសម្របសម្រួល ក៏អាចទាញចំណាប់អារម្មណ៍អ្នកចូលរួមចំពោះកុមារ ដែលកំពុងត្រូវឃ្លាតឆ្ងាយពី គ្រួសារ កុមារដែលរស់នៅក្នុងអង្គការ ឬ"មណ្ឌលកុមារកំព្រា"។ ក្នុងករណីខ្លះ ឪពុកម្តាយ និងគ្រួសារ បានទទួលការបញ្ចុះបញ្ចូល និង/ឬយល់ស្របបញ្ជូនកូនរបស់ខ្លួនទៅកាន់ "មណ្ឌលកុមារកំព្រា" ឬអង្គការ ដើម្បីទទួលបានឱកាស និងការអប់រំល្អប្រសើរជាងនេះ។ ដោយយល់ថាខ្លួននឹងកំពុងផ្តល់ជីវិតមួយដ៏ប្រសើរសម្រាប់កូនៗខ្លួន ឪពុកម្តាយក៏បញ្ជូនកូនឲ្យចេញឆ្ងាយពីបរិស្ថានដែលទទួលបានការការពារពីគ្រួសាររបស់ខ្លួន ហើយចូលទៅក្នុងបរិស្ថាន ដែលពុំមានសុវត្ថិភាព ដោយនៅទីនោះ កុមារអាចនឹងងាយរងគ្រោះដោយសារការរំលោភបំពាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៧ •**<br><br> | **តើមានសញ្ញាអ្វីខ្លះ ដែលបង្ហាញថា កុមារម្នាក់ អាចស្ថិតក្នុងគ្រោះថ្នាក់?**<br>មានសញ្ញាបង្ហាញចំនួនប្រាំសំខាន់ៗដែលចង្អុលប្រាប់ថាកុមារអាចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ ឬធ្លាប់មានទទួលរងនូវការរំលោភបំពាន។ | សូមមើល **កាតយកតាមខ្លួន (តើខ្ញុំគួរចាប់អារម្មណ៍ចំពោះអ្វីខ្លះ?)**<br><br> |
| **ស្លាយទី២៨ •**<br><br> | **១. ឥរិយាបថរបស់កុមារ**<br>យកចិត្តទុកដាក់លើឥរិយាបថរបស់កុមារ។ មានសញ្ញាមួយចំនួនដែលកុមារធ្លាប់ជួបបញ្ហាការរំលោភបំពាន។ ថ្វីបើរោគសញ្ញាទាំងនេះ មិនមានន័យជាចាំបាច់ថា កុមារត្រូវបានគេរំលោភបំពាន ពួកគេបានធ្វើល្អបំផុតនូវលទ្ធផល ដើម្បីចំណាយពេលយកចិត្តទុកដាក់ច្រើនពីស្ថានភាពនោះ។<br>• អារម្មណ៍ផ្លាស់ប្តូរ មានចិត្តរារែក កើតទុក្ខ ផ្ទុះកំហឹងភ្លាមៗ ឬរករឿងឈ្លោះ។<br>• ការរត់ចេញពីផ្ទះ ឬបាត់ខ្លួនក្នុងរយៈពេលយូរ។<br>• ការប្រែប្រួលសកម្មភាពរបស់កុមារនៅសាលារៀន ឬបាត់ពីសាលាដោយមិនដឹងមូលហេតុ។<br>• មិនបានពន្យល់ប្រាប់ពីលុយ អំណោយ ទូរស័ព្ទដៃ<br>• ប្រើប្រាស់សារជាតុញៀន (រួមទាំងគ្រឿងញៀន និងគ្រឿងស្រវឹង)<br>• ឥរិយាបថរំលោភបំពានផ្លូវភេទដែលមិនសមស្របនឹងអាយុរបស់ពួកគេ។<br>• កុមារដែលគេដាក់ងារជា "ក្មេងបង្កបញ្ហា" | អ្វីដែលជាចំណុចសំខាន់បំផុត គឺ ត្រូវសង្កេតការប្រែប្រួលពីឥរិយា បថកូនរបស់ខ្លួន។ វាអាចប្រែពី "ល្អ" មកជា "អាក្រក់"។ ជារឿយៗ កុមារដែល ចាប់ផ្តើមប្រព្រឹត្តិ អាក្រក់ មិនត្រូវបានគេមើល ឃើញថា អាចជាជនរងគ្រោះឡើយ។ ផ្ទុយទៅវិញ ពួកគេ បែរជាត្រូវគេដាក់ងារថាជា "ក្មេងបង្កបញ្ហា" ទៅវិញ។ កត្តាបែបនេះ ធ្វើឲ្យពួកគាត់កាន់តែស្ថិតក្នុងសភាពងាយរងគ្រោះកាន់តែខ្លាំងឡើងពីការរំលោភបំពានដែលកំពុងកើតមាន ហើយជារឿយៗ ការត្អូញត្អែរ និងការរាយការណ៍របស់កុមាររូបនេះ មិនមានអ្នកណាម្នាក់ជឿគាត់ឡើយ។ នេះគឺជាការខកខានមិនទទួលខុសត្រូវរបស់យើងចំពោះកុមារទាំងនោះ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី២៩ •**  | **តំរិយាបថរបស់មនុស្សផ្សេងទៀត**<br>ត្រូវដឹងពីឥរិយាបថរបស់មនុស្សដែលនៅជុំវិញកុមារ រួមបញ្ចូលសមាជិកគ្រួសារ មិត្តភក្តិ មនុស្សដែលមានតួនាទីដែលគួរទុកចិត្ត។<br>អាកប្បកិរិយារបស់គាត់រួមមាន៖<br>• ការយកចិត្តទុកដាក់ហួសហេតុពេក<br>• ការជូនអំណោយ<br>• ការចូលចិត្តហួសហេតុពេក<br>• ការសុំចំណាយពេលជាមួយកុមារតែឯង<br>• ទៅកំសាន្តទីណាមួយដោយពុំមានអ្នកនាំទៅ | |
| **ស្លាយទី៣០ •**  | **៣. សញ្ញាផ្លូវកាយ និងរោគសញ្ញា**<br>• សញ្ញាផ្លូវកាយគឺរាប់បញ្ចូលទាំងការមានផ្ទៃពោះ របួសផ្លូវកាយ ឬការឆ្លងរោគ (ដូចជាជំងឺដែលទាក់ទងនឹងផ្លូវភេទ)។ | |
| **ស្លាយទី៣១ •**  | **៤. ការលាតត្រដាងការពិតដោយកុមារ**<br>• ពេលខ្លះ នៅពេលដែលកុមារមានអារម្មណ៍គ្មានសុវត្ថិភាពក្នុងការនិយាយជាមួយឪពុកម្តាយឬអ្នកថែទាំ ពួកគេនឹងលាតត្រដាងការពិតប្រាប់ពីការរំលោភបំពានទៅមនុស្សពេញវ័យផ្សេងទៀតដែលពួកគេទុកចិត្ត។<br>• អ្នកអាចជាមនុស្សម្នាក់ដែលពួកគេជ្រើសរើសនិយាយប្រាប់។ វាជាការសំខាន់ដែលត្រូវស្តាប់កុមារ មិនស្តីបន្ទោសពួកគេ ហើយអះអាងប្រាប់កុមារថា អ្នកជឿអ្វីដែលពួកគេប្រាប់អ្នក។<br>• កុមារតូចៗ អាចនឹងលាតត្រដាងការពិតតាមរយៈវិធីណាមួយដែលមិនមែនជាការនិយាយ ដូចជា គូរគំនូរ គំនូរផាត់ពណ៌។ល។<br>• យើងនឹងពិភាក្សាគ្នាអំពីរបៀបឆ្លើយតបដោយខ្លី ចំពោះការលាតត្រដាងការពិត។ | អ្វីដែលជាការសំខាន់នោះ ត្រូវចាំ ថា អ្នកបំពានផ្លូវភេទកុមារមួយចំនួន ព្យាយាមប្រើលេសយករួច ខ្លួន ឬពន្យល់ហេតុផលបញ្ជាក់ពីឥរិយាបថរបស់កុមារ ដោយប្រាប់មនុស្សដទៃថា "នោះជាការចៃដន្យ ឬកុមារមានការយល់ខុសចំពោះស្ថានភាពនោះ"។ អ្នករំលោភបំពានខ្លះសង្កត់ធ្ងន់ថា កុមារបានកុហកអំពីរឿងដែលបានកើតឡើងនោះ ឬកុមារគឺជាអ្នកបង្ករបញ្ហា ឬកុមារគឺជាអ្នកមានចំណង់ផ្លូវភេទ។ ការប៉ុនប៉ងបង្វែរសាច់រឿងទាំងនេះបានធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ ឬការទុកចិត្តទៅលើកុមារ ដែលជាជនរងគ្រោះ។ ដូច្នេះ វាជាការសំខាន់ ដែលត្រូវលើកទឹកចិត្តកូនរបស់អ្នកថា អ្នកកំពុងស្តាប់គាត់ ហើយអ្នកជឿនូវអ្វីដែលគាត់កំពុងនិយាយប្រាប់អ្នក។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៣២** •<br> | **៥. សញ្ញាព្រមានពីសហគមន៍**<br>• ខណៈពេលដែលកុមារណាម្នាក់អាចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ កត្តាមួយចំនួនធ្វើឲ្យកុមារកាន់តែងាយរងគ្រោះដោយការរំលោភបំពាន។<br>• នៅថ្នាក់សហគមន៍ អ្នកគួរតែរកមើលថាតើ៖<br>– មានកុមារសុំទាន កុមារដែលលក់ដូរ កុមារដែលមិនចូលសាលារៀនឬទេ<br>– កុមារដែលរត់ចេញពីផ្ទះ។ កុមារដែលរស់នៅតាមចិញ្ចើមថ្នល់ ឬមិនមានឪពុកម្ដាយគ្រប់គ្រង<br>– កុមារដែលរស់នៅក្នុងគ្រួសារដែលងាយរងគ្រោះ( ជនជាតិដើមភាគតិច ស្ថានភាពសេដ្ឋកិច្ចទាប ជនចំណាកស្រុក និងគ្រួសារដែលមានអំពើហិង្សា ) | |
| **តើបច្ចេកវិទ្យា និងការរំលោភបំពានកុមារ មានទំនាក់ទំនងគ្នាដូចម្ដេច ?** | | |
| **ស្លាយទី៣៣** •<br> | **បច្ចេកវិទ្យាឌីជីថល៖ តើពាក្យនេះមានន័យដូចម្ដេច ?**<br>• បច្ចុប្បន្ននេះ មានការអភិវឌ្ឍន៍បច្ចេកវិទ្យាថ្មីៗ ដែលផ្ដល់ឱកាសច្រើនដល់ពួកយើងក្នុងការទទួលបានព័ត៌មាន និងទំនាក់ទំនងជាមួយមនុស្សនៅជុំវិញពិភពលោក។<br>• ឧទាហរណ៍៖ សព្វថ្ងៃនេះ មនុស្សមិនគ្រាន់តែប្រើប្រាស់ទូរស័ព្ទដៃសម្រាប់និយាយប៉ុណ្ណោះទេ តាមរយៈទូរស័ព្ទដៃទាំងនេះ ពួកគេថែមទាំងអាចផ្ញើសារជាអក្សរ និយាយជាមួយគ្នាដោយប្រើវីដេអូ ផ្ញើរូបថត ឬវីដេអូទៅមនុស្សផ្សេងទៀត ប្រើប្រព័ន្ធជីភីអេស ( ដូចជាផែនទី ) ប្រើប្រាស់អ៊ីនធឺណេត និងការប្រើប្រាស់ផ្សេងៗទៀត។<br>• អ៊ីនធើណេត គឺជាផ្នែកមួយដ៏ចាំបាច់នៃជីវិតរស់នៅរបស់មនុស្សជាច្រើន។ និយាយឲ្យងាយ គឺអ៊ីនធឺណេតអាចឲ្យមនុស្សទទួលបាន ឬផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងតាមរយៈការផ្ដុំបណ្ដាញកុំព្យូទ័រនៅក្នុងពិភពលោក។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | • មនុស្សអាចប្រើប្រាស់អ៊ីនធើណេតតាមកុំព្យូទ័រ ទូរស័ព្ទដៃអាយផេត តាប្លេត ឬគ្រឿងអេឡិចត្រូនិចដទៃទៀតដែលអាចយកតាមខ្លួនបាន។<br>• នៅពេលមនុស្សកំពុងប្រើអ៊ីនធើណេត ពួកគេអាចធ្វើសកម្មភាពផ្សេងជាច្រើន ដូចជា ការទទួលបាន ឬផ្សព្វផ្សាយព័ត៌មាន រូបភាព ឬមើលវីដេអូ ឬផ្ញើសារតាមអ៊ីមែល ផ្ញើសារភ្លាមៗ ឬជជែកជាមួយអ្នកដទៃ បណ្តាញសង្គម (ឧទាហរណ៍៖ ការរាប់អានមិត្តភក្តិ ការទំនាក់ទំនងជាមួយមិត្តភក្តិតាមរយៈហ្វេសប៊ុក)និងលេងល្បែងតាមកុំព្យូទ័រផ្សេងៗ។<br>• ដូច្នេះ នៅពេលយើងកំពុងនិយាយគ្នា អំពី "បច្ចេកវិជ្ជាឌីជីថល"យើងកំពុងនិយាយអំពីឧបករណ៍ ម៉ាស៊ីននិងប្រព័ន្ធដែលមានរូបរាង និងការទំនាក់ទំនងដែលគ្មានរូបរាង។ | |
| **ស្លាយទី៣៤** •<br><br> | **តើបច្ចេកវិជ្ជាឌីជីថលនាំឲ្យមានគ្រោះថ្នាក់អ្វីខ្លះ?**<br>• នៅក្នុងមជ្ឈដ្ឋានជាក់ស្តែង គឺជាកន្លែងដែលកុមារប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យ រីឯពិភពឌីជីថល គឺជាមជ្ឈដ្ឋានមួយបែបទៀត ជាទីដែលកុមារ អាចនឹងប្រាស្រ័យទាក់ទងជាមួយមនុស្សដែលខ្លួនមិនធ្លាប់ស្គាល់ រាប់បញ្ចូលទាំងកុមារ និងមនុស្សពេញវ័យផងដែរ។<br>• បច្ចេកវិជ្ជាឌីជីថល កំពុងតែមានសារៈសំខាន់ខ្លាំងឡើងៗ ចំពោះមនុស្សជំនាន់ថ្មី។ កុមារចាំបាច់ត្រូវយល់ដឹងពីបច្ចេកវិទ្យានេះ ដើម្បីត្រៀមប្រែក្លាយកុមារទាំងនោះឲ្យទៅជាមនុស្សពេញវ័យ ដោយនៅក្នុងវ័យនេះ កុមារអាចត្រូវការប្រើប្រាស់បច្ចេកវិជ្ជានេះសម្រាប់ការងារ និងជីវិតរស់នៅរបស់ខ្លួន។ ហេតុនេះ ចាំបាច់ត្រូវយល់ពីគុណសម្បត្តិ និងគ្រោះថ្នាក់ ដែលអាចកើតឡើងដោយសារបច្ចេកវិជ្ជានេះ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
| --- | --- | --- |
| | • បច្ចេកវិជ្ជាឌីជីថល ផ្តល់ឱកាសល្អៗជាច្រើនដល់យើង និងកូនរបស់យើង ប៉ុន្តែមិនខុសអ្វីពីបរិស្ថានថ្មីមួយឡើយ គឺយើងត្រូវតែធ្វើយ៉ាងណាឲ្យកូនរបស់យើងដឹងពីរបៀបរៀបចំឥរិយាបថ មានការយល់ដឹងពីគ្រោះថ្នាក់ និងដឹងពីវិធីការពារខ្លួនឲ្យរួចផុតពីគ្រោះថ្នាក់ទាំងនោះ រាប់ទាំងការរំលោភបំពានផ្លូវភេទកុមារផង។<br><br>*សំណួរឆ្លុះបញ្ចាំង/ការពិភាក្សា (អាចជ្រើសរើសបាន)*<br><br>• ត្រូវឲ្យអ្នកចូលរួមគិតពីគ្រោះថ្នាក់ចំពោះសុវត្ថិ-ភាពរបស់កុមារ ដែលអាចនឹងកើតឡើងតាមរយៈបច្ចេកវិជ្ជាឌីជីថល។ | ការឆ្លើយតបដែលអាចនឹងទទួលបានសម្រាប់ឆ្លើយទៅនឹងសំណួរស្តីពីគ្រោះថ្នាក់នានា ដែលស្តែងឡើងតាមរយៈបច្ចេកវិជ្ជាឌីជីថល រួមមាន៖<br>• នៅពេលដែលយើងចែករំលែកព័ត៌មាន/រូបភាពនៅលើអ៊ីនធើណេត ពួកយើងមិនអាចលុបវាបានទេ។<br>• កុមារអាចចែករំលែកព័ត៌មានឯកជនជាមួយមនុស្សដែលមិនស្គាល់គ្នាតាមរយៈបច្ចេកវិជ្ជា។<br>• កុមារអាចក្លាយជាមិត្តភក្តិជាមួយមនុស្សដែលពួកគេមិនស្គាល់តាមរយៈបច្ចេកវិជ្ជា ហើយរៀបចំជួបផ្ទាល់ជាមួយ មនុស្សទាំងនោះ។<br>• អ្នករំលោភបំពានអាចប្រើបច្ចេកវិជ្ជាដើម្បីល្បួងកុមារ<br>• មនុស្សពេញវ័យខ្លះធ្វើពុតជាកុមារផ្សេងទៀត ក្នុងគោលបំណងកសាងទំនាក់ទំនង និង បោកបញ្ឆោតជនរងគ្រោះ បន្ទាប់មកស្នើសុំរួមភេទ។<br>• រូបភាពនៃការរំលោភបំពានផ្លូវភេទត្រូវបានចែករំលែកតាមបច្ចេកវិជ្ជា។<br>• អ្នករំលោភបំពានប្រើបច្ចេកវិជ្ជាដើម្បីកំណត់ទីតាំងនិងព័ត៌មានលម្អិតផ្ទាល់ខ្លួនរបស់កុមារ។<br>• អ្នករំលោភបំពានប្រើបច្ចេកវិជ្ជា ដើម្បីរក្សាទំនាក់ទំនង និងជួបជាមួយជនរងគ្រោះ។<br>• អ្នករំលោភបំពានប្រើល្បែងតាមប្រព័ន្ធអ៊ីនធើណេតដើម្បីកំណត់គោលដៅ និងបង្កើតឲ្យមានទំនាក់ទំនងផ្លូវភេទតាមក្រោយ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៣៥** ●<br><br> | **តើមនុស្សពេញវ័យ ឆ្លើយតបដូចម្តេចទៅនឹងគ្រោះថ្នាក់នានា ដែលស្តែងឡើងតាមរយៈបច្ចេកវិទ្យាថ្មីៗ?**<br>• មនុស្សពេញវ័យជាច្រើន បាននិយាយថា ពិភពឌីជីថល កំពុងវិវត្តយ៉ាងឆាប់រហ័ស ហើយពួកគេមិនអាចតាមទាន់ឡើយ។<br>• មានវិធានការងាយៗ ដែលមនុស្សពេញវ័យ អាចប្រើប្រាស់បាន ដើម្បីពង្រឹងសុវត្ថិភាព កុមារ នៅពេលគេប្រើប្រាស់បច្ចេកវិទ្យាដូចជា កុំព្យូទ័រ តាប្លេត និង/ឬ ទូរស័ព្ទដៃ។<br>• ជួយឲ្យកុមារបានយល់ថា ដូចគ្នានឹងពេលយើងនិយាយជាមួយមនុស្សទល់មុខគ្នា មានរឿងខ្លះងាយស្រួល ដែលយើងអាចធ្វើបាន ពេលទំនាក់ទំនងតាមបច្ចេកវិទ្យាឌីជីថល។<br>• ឧទាហរណ៍៖<br>– ណែនាំកុមារមិនឲ្យចែករំលែកព័ត៌មានលម្អិតផ្ទាល់ខ្លួនឡើយ (ដូចជាលេខទូរស័ព្ទ អាសយដ្ឋាន ឈ្មោះសាលា ។ល។) ឬរូបថតរបស់ខ្លួន តាមរយៈបច្ចេកវិទ្យាឌីជីថល។<br>– ព័ត៌មានទាំងអស់តាមអីនធឺណេត ត្រូវរក្សាទុកនៅកន្លែងសម្ងាត់បំផុត ហើយមិនត្រូវឲ្យមានព័ត៌មានណាមួយដែលចែករំលែកជាសាធារណៈឡើយ។<br>– បង្រៀនកុមារឲ្យចេះរាយការតាមអ៊ីនធើណែត។ មានគេហទំព័រ និងកម្មវិធីជាច្រើនតាមអ៊ីនធើណេត (ដូចជាហ្វេសប៊ុក ធ្វីតធើ យូធូប អ៊ីនស្តាក្រាម ស្កាយ) ដែលផ្តល់វិធីងាយស្រួល ដើម្បីរាយការពីអ្នករំលោភបំពាន ឬព័ត៌មានអំពីការរំលោភបំពាន។<br>– លើកទឹកចិត្តកុមារឲ្យប្រាប់ដល់អ្នក បើកុមារមានអារម្មណ៍មិនស្រួលនៅក្នុងការទំនាក់ទំនងរបស់ខ្លួនតាមរយៈបច្ចេកវិទ្យា។<br>– រំឭកកុមារថា ពួកគាត់គួរតែបានគ្រប់គ្រងទៅលើព័ត៌មានរបស់ខ្លួន និងអ្វីដែលខ្លួនបានឃើញនៅតាមអ៊ីនធើណេត។ | ក្នុងករណីកុមារម្នាក់ត្រូវបានទាក់ទងតាមបច្ចេកវិទ្យាឌីជីថល ដោយជនណាម្នាក់ ដែលធ្វើឲ្យកុមាររូបនោះព្រួយបារម្ភ ឬមិនសប្បាយចិត្ត អាចរាយការដោយផ្ទាល់ទៅកាន់គេហទំព័រ ឬកម្មវិធីអ៊ីនធើណេតដែលបានប្រើប្រាស់សម្រាប់ទំនាក់ទំនង។<br>ឧទាហរណ៍ ៖<br>• គេហទំព័រ http://www.facebook.com/help/reportlinks<br>• គេហទំព័រ https://support.twitter.com/forms/abusiveuser<br>• គេហទំព័រ http://www.youtube.com/yt/policyandsafety/reporting.html<br>• គេហទំព័រ http://help.instagram.com/165828726894770<br>• គេហទំព័រ https://support.skype.com/en/faq/FA10001/how-do-i-report-abuse-by-someone-in-skype? |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | • មនុស្សពេញវ័យ ក៏អាចធ្វើអ្វីមួយបានដែរ ដូចជា៖<br>– ការត្រួតពិនិត្យ និងការយល់ដឹងអំពីអ្វីដែលកុមារធ្វើ នៅតាមបច្ចេកវិជ្ជាឌីជីថល។<br>– ការសួរនាំកុមារដើម្បីបានដឹងអំពីគេហទំព័រ និងបន្ទប់ជជែកនៅលើប្រព័ន្ធអ៊ីនធើណេតដែលកុមារប្រើ។<br>– រៀបចំពេលវេលាឲ្យបានសមគួរ ដើម្បីឲ្យកុមារបានប្រើប្រាស់បច្ចេកវិជ្ជាឌីជីថល។ | |
| **តើវិស័យទេសចរណ៍មានទំនាក់ទំនងដូចម្តេចខ្លះ ជាមួយការរំលោភបំពានកុមារ ?** | | |
| **ស្លាយទី៣៦ •**<br> | • វិស័យទេសចរណ៍កំពុងតែរីកចំរើនជុំវិញពិភពលោក និងនៅក្នុងតំបន់។<br>• កំណើនវិស័យទេសចរណ៍ អាចផ្តល់ប្រយោជន៍ច្រើនដល់ប្រទេស និងសហគមន៍។<br>• អ្នកដំណើរភាគច្រើន គឺជាអ្នកដំណើរប្រកបដោយការទទួលខុសត្រូវ និងជាអ្នកគោរពវប្បធម៌ បរិស្ថាន និងប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ពេលពួកគេធ្វើដំណើរ ឬទៅរស់នៅក្នុងប្រទេសមួយអស់មួយរយៈពេល។<br>• ទោះជាយ៉ាងណាក៏ដោយ មានគ្រោះថ្នាក់មួយចំនួនកើតឡើងចំពោះកុមារ ដែលបណ្តាលមកពីកំណើននៃការមកដល់របស់អ្នកទស្សនា និងការអភិវឌ្ឍន៍វិស័យទេសចរណ៍។ | |
| **ស្លាយទី៣៧**<br> | **?** *សំណួរឆ្លុះបញ្ចាំង/ពិភាក្សា*<br>• សូមឲ្យអ្នកចូលរួមគិតពិចារណាពីគ្រោះថ្នាក់ណាមួយ ដែលអាចកើតឡើងបានចំពោះសុវត្ថិភាពរបស់កុមារ ដែលកើតឡើងតាមរយៈកំណើនវិស័យទេសចរណ៍នៅក្នុងសហគមន៍របស់ខ្លួន។ | ចម្លើយ ដែលអាចទទួលបាន រួមមាន៖<br>• ការដាក់មនុស្ស និងវប្បធម៌ ខុសគ្នាឲ្យនៅជិតគ្នាអាចនាំឲ្យមានជម្លោះ ការរំលោភបំពានអំណាច និង/ឬប្រាក់។<br>• កុមារប្រឈមមុខនឹងផលប៉ះពាល់ពីការផ្សាយពាណិជ្ជកម្មមិនល្អ។<br>• កុមារអាចត្រូវបានប្រើប្រាស់សម្រាប់រកប្រាក់ពីភ្ញៀវទេសចរ តាមរយៈការសុំទាន ឬលក់របស់របរនៅតាមចិញ្ចើមថ្នល់។ ពេលរស់នៅ ឬធ្វើការនៅតាមចិញ្ចើមថ្នល់ កុមារអាចងាយរងគ្រោះដោយសារការរំលោភបំពាន។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | | • អ្នកទេសចរ អាចចង់ទៅលេងនៅទីកន្លែងទាំងឡាយណាកម្រិតឲ្យតែមនុស្សដែលគេទុកចិត្តចូលទៅ ដូចជាមណ្ឌលកុមារកំព្រា សាលារៀន ផ្ទះ។ល។ ការដែលឲ្យមនុស្សពេញវ័យដែលមិនស្គាល់ចូលទៅទំនាក់ទំនងជាមួយកុមារ អាចដាក់កុមារឲ្យស្ថិតក្នុងភាពងាយរងគ្រោះដោយសារការរំលោភបំពាន។<br>• កន្លែងកំសាន្ត នៅពេលយប់ ឬកន្លែងរកស៊ីផ្លូវភេទអាចកើនឡើង ដើម្បីបំពេញតាមសេចក្តីត្រូវការរបស់អ្នកទេសចរ។ កុមារអាចនឹងត្រូវគេលួងលោម ឬមិនដូច្នេះទេ ត្រូវគេកេងប្រវ័ញ្ច នៅក្នុងទីកន្លែងទាំងអស់នេះ។<br>• ឪពុកម្តាយ និងអ្នកថែទាំ អាចយល់ព្រមទទួលយកអ្វីដែលអ្នកទេសចរបរទេសផ្តល់ឲ្យក្នុងការផ្តល់កន្លែងស្នាក់នៅ ឬអប់រំដល់កូនរបស់ខ្លួន ឬឲ្យកូនខ្លួនចាកឆ្ងាយពីបរិស្ថានផ្ទះដែលស្ថិតនៅក្រោមការការពាររបស់ខ្លួនទៅកាន់កន្លែងដែលកុមារអាចនឹងងាយរងគ្រោះដោយសារការរំលោភបំពាន។ |
| **ស្លាយទី៣៨**   | • អ្នកធ្វើដំណើរភាគតិចបំផុតដែលប្រើប្រាស់ការធ្វើដំណើរជាឱកាសក្នុងរំលោភបំពានផ្លូវភេទលើកុមារ។<br>• អ្នករំលោភបំពានផ្លូវភេទលើកុមារដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ គឺជាអ្នកទេសចរ អ្នកធ្វើដំណើរ ឬជនបរទេស ដែលរំលោភបំពានផ្លូវភេទកុមារនៅក្នុងប្រទេសមួយ ឬប្រទេសច្រើន ដែលពួកគេបានទៅលេង ឬស្នាក់នៅ។<br>• ខណៈពេលដែលវិស័យទេសចរណ៍បាននាំមកនូវផលប្រយោជន៍ជាវិជ្ជមានដល់ប្រទេស និង សហគមន៍របស់យើង វាគឺជាការសំខាន់ដែលពួកយើងដឹងពីគ្រោះថ្នាក់ ហើយពួកយើងការពារកុមាររបស់យើងពីការរំលោភបំពានផ្លូវភេទដោយអ្នកទេសចរ និងប្រជាពលរដ្ឋក្នុងតំបន់។<br>• ព័ត៌មានដែលយើងបានចែករំលែករួច អំពីអ្នកបំពានផ្លូវភេទកុមារ គឺទាក់ទងនឹងអ្នកដំណើរដែលរំលោភបំពានផ្លូវភេទលើកុមារ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
| --- | --- | --- |
| **ស្លាយទី៣៩** ●   | • ដូចបានពិភាក្សាហើយថា អ្នករំលោភបំពានផ្លូវភេទកុមារ ប្រើប្រាស់មធ្យោបាយមួយចំនួន។ លក្ខណៈបែបនេះ គឺដូចគ្នាទៅនឹងអ្នករំលោភបំពានផ្លូវភេទលើកុមារដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយដែរ។<br>• នៅក្នុងបរិបទជាក់លាក់នៃវិស័យទេសចរណ៍ និងការធ្វើដំណើរ៖<br>– អ្នករំលោភបំពានបានរៀបចំទុកជាមុន ដើម្បីប៉ុនប៉ងរំលោភបំពានកុមារក្នុងតំបន់ណាមួយជាក់លាក់។<br>– អ្នករំលោភបំពានមួយចំនួន បានយកពេលវេលាសំរាកដើម្បីរំលោភបំពានកុមារ។<br>– អ្នករំលោភបំពានមួយចំនួនដែលធ្វើដំណើរទៅក្រៅប្រទេស ដើម្បីទៅកាន់ទីកន្លែងដែលត្រូវបានរាយការថាមានកុមារដែលពួកគេអាចរកបានដើម្បីរួមភេទ។<br>– អ្នករំលោភបំពានខ្លះ អាចនឹងទៅលេងប្រទេសនោះជាប្រចាំ ហើយស្នាក់នៅច្រើនខែ ឬច្រើនឆ្នាំនៅទីនោះ។ ក្នុងករណីបែបនេះ ពួកគេមិនដូចជាអ្នកទេសចរឡើយ តែគឺរស់នៅក្នុងលក្ខណៈអ្នកស្រុកដែលមកពីប្រទេសក្រៅដោយមានផ្ទះ ឬផ្ទះល្វែងផ្ទាល់ខ្លួន។<br>– អ្នករំលោភបំពានខ្លះប្រើប្រាស់បច្ចេកវិជ្ជាឌីជីថលដើម្បីបំពានលើកុមារនៅប្រទេសក្រៅ (ឧ.តាមរយៈការប្រើប្រាស់វេបខែមជាដើម)។<br>– អ្នករំលោភបំពានខ្លះ បម្រើការងារជាគ្រូបង្រៀនស្ម័គ្រចិត្ត ឬជាគ្រូពេទ្យនៅក្រៅប្រទេស ហើយរំលោភបំពានកុមារដែលខ្លួនជួបតាមរយៈការងារនៅក្នុងអង្គការសប្បុរសធម៌ មណ្ឌលកុមារកំព្រា សាលារៀន មន្ទីរព្យាបាល។ល។<br>– អ្នករំលោភបំពានខ្លះ ប្រើប្រាស់មេអណ្តើក និងបណ្តាញនានា ដើម្បីជួយខ្លួនស្វែងរក និងរំលោភបំពានកុមារ។ ដូចដែលបានកត់សម្គាល់ហើយថា មានមនុស្សច្រើនប្រភេទ ដែលអាចនឹងជួយដល់អ្នកបំពានឲ្យបានទៅជួប និងរំលោភបំពានលើកុមារ។ | អ្នកសម្របសម្រួល អាចនឹងលម្អិតព័ត៌មានដែលបានមកពីករណីសិក្សាតាមមូលដ្ឋាន/ក្នុងប្រទេស/អន្តរជាតិ។ ចាំបាច់ ត្រូវនិយាយរំឭកឡើងវិញថា នៅក្នុងសហគមន៍ណាមួយក៏ដោយ ភាគច្រើន អ្នករំលោភបំពាន គឺជាមនុស្សនៅក្នុងមូលដ្ឋាននោះតែម្តង ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **នៅក្រោមច្បាប់ និងគោលនយោបាយ តើអ្នកតំណាងសហគមន៍ មានការទទួលខុសត្រូវអ្វីខ្លះ ?** | | |
| **ស្លាយទី៤០ •**   | ក្នុងនាមជាតំណាងសហគមន៍ម្នាក់ៗ អ្នកអាចជាអ្នកបំពេញសិទ្ធិ ដែលមានការទទួលខុសត្រូវយ៉ាងជាក់លាក់ ដែលបានកំណត់ដោយគោលការណ៍ណែនាំ និងច្បាប់ជាតិ។ | |
| **ស្លាយទី៤១ •**   | ផ្តល់ការបង្ហាញខ្លីមួយនៃច្បាប់ដែលពាក់ព័ន្ធបំផុត និងការទទួលខុសត្រូវដែលពាក់ព័ន្ធទៅនឹងអ្នកតំណាងសហគមន៍នៅក្រោមច្បាប់ និងគោលការណ៍/យុទ្ធសាស្រ្ត។<br><br>**?** *សំណួរឆ្លុះបញ្ចាំង/ការពិភាក្សា (អាចជ្រើសរើស)*<br><br>• តើយុទ្ធសាស្រ្តជាតិ/ផែនការសកម្មភាពថ្នាក់ជាតិ មានជាប់ពាក់ព័ន្ធអ្វីខ្លះទៅនឹងការងាររបស់យើងនៅថ្នាក់សហគមន៍ ?<br>• តើវាអាចជះឥទ្ធិពលដល់កិច្ចខំប្រឹងប្រែងរបស់យើងក្នុងការពារកុមារពីការរំលោភបំពានផ្លូវភេទដោយវិធីណា ? | នៅក្នុងប្រទេស យុទ្ធសាស្រ្តថ្នាក់ជាតិ/ផែនការសកម្មភាពថ្នាក់ជាតិខាងក្រោមនេះគឺពាក់ព័ន្ធ៖<br>• ជ្រើសរើសសកម្មភាពជាក់លាក់ដែលពាក់ព័ន្ធនឹងការរំលោភបំពានកុមារ និងការទទួលខុសត្រូវចំពោះបទបញ្ញត្តិថ្នាក់ជាតិរបស់អ្នកតំណាងសហគមន៍។<br>• ប្រសិនបើសមស្រប ផ្នែកនេះអាចត្រូវបានចែកចាយដោយមន្ត្រីតំណាងរដ្ឋាភិបាលដែលសក្តិសម។ អាស្រ័យលើបរិបទនៅក្នុងសហគមន៍ ក៏អាចយោងទៅលើគោលនយោបាយ ឬក្រមឧទ្ទេសពាក់ព័ន្ធនានារបស់វិស័យទេសចរណ៍ ដែលប្រកបដោយការទទួលខុសត្រូវ។ |
| **តើយើងអាចធ្វើសកម្មភាពអ្វីខ្លះ ដើម្បីការពារកុមារឲ្យបានល្អប្រសើរឡើង ?** | | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤២**<br><br> | *សកម្មភាព៖ តើសហគមន៍របស់ខ្ញុំមានសុវត្ថិភាពកម្រិតណាចំពោះកុមារ ? ( អាចជ្រើសរើសបាន សម្រាប់កម្មវិធីមួយថ្ងៃពេញ )*<br>• ស្នើអ្នកចូលរួមដើម្បីបំពេញទម្រង់ស្ទង់មតិចំពោះកាតយកតាមខ្លួនរួចបូកសរុបពិន្ទុ។<br>• ស្នើអ្នកចូលរួមឲ្យលើកដៃ ប្រសិនបើពួកគេទទួលបានពិន្ទុ "៧"។ ផ្តល់អនុសាសន៍ដល់អ្នកតំណាងទាំងនេះ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ដើម្បីការពារកុមារ។ សូមសួរសំណួរទៅពួកគេអនុវត្តវិធានការការពារកុមារ និងភាពជោគជ័យនានាដែលសម្រេចបាន។<br>• ស្នើអ្នកចូលរួមដែលមានពិន្ទុ ៦ ឬតិចជាងនេះដាក់លើកដៃ។ ពន្យល់ថា ពួកគេមានតួនាទីសំខាន់ ដែលអាចធ្វើសកម្មភាពជាវិជ្ជមានដើម្បីការពារកុមារពីការរំលោភបំពាន។<br>• ពន្យល់ថា អ្នកចូលរួមមួយចំនួនមិនស្គាល់ចម្លើយទាំងអស់ទេ ហើយ វាមានន័យថា ពួកយើងចាំបាច់អភិវឌ្ឍគំនិតឲ្យកាន់តែច្បាស់ឡើងនូវអ្វីដែលសហគមន៍កំពុងតែធ្វើដើម្បីការពារកុមារ។ | សូមមើល **កាតយកតាមខ្លួន ( តើសហគមន៍របស់ខ្ញុំមានសុវត្ថិភាពកម្រិតណាសម្រាប់កុមារ ? )**<br><br><br>• មុនវគ្គបណ្តុះបណ្តាល អ្នកសម្របសម្រួលគួរតែប្រមូលចម្លើយសម្រាប់សំណួរនីមួយៗក្នុងតេស្ត។ ប្រើវិធីនេះ ដើម្បីណែនាំតំណាងសហគមន៍ នៅពេលពួកគេកំពុងពិចារណាសកម្មភាពដែលសមស្របដើម្បីកសាងបរិយាកាសដែលផ្តល់កិច្ចការពារដល់កុមារ។<br>• សង្កេតមើលពីកម្រិតនៃការដឹងសំណួរ។ ការសង្កេតនេះ អាចរាយការណ៍នៅក្នុងរបាយការណ៍បណ្តុះបណ្តាលក្រោយវគ្គ ( **ឧបសម្ព័ន្ធទី៩** ) |
| **ស្លាយទី៤៣** •<br><br> | • ក្នុងនាមជាអ្នកតំណាងសហគមន៍ ពួកយើងចាំបាច់ប្រុងប្រយ័ត្នចំពោះកិច្ចខំប្រឹងប្រែងរបស់យើង ដើម្បីដោះស្រាយបញ្ហាការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍។<br>• សកម្មភាពដែលអ្នកតំណាងសហគមន៍អាចធ្វើបានដើម្បីការពារកុមារអាចត្រូវបានក្រុមដាក់បញ្ចូលក្នុងបរិវេណដែលសំខាន់ចំនួនបី៖<br>១. បើកកិច្ចសន្ទនា និងការទំនាក់ទំនង<br>២. ការបង្ការ<br>៣. ការការពារ<br>• សម្រាប់ផ្នែកនីមួយៗ ពួកយើងត្រូវការធ្វើការរួមគ្នា។<br>• សូមឲ្យអ្នកចូលរួមទាំងអស់ ពិនិត្យមើលផ្នែកនីមួយៗឲ្យបានលម្អិត។ | សូមមើល **កាតយកតាមខ្លួន ( តើត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឲ្យសហគមន៍របស់យើងមានសុវត្ថិភាពសម្រាប់កុមារ ? )**<br><br> |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៤៤** •<br> | *១. ការសន្ទនា និងការទំនាក់ទំនងលក្ខណៈបើកចំហ*<br>• ការរក្សាភាពស្ងៀមស្ងាត់ អំពីការរំលោភបំពានគឺជាឧបសគ្គចំបងដើម្បីរក្សាសុវត្ថិភាពកុមារ។<br>• ដូចយើងដឹងហើយថា ជារឿយៗកុមារ និងមនុស្សពេញវ័យ មិនចែករំលែកព័ត៌មាន ឬមិនរាយការណ៍ថា ខ្លួនរងការរំលោភបំពានឡើយ។ ក្នុងករណីបែបនេះ ជនល្មើសនៅតែបន្តរំលោភបំពានតទៅទៀត ហើយជនរងគ្រោះ និងសហគមន៍នៅតែទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។<br>• ការពិភាក្សា និងការទំនាក់ទំនងលក្ខណៈបើកចំហត្រូវធ្វើឡើងនៅពីរកម្រិតយ៉ាងតិច។ | អ្នកសម្របសម្រួលគួរតែធ្វើការស៊ើបអង្កេត និងចែករំលែកឧទាហរណ៍ថ្នាក់ជាតិ និងក្នុងតំបន់ ក្នុងកិច្ចសន្ទនា និងការទំនាក់ទំនងដែលមានលក្ខណៈបើកចំហ ដែលសមស្រប/ពាក់ពន្ធ័ទៅនឹងសហគមន៍ដែលវេទិកាពិភាក្សាត្រូវបានធ្វើឡើង។ |
| **ស្លាយទី៤៥** •<br> | • ទីមួយ ត្រូវលើកទឹកចិត្តឲ្យមានការទំនាក់ទំនងដោយផ្ទាល់ និងដោយការផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក រវាងកូន និងឪពុកម្តាយ ឬអ្នកថែទាំ។<br>• កូនៗក៏គួរតែអាចពិភាក្សាជាមួយមនុស្សពេញវ័យដែលខ្លួនទុកចិត្ត ក្នុងករណីពួកគេមានអារម្មណ៍ថាគ្មានសុវត្ថិភាព។<br>• ប្រសិនបើអ្នកធ្លាប់ស្ថិតនៅក្នុងស្ថានភាពបែបនេះ ចាំបាច់ត្រូវស្តាប់ដោយយកចិត្តទុកដាក់ ហើយមិនត្រូវស្តីបន្ទោសកុមារឡើយ ប្រសិនបើកុមាររូបនោះបានរាយការណ៍ពីការរំលោភបំពាន។ | |
| **ស្លាយទី៤៦** •<br> | • កម្រិតសំខាន់ទីពីរនៃការពិភាក្សា គឺនៅកម្រិតសហគមន៍។<br>• ក្នុងនាមជាអ្នកតំណាងសហគមន៍ ពួកយើងមានតួនាទីសំខាន់ដើម្បីលើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តដល់ការពិភាក្សាដោយបើកចំហ និងការសន្ទនាជាមួយកុមារ គ្រួសារ សហគមន៍ និងតាមរយៈប្រពន្ធ័ផ្សព្វផ្សាយ។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | • ពួកយើងផ្តល់ឱកាសសម្រាប់កិច្ចសន្ទនា ដោយបើកចំហស្តីពីការការពារកុមារ នៅតាមសាលារៀន វិទ្យាស្ថាន និងមជ្ឈមណ្ឌលសហគមន៍។ ចំណុចនេះអាចរួមបញ្ចូលទាំងការលើកកម្ពស់ការយល់ដឹង និងការអប់រំសម្រាប់កុមារ និងសម្រាប់ក្មេងជំទង់ ស្តីពីរបៀបការពារខ្លួន ឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ។<br>• នេះជាមធ្យោបាយដែលត្រូវបានអះអាងថានឹងលើកកំពស់ដល់ការផ្លាស់ប្តូរសង្គម និងកាត់បន្ថយការអនុវត្តដែលប្រកបដោយគ្រោះថ្នាក់ចំពោះកុមារ។<br>• ការពិភាក្សានិងការទំនាក់ទំនងជាលក្ខណៈបើកចំហ ជួយជំរុញអាកប្បកិរិយានៃការផ្លាស់ប្តូរទៅលើកម្រិតមួយ ដែលមានទំហំធំជាងនេះ។ | |
| **ស្លាយទី៤៧**<br> | *ឧទាហរណ៍ នៃគំរូនៃការអនុវត្តន៍ល្អៗ៖*<br>មានឧទាហរណ៍ជាច្រើននៃការអប់រំជាសាធារណៈ និងការលើកកម្ពស់ការយល់ដឹងស្តីពីការការពារកុមារ។ ជារឿយៗ គំរូទាំងនេះមានទម្រង់ជាការការអប់រំនៅតាមបណ្តាញផ្សព្វផ្សាយ (ដូចជាវិទ្យុ ទូរទស្សន៍ កាសែត) និងតាមអ៊ីនធើណេត។ ឧទាហរណ៍នៃគំរូនេះនៅចក្រភពអង់គ្លេស គឺមជ្ឈមណ្ឌលការពារកុមារពីការកេងប្រវ័ញ្ច និងមណ្ឌលការពារកុមារ បានបង្កើតគេហទំព័រមួយដើម្បីផ្តល់ព័ត៌មានទៅឲ្យកុមារ ឪពុកម្តាយ និងអ្នកអប់រំពីរបៀបការពារកុមារនៅក្នុងមជ្ឈដ្ឋានអ៊ីនធើណេត។<br>**?** *សំណួរឆ្លុះបញ្ចាំង/ការពិភាក្សា (អាចជ្រើសរើសបាន)*<br>• តើមានគំរូល្អៗអ្វីខ្លះនៅក្នុងការពិភាក្សាជាលក្ខណៈបើកចំហនេះដែលកំពុងកើតឡើងនៅក្នុងសហគមន៍ និងប្រទេសរបស់អ្នក?<br>• តើមានឱកាសផ្សេងទៀតណាខ្លះ សម្រាប់បង្កើតជាគំរូទាំងនេះ? | អ្នកសម្របសម្រួលគួរតែព្យាយាមប្រមូលឧទាហរណ៍ដែលពាក់ព័ន្ធទៅនឹងសហគមន៍នេះ នៅថ្នាក់ជាតិ ឬក្នុងមូលដ្ឋាន។ ឧទាហរណ៍ក្នុងមូលដ្ឋាន នៃការសន្ទនាដោយបើកចំហអាចរួមបញ្ចូលទាំង៖ សុវត្ថិភាពតាមផ្លូវ (ឧ. ត្រូវការប័ណ្ណបើកបរ, យើងប្រាប់កូនចៅរបស់យើងពីវិធីឆ្លងផ្លូវ) ទឹកជំនន់ និងការប្រកាសព័ត៌មានពីអាកាសធាតុ (វិធីដែលសហគមន៍ជជែកពិភាក្សា និងត្រៀមបង្ការសម្រាប់ព្រឹត្តិការណ៍នេះ)។<br>ឧទាហរណ៍ខ្លះៗនៅក្នុងប្រទេស រួមមាន៖ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| ស្លាយទី៤៨ •<br> | *២. ការការពារ*<br>• ការពារប្រសើរជាងព្យាបាល។<br>• ការប្រឹងប្រែងការពារជាមុនរបស់អ្នកចំពោះទង្វើរំលោភបំពានផ្លូវភេទកុមារ អាចធ្វើឲ្យកុមាររួចផុតពីគ្រោះថ្នាក់ធ្ងន់ធ្ងរ និងដែលធ្វើឲ្យអន្តរាយដល់កុមារអស់មួយជីវិត។<br>• យុទ្ធសាស្ត្រការពារ អាចប្រើរួមគ្នានៅក្នុងបរិបទផ្សេងៗគ្នា។<br>• ឧទាហរណ៍៖ សាលារៀន សេវាថែទាំកុមារ សួនកុមារ និងទីសាធារណៈផ្សេងទៀត។ | អ្នកសម្របសម្រួល គួរតែអង្កេត និងចែករំលែកឧទាហរណ៍មកពីថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិនៃសកម្មភាពបង្ការ ដែលសមស្របបំផុត/ពាក់ព័ន្ធនឹងសហគមន៍ដែលវេទិកាពិភាក្សាបានរៀបចំឡើង។<br>ឧទាហរណ៍ខ្លះៗ នៅក្នុងប្រទេសរួមមាន៖ |
| ស្លាយទី៤៩ •<br> | • គម្រូយុទ្ធសាស្ត្របង្ការនៅក្នុងស្ថាប័នរួមមាន៖<br>– ធ្វើការត្រួតពិនិត្យលើជីវប្រវត្តិ និងពិនិត្យទៅលើមនុស្ស ដែលត្រូវធ្វើការជាមួយកុមារ ដូចជាគ្រូបង្រៀនជាដើម។ ការត្រួតពិនិត្យបែបនេះគួរធ្វើឡើងចំពោះមនុស្ស ដែលនៅក្នុងប្រទេស និងមកពីក្រៅប្រទេស។<br>– ចាត់ទុកការរាយការណ៍អំពីបញ្ហាបារម្ភនានាជាកត្តាសំខាន់ ហើយស៊ើបអង្កេតទៅលើការសង្ស័យនានា។<br>– ដាក់កម្រិតលើការឲ្យមនុស្សប្លែកមុខដែលចូលទៅរកកុមារ។<br>– ដាក់កម្រិតលើទីកន្លែងនានា ដែលអាចមានកុមារនៅតែឯងជាមួយមនុស្សពេញវ័យ។<br>• គោលនយោបាយទាំងនេះ អាចត្រូវបានបង្កើតឡើងជាផ្លូវការ សម្រាប់ស្ថាប័នមូលដ្ឋានទាំងអស់។ | |
| ស្លាយទី៥០ •<br> | • សំដែងការមិនអត់ធ្មត់ចំពោះការរំលោភបំពានផ្លូវភេទកុមារនៅក្នុងសហគមន៍។ ឧទាហរណ៍៖ នៅក្នុងកម្មវិធីសាធារណៈផ្សេងៗ នៅក្នុងអង្គប្រជុំធំៗ និងតាមរយៈសេចក្តីប្រកាសនានា តាមការគួរ។ នេះមិនមែនគ្រាន់តែជាការធានាចំពោះសហគមន៍ប៉ុណ្ណោះទេ តែវាក៏ធ្វើឲ្យអ្នកដែលអាចជាអ្នករំលោភបំពាន មានការខ្លាចរអារកាន់តែខ្លាំងឡើងថែមទៀត។ | |

<table>
<tr><th>ស្លាយ</th><th>សារគន្លឹះ</th><th>កំណត់សំគាល់ជំនួយ</th></tr>
<tr><td>

**ស្លាយទី៥១ ●**




</td><td>

• ឧទាហរណ៍មួយផ្សេងទៀត បង្ហាញពីកិច្ចការពារគឺ កម្មវិធីអន្តរាគមន៍ឲ្យបានមុនដើម្បីគាំទ្រគ្រួសារដែលងាយរងគ្រោះឲ្យជួយការពារកុមារឲ្យមានសុវត្ថិភាព។<br>
• អន្តរាគមន៍នេះរាប់ទាំងទីកន្លែងណាដែលអាចមានការសង្ស័យ ហើយត្រូវរាយការណ៍ពីឥរិយាបថមិនត្រឹមត្រូវនោះផង។ បើមានវិធានការភ្លាមៗបានទាន់ពេល វាអាចការពារមិនឲ្យការរំលោភបំពានដទៃទៀតកើតឡើង។

</td><td></td></tr>
<tr><td>

**ស្លាយទី៥២**




</td><td>

*គំរូល្អៗ សម្រាប់អនុវត្ត៖*

នៅក្នុងប្រទេសជាច្រើន គ្រប់បុគ្គលដែលធ្វើការ ឬស្ម័គ្រចិត្តបម្រើការងារជាមួយកុមារ ត្រូវឆ្លងកាត់ការត្រួតពិនិត្យ ឬពិនិត្យពិច័យឲ្យបានត្រឹមត្រូវជាមុនសិន។ ប៉ូលីសមូលដ្ឋាន /ជាតិ ត្រូវធ្វើការត្រួតពិនិត្យទៅលើបុគ្គលិកដើម្បីឲ្យដឹងថា តើអ្នកដែលអាចជាបុគ្គលិកនោះ មានរងការចោទប្រកាន់ ឬមានទោសដែលធ្វើឲ្យគាត់មិនសមនឹងធ្វើការជាមួយកុមារឬទេ ( ឧទាហរណ៍ដូចជា បទល្មើសទៅលើកុមារ បទល្មើសគ្រឿងញៀន ឃាតកម្ម ឬការប្រើប្រាស់អំពើហិង្សា )។

**?** *សំណួរឆ្លុះបញ្ចាំង/ការពិភាក្សា ( អាចជ្រើសរើស )៖*

• តើមានគំរូល្អអ្វីខ្លះ  ដែលបង្ហាញពីសកម្មភាពបង្ការ ដែលកើតមាននៅក្នុងសហគមន៍ ឬប្រទេសរបស់អ្នក ?<br>
• តើមានឱកាសអ្វីផ្សេងទៀតឬទេ សម្រាប់ពង្រឹងបន្ថែមទៅលើគំរូទាំងអស់នេះ ?

</td><td></td></tr>
</table>

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| ស្លាយទី៥៣ •<br> | *៣. កិច្ចការពារ*<br>• កិច្ចការពារ សំដៅលើការសម្គាល់ច្បាស់ថាកុមារស្ថិតក្នុងគ្រោះថ្នាក់ និងការមានវិធានការសមស្រប។<br>• ចាំបាច់ត្រូវដឹងពីអ្វីដែលត្រូវធ្វើ និងរបៀបឆ្លើយតប ក្នុងករណីអ្នកទទួលបានព័ត៌មានអំពីករណីរំលោភបំពានណាមួយ ដែលអាចនឹងកើតឡើង។<br>• មធ្យោបាយនានា ដែលអាចឲ្យអ្នកទទួលបានព័ត៌មានផ្សេងៗ រួមមាន ៖<br>– ការសង្ស័យនានារបស់អ្នក។<br>– ព័ត៌មានដែលបានមកពីកុមារ។<br>– ព័ត៌មានបានមកពីមនុស្សពេញវ័យ។<br>– ព័ត៌មានបានមកដោយប្រយោល ពីអ្នកណាម្នាក់។ | |
| ស្លាយទី៥៤ •<br> | **តើអ្នកត្រូវឆ្លើយតបដូចម្តេចខ្លះ ចំពោះការលាតត្រដាងពីការពិតណាមួយ?**<br>ប្រសិនបើកុមារម្នាក់លាតត្រដាងពីការពិតណាមួយថា ខ្លួនរងការរំលោភបំពាន៖<br>• សូមស្តាប់កុមារដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់នូវអ្វីដែលកុមារនិយាយប្រាប់។<br>• លើកទឹកចិត្តកុមារថា វាជាការល្អណាស់ ដែលគាត់ផ្តល់ព័ត៌មានបែបនេះ ហើយថាគាត់ពុំមានកំហុស ឬត្រូវគេស្តីបន្ទោសចំពោះស្ថានភាពនោះឡើយ។<br>• សូមពន្យល់ថា អ្នកនឹងត្រូវផ្តល់ព័ត៌មាននេះជាមួយមនុស្សដែលពាក់ព័ន្ធ ដើម្បីរក្សាសុវត្ថិភាពដល់កុមារ (មិនត្រូវសន្យារក្សាព័ត៌មាននេះទុកជាការសម្ងាត់ឡើយ)។<br>• មិនត្រូវធ្វើជាអ្នកស៊ើបអង្កេតឡើយ៖ លើកលែងតែអ្នកជាបុគ្គលិកផ្នែកសង្គមកិច្ច ឬជាប៉ូលីសប៉ុណ្ណោះ បើមិនដូច្នេះទេ អ្នកគ្មាននាទីស៊ើបអង្កេតឡើយ។<br>• អ្នកអាចសួរសំណួរមួយចំនួនបាន ប៉ុន្តែមិនអាចសួរសំណួរនាំមុខនានា ដូចជាសំណួរដែលបង្ខំ ឬជំរុញឲ្យកុមារឆ្លើយចម្លើយណាមួយជាក់លាក់ជាដើម។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | • ធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរ ពីអ្វីដែលអ្នកបានឮ ឲ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីបញ្ចប់ការសន្ទនា។ អ្វីដែលសំខាន់នោះគឺមិនត្រូវធ្វើរបាយការណ៍នៅចំពោះមុខកុមារឡើយ។ ដើម្បីចៀសវាងការភាន់ច្រឡំ ការបារម្ភ ឬកំហុសណាមួយនោះ មិនត្រូវឲ្យកុមារបានស្តាប់ឮការសន្ទនាដោយចៃដន្យអំពីការបង្ហាញព័ត៌មានរបស់កុមារនោះឡើយ។<br>• ត្រូវពិភាក្សាព័ត៌មាននោះដោយសម្ងាត់ និងប្រាប់តែចំពោះអ្នកជំនាញណាដែលគួរប្រាប់ប៉ុណ្ណោះ។<br>• មិនត្រូវប៉ាន់ស្មានទាបលើភាពសំខាន់ដែលខ្លួនអ្នកមានឡើយ ប៉ុន្តែក៏ត្រូវចៀសវាងការទទួលខុសត្រូវតែម្នាក់ឯង ក្នុងការដោះស្រាយស្ថានភាពបែបនោះ។<br>• អ្វីដែលជាការចាំបាច់បំផុតនោះ គឺអ្នកត្រូវប្រាប់ព័ត៌មាននេះ ដល់អ្នកជំនាញដែលអាចជួយដល់ស្ថានភាពនោះបាន។ អ្នកតំណាងសហគមន៍ដទៃទៀត(រួមទាំងសេវាសុខភាព ប៉ូលីស សេវាផ្តល់ទីជម្រក អង្គការសប្បុរសធម៌ និងសេវាសង្គមកិច្ច ) ប្រហែលជាអាចនឹងបានដឹងព័ត៌មានអំពីការ រក្សាសុវត្ថិភាពដល់កុមាររួចហើយ។ បើរួមគ្នាពិភាក្សាអំពីព័ត៌មានដែលកុមារបានប្រាប់នោះ  ព័ត៌មាននេះអាចទាក់ទាញចំណាប់អារម្មណ៍មនុស្សទៅលើបញ្ហាសំខាន់នានា សម្រាប់រក្សាសុវត្ថិភាពដល់កុមារ។ ក្នុងករណីព័ត៌មាននេះមិនត្រូវបាន ចែករំលែកដល់អ្នកជំនាញដែលដែលពាក់ ព័ន្ធទេនោះ កុមារម្នាក់អាចនឹងត្រូវគេដាក់ ឲ្យស្ថិតនៅក្នុងមជ្ឈដ្ឋានអសុវត្ថិភាព ដែល អាចនឹងបណ្តាលឲ្យមានគ្រោះថ្នាក់។<br>• ត្រូវចាំថា សុវត្ថិភាពកុមារ គឺជាកត្តាចម្បងដែលត្រូវយកចិត្តទុកដាក់។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥៥** •<br><br> | ត្រូវផ្តល់ព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងទៅកាន់អាជ្ញាធរមូលដ្ឋាន និងអង្គការនានាដែលយើងគួររាយការណ៍ប្រាប់។ | សូមមើល **កាតយកតាមខ្លួន (តើមានអ្នកណាផ្សេងទៀត ដែលអាចជួយបាន?)** ហើយសូមផ្តល់ព័ត៌មានសម្រាប់ទំនាក់ទំនងក្នុងមូលដ្ឋាន និងក្នុងប្រទេសទៅឲ្យអ្នកចូលរួម។ លេខទូរស័ព្ទទំនាក់ទំនងថ្នាក់ជាតិសម្រាប់ការរាយការណ៍ពីកិច្ចការពារកុមារនៅក្នុងប្រទេស។<br><br> |
| **ស្លាយទី៥៦** •<br><br> | *សរុបសេចក្តីមកៈ*<br>• ត្រូវមានវិធានការណ៍បន្ទាន់ ក្នុងករណីទទួលបានព័ត៌មានថា មានកុមារណាម្នាក់កំពុងស្ថិតក្នុងគ្រោះថ្នាក់នៃការរំលោភបំពាន បានក្លាយជាអ្នករងគ្រោះម្នាក់នៅក្នុងការរំលោភបំពាន។<br>• វិធានការការពារសុវត្ថិភាពរាងកាយកុមារដែលកំពុងស្ថិតក្នុងភាពសង្ស័យ។<br>• បញ្ជូនករណីទាំងនេះ ទៅឲ្យបុគ្គល ឬ ភ្នាក់ងារមានសមត្ថកិច្ច។<br>• អនុវត្តតាមនីតិវិធីសហគមន៍ ដែលបានព្រមព្រៀងគ្នារួច។<br>**?** *សំណួរឆ្លុះបញ្ចាំង/ពិភាក្សាៈ*<br>• ត្រូវពិនិត្យឲ្យបានច្បាស់ថា តើអ្នកចូលរួមទាំងអស់បានយល់ពីអ្វីដែលខ្លួនត្រូវធ្វើ ហើយឬនៅ ក្នុងករណីពួកគាត់បានដឹងថា កុមារកំពុងស្ថិតក្នុងគ្រោះថ្នាក់។ | |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| | • វិធានការជាក់លាក់ដែលត្រូវអនុវត្ត នឹងត្រូវអាស្រ័យទៅលើតួនាទីរបស់អាជ្ញាធរនៅក្នុងសហគមន៍ និងអំណាចស្របច្បាប់របស់អ្នក។ ឧទាហរណ៍៖ ប៉ូលីសមានសិទ្ធិចាប់ខ្លួន ឬស៊ើបអង្កេតបទឧក្រិដ្ឋនានា រួមទាំងការរារាំងអ្នកដែលជាប់ពាក់ព័ន្ធនៅក្នុងការធ្វើឲ្យកុមារស្ថិតនៅក្នុងការរំលោភបំពាន។<br>• គ្រប់ករណីទាំងអស់ ចំណុចសំខាន់បំផុតគឺសុវត្ថិភាពកុមារ គឺជាកត្តាសំខាន់បំផុតដែលត្រូវយកចិត្តទុកដាក់។ ឧទាហរណ៍៖ ក្នុងករណីត្រូវរំលោភបំពាន គួរមានវិធានការបន្ទាន់នានា ដើម្បីការពារផ្នែករាងកាយរបស់កុមារ។ នេះមានន័យថា ជនដែលត្រូវគេសង្ស័យថាជាអ្នករំលោភបំពាន គួរត្រូវបញ្ជូនចេញឲ្យឆ្ងាយពីកុមារ។ លើកលែងតែគ្រួសារជាអ្នកកំពុងបង្កគ្រោះថ្នាក់ដល់កុមារ បើមិនដូច្នេះទេ មិនគួរឲ្យកុមារទៅរស់នៅកន្លែងឆ្ងាយពីគ្រួសារឡើយ។ | |
| **ស្លាយទី៥៧**<br><br> | *សកម្មភាព៖ សេណារីយ៉ូករណីសិក្សា*<br>• បែងចែកអ្នកចូលរួមជាក្រុមតូចៗ<br>• ប្រឋបក្រុមចូលគ្នា ដើម្បីឲ្យមានអ្នកតំណាងវិស័យផ្សេងគ្នានៅក្នុងក្រុមនីមួយ (ឧទាហរណ៍៖ វិស័យអប់រំ សុខភាព សង្គមកិច្ច ការអនុវត្តច្បាប់)<br>• ត្រូវផ្ដល់ឯកសារសេណារីយ៉ូមួយច្បាប់ដែលបានមកពីប័ណ្ណសេណារីយ៉ូលើករណីសិក្សាអំពីអ្នកតំណាងសហគមន៍(ឧបសម្ព័ន្ធទី៧)<br>• ប្រាប់ក្រុមនីមួយៗឲ្យពិភាក្សា ពីករណីសិក្សា និងរៀបចំឆ្លើយសំណួរនានា ដែលមានស្រាប់នៅក្នុងឯកសារចែកជូន របស់ពួកគេ។ បើមានពេល អ្នកអាចឲ្យសេណារីយ៉ូមួយបន្ថែមទៀតទៅក្រុមនីមួយៗ។<br>• សូមពិភាក្សាទៅលើចម្លើយរបស់ក្រុមនីមួយៗ។<br>• បន្ទាប់ពីក្រុមនីមួយបានបង្ហាញចម្លើយរបស់ខ្លួនហើយ ត្រូវសួរក្រុមដទៃទៀតមើលថាតើពួកគាត់មានគំនិតអ្វីបន្ថែមទៀតដែរឬទេ។ | អ្នកសម្របសម្រួលគួរតែជ្រើសរើសសេណារីយ៉ូករណីសិក្សាដែលពាក់ព័ន្ធ ពីក្នុង **ឧបសម្ព័ន្ធទី ៧** ហើយត្រូវថតចម្លងទុកមុន។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៥៨**<br><br> | *សកម្មភាព៖ បង្កើតសហគមន៍មួយ ដែលមានសុវត្ថិភាពដល់កុមារ៖ ផែនការការពារកុមាររបស់យើង (អាចជ្រើសរើសបានចំពោះកម្មវិធីពេញឲ្យថ្ងៃ)*<br>អាស្រ័យលើទំហំក្រុម និងពេលវេលា ចំណុចនេះអាចធ្វើការពិភាក្សាជាក្រុមធំ ឬតូច។<br>• ត្រូវណែនាំអ្នកចូលរួមថា មិនមែនជាគណៈកម្មាធិការថ្មី ដែលទទួលខុសត្រូវសម្រាប់ការសម្របសម្រួលកិច្ចការពារកុមារក្នុងសហគមន៍របស់ពួកគេ។<br>• ប្រាប់ពួកគាត់ថា ពេលនេះពួកគាត់ត្រូវរៀបចំបង្កើតផែនការសម្រាប់រយៈពេលមួយឆ្នាំ។<br>– តើមានកត្តាសំខាន់ៗអ្វីខ្លះ ដែលដាក់កុមារឲ្យប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពាន (រួមទាំងការរំលោភបំពានផ្លូវភេទផងដែរ)នៅក្នុងសហគមន៍នេះ?<br>– តើអ្នកនឹងធ្វើសកម្មភាពអ្វីខ្លះក្នុងសហគមន៍នេះ ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពាន (រួមទាំងការរំលោភបំពានផ្លូវភេទ)?<br>– តើមានសកម្មភាពជាអាទិភាពសំខាន់ៗអ្វីខ្លះ ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ?<br>– តើអ្នកតំណាងសហគមន៍ណាខ្លះ ដែលត្រូវចូលរួមក្នុងបណ្តាញនេះ?<br>– តើមាននរណាខ្លះទៀត ដែលត្រូវចូលរួម?<br>– តើវិស័យណាដែលទទួលខុសត្រូវក្នុងការដឹកនាំ/គ្រប់គ្រងបណ្តាញសហគមន៍?<br>– តើវិស័យនីមួយៗ (ឧ. អប់រំ សុខាភិបាល សង្គមកិច្ច) មានតួនាទីជាក់លាក់អ្វីខ្លះ?<br>តើអ្នកនឹងត្រូវការធនធានអ្វីខ្លះ?<br>• ពិភាក្សាលើការឆ្លើយតប<br>• លើកឡើងនូវយោបល់ដែលត្រឹមត្រូវជាងគេ ដែលក្រុមបានបង្ហាញ ហើយលើកទឹកចិត្តដល់ពួកគេ បន្តអនុវត្តគំនិតទាំងនេះក្រោយពេលវេទិកាពិភាក្សាបញ្ចប់។ | ឧទាហរណ៍ដែលគួរតែដាក់បញ្ចូលមានដូចជា៖<br>• គោលនយោបាយនៅក្នុងសាលា និងនៅក្នុងមជ្ឈមណ្ឌលសុខភាពនានា។<br>• ការព្រមព្រៀងគ្នាទៅវិញទៅមករវាងទីភ្នាក់ងារ និងនាយកដ្ឋាននានាដោយមានទម្រង់ពិភាក្សាផ្សេងៗដែលបានព្រមព្រៀងគ្នា។<br>• ការសម្ងាត់ រឿងផ្ទាល់ខ្លួនព្រមទាំងសុវត្ថិភាពជនរងគ្រោះ និងគ្រួសារ។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ការសន្និដ្ឋាន** | | |
| **ស្លាយទី៥៩** ●   | *សកម្មភាព៖ ការវាយតម្លៃ*<br>• ដូច្នេះពួកយើងអាចបន្តធ្វើឲ្យសកម្មភាពរបស់យើងជាមួយកុមារបានប្រសើរឡើង។ យើងស្វាគមន៍មតិយោបល់របស់លោក លោកស្រីទាំងអស់ដែលឆ្លើយតបទៅនឹងសំណួរខាងក្រោម៖<br>– តើវគ្គសិក្សានេះមានសារៈប្រយោជន៍ដែរឬទេ ?<br>– តើព័ត៌មានអ្វីដែលមានសារៈប្រយោជន៍បំផុតដែលអ្នកបានរៀនសូត្រនៅថ្ងៃនេះ ?<br>– តើមានអ្វីដែលយើងគួរផ្លាស់ប្តូរសម្រាប់វគ្គសិក្សាខាងមុខឬទេ ?<br>• ក្រៅពីនេះ អ្នកសម្របសម្រួលអាចចែកទម្រង់បែបបទស្ទង់មតិរបស់ខ្ញុំ ( ឧបសម្ព័ន្ធទី៨ ) សម្រាប់ឲ្យអ្នកចូលរួមបំពេញ។<br>*សកម្មភាព៖ សំណួររំឭកមេរៀនសារឡើងវិញ*<br>• ពេលនេះ ខ្ញុំចង់ពិនិត្យមើលថា តើចម្លើយរបស់អ្នកទាំងអស់គ្នាចំពោះសំណួរទាំងនេះមានភាពខុសគ្នា ឬដូចគ្នាទៅនឹងចម្លើយដែលអ្នកបានឆ្លើយមុនពេលបានរៀន។<br>• សំណួររំឭកមេរៀនសារឡើងវិញ ( **ឧបសម្ព័ន្ធទី៤** ) ហើយត្រូវទុកពេលឲ្យអ្នកចូលរួមពី៣-៤នាទីដើម្បីបំពេញទម្រង់នោះ បន្ទាប់មកត្រូវប្រមូលទម្រង់នោះទុក ( ឈ្មោះមិនសំខាន់ឡើយ )។<br>• បន្ទាប់មក ត្រូវប្រាប់ចម្លើយត្រឹមត្រូវដល់អ្នកចូលរួម ដើម្បីធានាថាគ្រប់គ្នាបានយល់អំពីសារសំខាន់ៗមុននឹងបញ្ចប់វេទិកាពិភាក្សា។ | ទម្រង់បែបបទស្ទីពីគំនិតរបស់ខ្ញុំ មាននៅក្នុង**ឧបសម្ព័ន្ធទី ៨**។ ត្រូវថតចម្លងទម្រង់បែបបទទាំងនេះ ឲ្យអ្នកចូលរួមម្នាក់ៗ មុនពេលដំណើរការវេទិកាពិភាក្សា លើកលែងតែមានការវាយតម្លៃដោយផ្ទាល់មាត់។<br>សំណួររំឭកមេរៀនសារឡើងវិញ មាននៅក្នុង **ឧបសម្ព័ន្ធទី៤**។ ដូចគ្នាទៅនឹងសំណួរមុនផ្តើមមេរៀនដែរ ការឆ្លើយតបទៅនឹងសំណួរទាំងនេះអាចធ្វើឡើង ដោយមានការចូលរួមផុសផុលតាមរយៈការប្រើប្រាស់ប័ណ្ណ ឆ្លើយតបនៅក្នុងឧបសម្ព័ន្ធទី៥ ឬតាមរយៈការឲ្យអ្នកចូលរួមទៅកាន់កន្លែង ដែលមានដាក់សញ្ញាខ្វែង ( x ) សញ្ញាធីក ( ✓ )និងសញ្ញាសួរ ( ? )។<br>អ្នកសម្របសម្រួលគួរកត់ត្រា ចម្លើយបានមកពីការពិភាក្សាសំណួរវាយតម្លៃ និងសំណួររំឭកមេរៀនសារឡើងវិញ ( ប្រសិនបើឆ្លើយសំណួរដោយប្រើប្រាស់ការចូលរួម ) ដើម្បីអាចយកចម្លើយទាំងនេះទៅបញ្ចូលទៅក្នុងរបាយការណ៍ក្រោយការបណ្តុះបណ្តាល ( **ឧបសម្ព័ន្ធទី៩** )។ |

| ស្លាយ | សារគន្លឹះ | កំណត់សំគាល់ជំនួយ |
|---|---|---|
| **ស្លាយទី៦០** ●   | • អរគុណអ្នកចូលរួមចំពោះការយកចិត្តទុកដាក់ និងការចូលរួមមតិយោបល់របស់ពួកគេ។<br>• រំលឹកអ្នកចូលរួមឡើងវិញពីតួនាទីដ៏សំខាន់ដែលអ្នកតំណាងសហគមន៍អាចធ្វើបានក្នុងកិច្ចការពារកុមារពីការរំលោភបំពានផ្លូវភេទ។<br>• លើកទឹកចិត្តអ្នកចូលរួមឲ្យប្រើប្រាស់ព័ត៌មានដែលពួកគាត់បានរៀនសូត្រពីវគ្គសិក្សាថ្ងៃនេះ ដើម្បីកសាងបរិដ្ឋានប្រកបដោយកិច្ចការពារមួយសម្រាប់កុមារ។<br>• អញ្ជើញអ្នកចូលរួមឲ្យទាក់ទងទៅតាមព័ត៌មានសម្រាប់ទំនាក់ទំនង ដែលត្រូវបានរៀបរាប់ ក្នុងអំឡុងវគ្គនេះប្រសិនបើពួកគាត់មានកង្វល់អ្វីមួយ ពីការរំលោភបំពានផ្លូវភេទលើកុមារ។<br>• សូមសង្កត់ធ្ងន់ថា តាមរយៈការធ្វើសកម្មភាពងាយៗ ពួកយើងអាចធ្វើឲ្យសំណាញ់សុវត្ថិភាពសម្រាប់កុមារនៅក្នុងសហគមន៍យើងកាន់តែមានភាពប្រសើរឡើង។ | |

# កំណត់ត្រា

# កំណត់ត្រា

# ផ្នែកទី៣៖

# ឧបសម្ព័ន្ធ



# ឧបសម្ព័ន្ធទី១៖ កាតយកតាមខ្លួន

គួរថតចម្លងកាតទាំងនេះ សម្រាប់អ្នកចូលរួមនីមួយៗ។ អ្នកចូលរួមទាំងអស់ អាចយកកាតនេះទៅបាន បន្ទាប់ពីវេទិកាពិភាក្សា ដើម្បីរំឭកចំណុចសំខាន់ៗ ដែលខ្លួនបានរៀន និងដើម្បីផ្សព្វផ្សាយប្រាប់ដល់គ្រួសារ និងសហគមន៍របស់ខ្លួនផង។ ជាការគួរ សូមថតចម្លងប័ណ្ណចែកជូន ផ្នែកក៥ និងក៦ ជាទម្រង់ប័ណ្ណដែលអាចសរសេរសងខាងបាន។ ធ្វើបែបនេះ នឹងធ្វើឲ្យអ្នកចូលរួមប្រើប្រាស់ប័ណ្ណទាំងនេះ ធ្វើជាធនធានដែលអាចឲ្យពួកគាត់ចងចាំបានល្អ និងមានប្រយោជន៍។

# រក្សាសុវត្ថិភាពកុមារ ពីការរំលោភបំពានផ្លូវភេទ

## អ្នកតំណាងសហគមន៍



Australian Aid

World Vision

# ការការពារកុមារ គឺជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា

កុមារ គឺជាមនុស្សទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។ កុមារត្រូវការការការពារជាពិសេស។ មនុស្សគ្រប់រូបដែលមានទំនាក់ទំនងវិជ្ជាជីវៈជាមួយកុមារក្នុងសហគមន៍ (រួមមាន គ្រូបង្រៀន បុគ្គលិកសុខាភិបាល បុគ្គលិកសង្គមកិច្ច និងអ្នកបម្រើការផ្នែកយុវជន អ្នកដឹកនាំសាសនា មន្ត្រីប៉ូលីស មន្ត្រីសហគមន៍ ) មានតួនាទីសំខាន់ក្នុងការទប់ស្កាត់ កំណត់សញ្ញាណ និងឆ្លើយតបទៅនឹងគ្រោះថ្នាក់ដែលកុមារប្រឈម។




**យើងរួមគ្នា បង្កើតសហគមន៍មួយដែលមានសុវត្ថិភាពសម្រាប់កុមារ។**

# តើអ្វីជាការរំលោភបំពានកុមារ ?

ការរំលោភបំពានកុមារ គឺជាសកម្មភាពណាមួយ (ឬ មិនមែនសកម្មភាព) ដែលធ្វើឡើងមិនមែនដោយចៃដន្យ  ហើយធ្វើឲ្យកុមារឈឺចាប់ ឬធ្វើឲ្យកុមារមានគ្រោះថ្នាក់ ។

មានកុមាររាប់លាននាក់ នៅជុំវិញពិភពលោក បានទទួលរងគ្រោះដោយសារការរំលោភបំពានជារៀងរាល់ថ្ងៃ ។ ការរំលោភបំពានកុមារកើតឡើងនៅគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក ។

## ប្រភេទនៃការរំលោភបំពានកុមារ

ការរំលោភបំពានកុមារមាន៤ប្រភេទសំខាន់ៗ ។ ជាញឹកញាប់ការរំលោភបំពានលើសពីមួយ ប្រភេទបានកើតឡើងក្នុងពេលដំណាលគ្នា ។

- ការរំលោភបំពានផ្លូវកាយ
- ការរំលោភបំពានផ្លូវភេទ
- ការរំលោភបំពានផ្លូវចិត្ត
- ការមិនអើពើ

## ផលប៉ះពាល់នៃការរំលោភបំពានកុមារ

ការរំលោភបំពានមានផលប៉ះពាល់ធ្ងន់ធ្ងរលើកុមារ ហើយអាចបណ្ដាលឲ្យកុមារមានបញ្ហាទាំងផ្លូវកាយ និងផ្លូវចិត្តក្នុងរយៈពេលវែង។

ផលវិបាកនៃការរំលោភបំពានគឺមិនត្រឹមតែប៉ះពាល់ទៅលើជនរងគ្រោះប៉ុណ្ណោះទេប៉ុន្តែវាក៏ជះឥទ្ធិពល ទៅដល់គ្រួសារ សហគមន៍ និងសង្គមជាតិផងដែរ ។

យើងមិនត្រូវបន្ទោសកុមារចំពោះការរំលោភបំពាន ឬផលប៉ះពាល់ដែលកើតមានចំពោះគ្រួសារ និងសហគមន៍នោះឡើយ។

# តើអ្វីជាការរំលោភបំពានកុមារ ?



រំលោភបំពានដោយប្រើពាក្យសម្តីមិនល្អចំពោះកុមារ



និយាយលូកលាន់លើកុមារដែលមិនចាំបាច់



ប៉ះពាល់លើកុមារនៅផ្នែកណាមួយនៃរាងកាយដែលកុមារមិនចង់ឲ្យប៉ះ



មិនស្តាប់សំដីកុមារ



នាំឲ្យកុមារឃើញសកម្មភាព ឬរូបអាសអាភាសផ្លូវភេទ



បង្ខំកុមារឲ្យប៉ះពាល់ផ្នែកណាមួយនៃរាងកាយរបស់ខ្លួន



ធ្វើឲ្យកុមារបាត់បង់ទំនុកចិត្តលើខ្លួនឯង



វាយដំ ឬធ្វើឲ្យកុមារឈឺចាប់ ជារឿយៗ ដើម្បីរំសាយកំហឹងខ្លួនឯង



បោកបញ្ឆោតកុមារ



មិនយកចិត្តទុកដាក់ថែទាំកុមារ ដូចជាមិនសម្អាត ស្លៀកពាក់ និងឲ្យចំណីអាហារ



ប្រើប្រាស់កុមារធ្វើជាអ្នកបម្រើ



មិនយកចិត្តទុកដាក់លើសេចក្តីត្រូវការផ្នែកសតិអារម្មណ៍របស់កុមារ



ធ្វើឲ្យកូនរបស់ខ្លួនក្លាយជា "អ្នកបម្រើ" ដោយមិនឲ្យមានពេលលំហែរនិងសិក្សា



វាយដំ និងសើចចំអកឲ្យកុមារនៅសាលារៀន



មិនយកចិត្តទុកដាក់លើតម្រូវការផ្នែកសុខភាពរាងកាយរបស់កុមារ



មិនយកចិត្តទុកដាក់លើតម្រូវការផ្នែកអប់រំរបស់កុមារ



ទុកកុមារចោលគ្មានអ្នកមើលថែ

រូបភាព និងអត្ថបទដកស្រង់ចេញពីផ្ទាំងរូបភាព "តើអ្វីទៅជាការរំលោភបំពានលើកុមារ" ដែលផលិតដោយ *Childline Thailand Foundation* ក្នុង គេហទំព័រ *http://childlinethailand.org*



# តើអ្វីជាការរំលោភបំពានផ្លូវភេទកុមារ ?

- ការរំលោភបំពានផ្លូវភេទកុមារ កើតមានឡើងនៅពេលមាននរណាម្នាក់ឲ្យកុមារពាក់ព័ន្ធក្នុង សកម្មភាពផ្លូវភេទ ដោយប្រើប្រាស់អំណាចរបស់ខ្លួនលើកុមារ ឬកេងចំណេញពីការទុកចិត្តរបស់ កុមារ។

- ការរំលោភបំពានផ្លូវភេទកុមាររួមបញ្ចូលទាំងអាកប្បកិរិយាផ្លូវភេទដែលមិនគួរគប្បីគ្រប់ប្រភេទ។ ទង្វើទាំងនេះ អាចរួមមានទាំងទង្វើដែលមានការប៉ះកាន់ ឬមិនមានប៉ះកាន់ទាល់តែសោះ។

- ការរំលោភបំពានផ្លូវភេទកុមាររួមមាន៖
  - ការផលិតរូបភាព/រូបថត/វីដេអូ ដែលមានលក្ខណៈរំលោភបំពានអំពីកុមារ។
  - ការបង្ខំកុមារឲ្យមើល ឬឲ្យចូលរួមក្នុងទង្វើផ្លូវភេទ
  - បង្ខិតបង្ខំកុមារឲ្យរួមភេទ ឬចូលរួមក្នុងទង្វើផ្លូវភេទជាមួយកុមារដទៃ ឬជាមួយមនុស្សធំ។

# តើអ្នកដឹងទេថា ?

## ការរំលោភបំពានផ្លូវភេទកុមារ គឺជាបញ្ហាសកល

ការរំលោភបំពានផ្លូវភេទកុមារ កើតឡើងនៅគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក។ សូម្បីតែសហគមន៍របស់យើង ក៏មិនប្រាកដថាគ្មាន ការរំលោភបំពានផ្លូវភេទកុមារដែរ។ ភាគច្រើននៃអ្នករំលោភបំពាន គឺជាអ្នកនៅក្នុងស្រុកនោះ។

## ជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ អាចមានទាំងកុមារា និងកុមារី

ទាំងកុមារា និងកុមារីសុទ្ធតែអាចជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទ។ កុមារភេទទីបី ឬកុមារដែលកំពុងស្វែងយល់អត្តសញ្ញាណផ្លូវភេទរបស់ខ្លួន អាចប្រឈមនឹងគ្រោះថ្នាក់កាន់តែខ្ពស់។ កុមារមានពិការភាព ( ពិការភាពគ្រប់ប្រភេទ ) ក៏អាចប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ផងដែរ។ ការរំលោភបំពានផ្លូវភេទ អាចកើតឡើងចំពោះកុមារមកពីគ្រប់សាវតាទាំងអស់។

## ជារឿយៗ អ្នករំលោភបំពាន ច្រើនតែជាមនុស្សដែលកុមារស្គាល់

ជារឿយៗ អ្នករំលោភបំពានផ្លូវភេទកុមារគឺច្រើនតែជាសមាជិកគ្រួសារ សមាជិកក្នុងសហគមន៍ ឬនរណាម្នាក់ដែលគេទុកចិត្ត។

## អ្នករំលោភបំពានអាចធ្វើខ្លួនជាមិត្តភក្តិជិតស្និទ្ធជាមួយកុមារ និងគ្រួសាររបស់ពួកគេ

ជារឿយៗ អ្នករំលោភបំពានច្រើនតែសាងមិត្តភាពជាមួយជនរងគ្រោះ និងគ្រួសាររបស់គេ ជាវិធីមួយដើម្បី "លាក់បាំង" ការរំលោភបំពានរបស់ពួកគេ។

## ការរំលោភបំពានផ្លូវភេទកុមារអាចកើតមានក្នុងវិស័យទេសចរណ៍

ជនបរទេសមួយចំនួនតូច ប្រើប្រាស់ការធ្វើដំណើរជាឱកាសដើម្បីរំលោភបំពានផ្លូវភេទកុមារ។ ពួកគេ គឺជាអ្នកទេសចរ អ្នកធ្វើដំណើរ ឬអ្នកតាំងលំនៅបរទេសទាំងឡាយណា ដែលរំលោភ បំពានផ្លូវភេទកុមារក្នុងប្រទេស ឬបណ្តាប្រទេសដែលខ្លួនកំពុងរស់នៅ ឬកំពុងទស្សនា។

## ជារឿយៗកុមារមិននិយាយប្រាប់មនុស្សធំអំពីការរំលោភបំពាននោះទេ

ដោយសារហេតុផលជាច្រើន ជារឿយៗកុមារតែងនៅស្ងៀមស្ងាត់មិននិយាយអំពីការរំលោភបំពាននោះទេ។ សូមពិនិត្យរកមើលសញ្ញានានា ជាជាងរង់ចាំឲ្យកុមារមករាយការណ៍។

## កុមារគ្រប់រូបមានសិទ្ធិទទួលបានការការពារ

កុមារគ្រប់រូបនៅទូទាំងពិភពលោក មានសិទ្ធិទទួលបានការការពារឲ្យរួចផុតពីការរំលោភបំពានគ្រប់ទម្រង់ទាំងអស់។ ក្នុងនាមជាមនុស្សធំ យើងមានភារកិច្ចការពារកុមារឲ្យរួចផុតពីគ្រោះថ្នាក់។ យើងមិនត្រូវស្តីបន្ទោសកុមារចំពោះការរំលោភបំពានដែលកើតលើរូបគេនោះឡើយ។

# តើអ្នករំលោភបំពានផ្លូវភេទកុមារ ប្រតិបត្តិការយ៉ាងដូចម្តេច ?

អ្នករំលោភបំពាន អាចប្រើប្រាស់វិធីផ្សេងៗជាច្រើនដើម្បីចូលទៅរកកុមារនិងរំលោភបំពានកុមារ។

មនុស្សជាច្រើនតែងគិតថា ការរំលោភបំពានផ្លូវភេទកុមារ ច្រើនតែកើតឡើងក្នុងលក្ខណៈជាការវាយប្រហារដោយមនុស្សមិនដែលស្គាល់គ្នា។ តាមពិត អ្នករំលោភបំពាន និង/ឬមេអណ្តើកច្រើន ចំណាយពេលដើម្បីសាងទំនាក់ទំនងជាមួយកុមារ ( និងពេលខ្លះជាមួយគ្រួសាររបស់កុមារ )។

ដំណើរការនេះហៅថា “ការល្បួង” ហើយអាចរួមមានជំហ៊ានជាច្រើន៖




អ្នករំលោភបំពានស្វែងរកកុមារដែលខ្លួនចង់រំលោភបំពាន។ ជារឿយៗ ពួកគេច្រើនជ្រើសរើសយកកុមារដែលងាយរងគ្រោះ។

អ្នករំលោភបំពានកសាងការទុកចិត្តពីកុមារ តាមរយៈការចែករំលែកចំណាប់អារម្មណ៍ជាមួយកុមារ ផ្តល់អំណោយផ្សេងៗដល់កុមារនិងធ្វើជាមិត្តរបស់កុមារ។

អ្នករំលោភបំពានចាប់ផ្តើមមានការសម្ងាត់ជាមួយកុមារ និងប្រើប្រាស់ការសន្យា ការគម្រាម ឬការបង្ខំ ដើម្បីឲ្យកុមាររក្សាភាពស្ងៀមស្ងាត់។

អ្នករំលោភបំពាន ពង្រីកលក្ខណៈផ្លូវភេទនៅក្នុងទំនាក់ទំនងរបស់ពួកគេ កាន់តែធំឡើងៗ។ ពួកគេលើកឡើងអំពីបញ្ហាផ្លូវភេទ និងចែករំលែកសម្ភារៈផ្លូវភេទដើម្បីឲ្យកុមារស៊ាំ។

អ្នករំលោភបំពានអនុវត្ត ( ប្រតិបត្តិ ) សកម្មភាពដែលមានលក្ខណៈរំលោភបំពានផ្លូវភេទ។

មិនមែនអ្នករំលោភបំពានទាំងអស់សុទ្ធតែប្រើប្រាស់បច្ចេកទេសល្បួងនោះឡើយ។ វិធីដទៃទៀតមានដូចជា ការវាយប្រហារភ្លាមៗ ការទិញ ការបញ្ឆោត និងកេងប្រវ័ញ្ច ការបង្ខំ។ ជារឿយៗ អ្នករំលោភបំពានមិនធ្វើសកម្មភាពតែម្នាក់ឯងនោះឡើយ។ ពួកគេអាចនឹងទទួលការជួយជ្រោមជ្រែង ឬការគាំទ្រពីមនុស្សផ្សេងទៀត ដូចជាជំនួយការ អ្នករកទិញ ភ្នាក់ងារ មេអណ្តើក និងអ្នកសម្របសម្រួល ជាដើម។

# តើសញ្ញាអ្វីខ្លះដែលបង្ហាញថាកុមារ ប្រហែលជាកំពុងប្រឈមនឹងគ្រោះថ្នាក់ ?

## ១ អាកប្បកិរិយារបស់កុមារ

ថ្វីបើសញ្ញាទាំងនេះជានិច្ចកាលពុំមែនមានន័យថាកុមារធ្លាប់បានឬកំពុងត្រូវបានគេរំលោភបំពានក្តី ប៉ុន្តែវាបញ្ជាក់ថាយើងត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀតលើស្ថានភាពនេះ៖

- អារម្មណ៍ប្រែប្រួល, ដកខ្លួនពីគេឯង តានតឹងចិត្ត ខឹងភ្លាមៗ ឬកម្រោល
- រត់ចេញពីផ្ទះ ឬបាត់ខ្លួនរយៈពេលយូរ
- មានការប្រែប្រួលចំពោះលទ្ធផលរៀនសូត្រនៅសាលា ឬគេចសាលាដោយគ្មានមូលហេតុ
- មានលុយ អំណោយ ទូរស័ព្ទដៃដោយមិនមានមូលហេតុ
- ប្រើប្រាស់បំពានសារធាតុផ្សេងៗ ( ដូចជាថ្នាំញៀន និងគ្រឿងស្រវឹង )
- អាកប្បកិរិយាក្នុងលក្ខណៈផ្លូវភេទមិនសមស្របតាមអាយុ
- កុមារដែលត្រូវបានគេចាត់ទុកថាជា "អ្នកបង្កបញ្ហា"

## ២ អាកប្បកិរិយារបស់មនុស្សដទៃទៀត

ត្រូវដឹងពីអាកប្បកិរិយារបស់មនុស្សពេញវ័យដែលនៅជុំវិញកុមារ។ អាកប្បកិរិយានេះអាចរួមមាន៖ ការយកចិត្តទុកដាក់ហួសប្រមាណ ការឲ្យអំណោយ ការស្រឡាញ់ហួសប្រមាណ ការស្នើឲ្យចំណាយពេលនៅតែម្នាក់ឯង និងការមកលេងដែលមិនមានអ្នកផ្សេងនៅជាមួយ

## ៣ សញ្ញា និងរោគសញ្ញាផ្នែករាងកាយ

សញ្ញា និងរោគសញ្ញាផ្នែករាងកាយរួមមាន ការមានផ្ទៃពោះ របួសរាងកាយ ឬឆ្លងជំងឺ (ដូចជាមេរោគ និងជំងឺឆ្លងតាមការរួមភេទ )។

## ៤ ការប្រាប់ឲ្យដឹងរបស់កុមារ

ពេលខ្លះ បើកុមារមានអារម្មណ៍មិនស្រួលក្នុងការនិយាយជាមួយឪពុកម្តាយ ឬអ្នកថែទាំ ពួកគេនឹងនិយាយប្រាប់ពីការរំលោភបំពានដល់មនុស្សពេញវ័យដែលគេជឿទុកចិត្ត។

## ៥ សញ្ញាគួរឲ្យប្រយ័ត្នក្នុងសហគមន៍

នៅពេលកុមារកំពុងរស់នៅក្នុងស្ថានភាពលំបាក ពួកគេងាយរងគ្រោះដោយការរំលោភបំពានណាស់។ សូមសម្លឹងរកមើលទៅក្នុងសហគមន៍នូវ៖ កុមារដែលដើរសុំទាន មិនទៅសាលារៀន រស់នៅនិងឬធ្វើការនៅតាមផ្លូវ គ្មានការមើលថែគ្រប់គ្រាន់របស់ឪពុកម្តាយ រស់នៅក្នុងគ្រួសារដែលមានភាពងាយរងគ្រោះ ញៀនអ៊ីនធើណេតឬហ្គេម។ សូមរកមើលផងដែរទៅលើកំណើនមនុស្សពេញវ័យ ឬកន្លែងកំសាន្តពេលយប់ ឬសេវាទេសចរណ៍ដែលពាក់ព័ន្ធជាមួយឧស្សាហកម្មផ្លូវភេទ។

# តើសហគមន៍របស់ខ្ញុំមានសុវត្ថិភាព កម្រិតណា ចំពោះកុមារ ?

## សូមធ្វើតេស្ត

**សូមគូសចម្លើយរបស់អ្នកដោយសញ្ញា ✓**

| | បាទ/ចាស | ទេ |
|---|---|---|
| ១. ខ្ញុំដឹងពីរបៀបកំណត់សញ្ញាដែលបង្ហាញថាកុមារប្រហែលជាកំពុងប្រឈមនឹងគ្រោះថ្នាក់ ឬកំពុងជួបប្រទះការរំលោភបំពានផ្លូវភេទ។ | | |
| ២. ខ្ញុំដឹងថាត្រូវឆ្លើយតបដោយរបៀបណាប្រសិនបើកុមារកំពុងប្រឈមនឹងការរំលោភបំពាន (ការរំលោភបំពានផ្លូវកាយ ចិត្ត ភេទ ឬការមិនអើពើ)។ | | |
| ៣. ខ្ញុំស្គាល់លេខទូរស័ព្ទសម្រាប់ទំនាក់ទំនងដើម្បីបញ្ជូន និងរាយការណ៍ពីករណីសង្ស័យលើការរំលោភបំពានកុមារ (ការរំលោភបំពានផ្លូវកាយ ចិត្ត ភេទ ឬការមិនអើពើ)។ | | |
| ៤. កុមារនៅក្នុងសហគមន៍របស់ខ្ញុំទទួលបានការអប់រំសមស្របដើម្បីការពារខ្លួនពួកគេពីការរំលោភបំពានផ្លូវភេទ។ | | |
| ៥. កន្លែងធ្វើការរបស់ខ្ញុំមានគោលនយោបាយការពារកុមារ ហើយបុគ្គលិកទាំងអស់សុទ្ធតែយល់ច្បាស់អំពីការអនុវត្តគោលនយោបាយនេះ។ | | |
| ៦. អង្គភាពរបស់ខ្ញុំអប់រំសាធារណៈជនអំពីរបៀបការពារកុមារពីការរំលោភបំពាន (ការរំលោភបំពានផ្លូវកាយ ចិត្ត ភេទ ឬការមិនអើពើ)។ | | |
| ៧. សហគមន៍របស់យើងមានបណ្ដាញអ្នកផ្តល់សេវាដែលធ្វើការជាមួយគ្នាក្នុងការបញ្ជូនករណីរំលោភបំពានផ្លូវភេទកុមារ និងការពារជនរងគ្រោះជាកុមារ។ | | |

**លទ្ធផល៖**

ប្រសិនបើអ្នកគូសយកចម្លើយ “បាទ/ចាស” ចំពោះគ្រប់សំណួរខាងលើ នោះមានន័យថាអ្នកតំណាងសហគមន៍កំពុងធ្វើការការពារកុមារជាជំហានៗបានយ៉ាងល្អប្រសើរ។ សូមបន្តធ្វើការងារដ៏ល្អនេះតទៅទៀត។

ប្រសិនបើអ្នកគូសយកចម្លើយ “ទេ” នូវសំណួរណាមួយ នោះសូមមើលផ្នែកខាងក្រោយនៃប័ណ្ណនេះ ដើម្បីពិនិត្យរក វិធីបង្កើតបរិយាកាសដែលការពារកុមារនៅក្នុងសហគមន៍របស់អ្នក។

# តើយើងអាចធ្វើឲ្យសហគមន៍របស់យើងមានសុវត្ថិភាពសម្រាប់កុមារបានដោយរបៀបណា ?

## ១ ការសន្ទនា និងទំនាក់ទំនងដោយបើកចំហ

- ទំនាក់ទំនងនិងពិភាក្សាដោយផ្ទាល់ រវាងកុមារ និងឪពុកម្ដាយរបស់ពួកគេ។
- ការសន្ទនាដោយបើកចំហស្ដីពីការការពារកុមារ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ នៅសាលារៀន នៅតាមស្ថាប័ន និងនៅក្នុងសហគមន៍។

## ២ ការទប់ស្កាត់

- ត្រួតពិនិត្យសាវតា វាយតម្លៃអ្នកស្ម័គ្រចិត្ត ឬអ្នកធ្វើការជាមួយកុមារ។
- យកចិត្តទុកដាក់ខ្ពស់ចំពោះករណីដែលបានរាយការណ៍ និងស៊ើបអង្កេតករណីសង្ស័យ។
- កំហិតលទ្ធភាពរបស់មនុស្សប្លែកមុខ ក្នុងការចូលទៅរកកុមារ និងចូលទៅកាន់កន្លែងដែលកុមារអាចនៅតែម្នាក់ឯងជាមួយមនុស្សធំ។
- បង្ហាញពីការមិនអនុគ្រោះចំពោះការរំលោភបំពានផ្លូវភេទកុមារនៅក្នុងសហគមន៍។
- កម្មវិធីអន្តរាគមន៍ទាន់ពេលវេលា ដើម្បីគាំទ្រដល់គ្រួសារងាយរងគ្រោះ។

## ៣ ការការពារ

- សូមប្រយ័ត្ន! សូមរកមើលសញ្ញាគួរឲ្យប្រយ័ត្នក្នុងសហគមន៍ដែលបង្ហាញថាកុមារអាចកំពុងប្រឈមនឹងគ្រោះថ្នាក់។
- ចាត់វិធានការភ្លាមៗប្រសិនបើអ្នកទទួលបានព័ត៌មានថាកុមារណាម្នាក់កំពុងប្រឈមជាមួយនឹងគ្រោះថ្នាក់ឬជាជនរងគ្រោះដោយការរំលោភបំពាន។
- ផ្ដល់ការការពារដល់កុមារដែលជួបបញ្ហាផ្ទាល់។
- បញ្ជូនករណីទៅបុគ្គលឬទីភ្នាក់ងារដែលបានចាត់តាំង។
- គោរពតាមនីតិវិធីនៅក្នុងសហគមន៍ដែលបានព្រមព្រៀងគ្នារួចហើយ។

# តើអ្នកតំណាងសហគមន៍ណាមួយដែលអាចជួយបាន ?

ក្នុងនាមជាគ្រូបង្រៀន គិលានុបដ្ឋាក វេជ្ជបណ្ឌិត អ្នកដឹកនាំសាសនា មន្ត្រី នគរបាល បុគ្គលិក សង្គមកិច្ច មេភូមិ មន្ត្រីសហគមន៍ អ្នកបម្រើការផ្នែកយុវជន ឬអ្នកជំនាញដែល ធ្វើការជាមួយកុមារ អ្នកអាចជួយរក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទនៅក្នុង សហគមន៍របស់អ្នកបាន។




កិច្ចសហប្រតិបត្តិការគឺជាគន្លឹះនៃភាពជោគជ័យក្នុងការការពារកុមារ។ ត្រូវប្រាកដថាអ្នកដឹងថានរណា ស្ថិតនៅក្នុងបណ្តាញការពារកុមារក្នុងតំបន់របស់អ្នក ដើម្បីឲ្យអ្នកអាចចាត់វិធានការភ្លាមៗ និងបាន សមស្រប នៅពេលដែលកុមារកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការរំលោភបំពានផ្លូវភេទ។



# តើមាននរណាខ្លះទៀតអាចជួយបាន ?

តើអ្នកត្រូវការព័ត៌មានបន្ថែមទៀត ឬទេ ? ឬ តើអ្នកដឹងអំពីស្ថានភាពដែលកុមារប្រហែលជាកំពុងប្រឈមនឹង គ្រោះថ្នាក់ពីការរំលោភបំពាន ឬទេ ?

ទូរសព្ទ័ទៅបណ្តាញទូរសព្ទ័ទាន់ហេតុការណ៍ការពារកុមារថ្នាក់ជាតិ

**១២៨៨**

ទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋាន

..........................................................................

ទំនាក់ទំនងទីភ្នាក់ងារការពារកុមារ ដែលមានកេរ្តិ៍ឈ្មោះល្អ:

**០៩២ ៣១១ ៥១១**

**w:** childsafetourism.org **and** wvi.org/asiapacific/childsafetourism

**f:** facebook.com/ChildSafeTourism **t:** twitter.com/childsafetravel

**Child Safe Tourism**

Take action against abuse

# ឧបសម្ព័ន្ធទី២៖ ទម្រង់វត្តមានសម្រាប់អ្នកចូលរួម

គំរូទម្រង់នេះ អាចប្រើប្រាស់សម្រាប់កត់ត្រាព័ត៌មានលម្អិត និងព័ត៌មានសំខាន់ៗអំពីអ្នកចូលរួម។

ទីតាំងរៀបចំវេទិពិភាក្សា ៖ ____________________

កាលបរិច្ឆេទ និងម៉ោងធ្វើវេទិកាពិភាក្សា ៖ ____________________

| គោត្តនាម និងនាម | ភេទ | មុខងារ/តួនាទី | លេខទូរស័ព្ទ | អ៊ីមែល (បើមាន) | ហត្ថលេខា |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

# ឧបសម្ព័ន្ធទី ៣ ៖ សំណួរមុនចូលមេរៀន

គួរថតចម្លងទម្រង់សំណួរនេះ ចែកជូនដល់អ្នកចូលរួមម្នាក់ៗ នៅពេលចាប់ផ្តើមវេទិកាពិភាក្សា។ អ្នកសម្របសម្រួលគួរតែប្រមូលទម្រង់ដែលបានបំពេញរួចទុកវិញ សម្រាប់ធ្វើការវិភាគ ( ដោយប្រើគំរូនៅក្នុងឧបសម្ព័ន្ធទី៦ ) បន្ទាប់ពីចប់ម៉ោងរៀន។ ក្រៅពីនេះ អាចប្រើសំណួរចូលទៅកាន់មេរៀន ជាទម្រង់ប្រាស្រ័យទាក់ទងគ្នាក៏បាន ដោយប្រើប្រាស់គំនិតនានា ដែលមានស្រាប់នៅក្នុងការណែនាំតាមរយៈស្លាយ។

| | សូមអានសំណួរនីមួយៗ ហើយត្រូវជ្រើសរើសចម្លើយ | បាទ/ចាស | ទេ | មិនដឹង |
|---|---|---|---|---|
| ១. | តើអ្នកយល់ថា "ការរំលោភបំពានផ្លូវភេទកុមារ" ជាអ្វីដែរឬទេ ? | | | |
| ២. | តើការរំលោភបំពានផ្លូវភេទកុមារ កើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ ? | | | |
| ៣. | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ? | | | |
| ៤. | ជាធម្មតា តើការរំលោភបំពានផ្លូវភេទកុមារ កើតឡើងដោយសារមនុស្សប្លែកមុខដែលគេមិនធ្លាប់ស្គាល់ឬ ? | | | |
| ៥. | តើកុមារមានការលំបាក ក្នុងការប្រាប់មនុស្សពេញវ័យឲ្យបានដឹងអំពីការរំលោភបំពានឬទេ ? | | | |
| ៦. | តើអ្នកស្គាល់ពីសញ្ញាសម្គាល់ដែលបង្ហាញថា កុមារអាចនឹងស្ថិតក្នុងគ្រោះថ្នាក់នៅក្នុងការរំលោភបំពានឬទេ ? | | | |
| ៧. | តើអ្នកដឹងថា អ្នកត្រូវអនុវត្តសកម្មភាពអ្វីខ្លះ ប្រសិនបើអ្នកទទួលដំណឹងថា មានកុមារស្ថិតក្នុងគ្រោះថ្នាក់ ឬត្រូវគេរំលោភបំពាន ? | | | |
| ៨. | តើអ្នកស្គាល់មនុស្ស/ ភ្នាក់ងារណាមួយដែលមានសមត្ថកិច្ច ដើម្បីរាយការពីករណីសង្ស័យនានា អំពីការរំលោភបំពានផ្លូវភេទកុមារ។ បើស្គាល់ ចូរសរសេរឈ្មោះ និង/ឬលេខទូរស័ព្ទនៅទីនេះ<br>..............................................................................................<br>.............................................................................................. | | | |
| ៩. | ក្នុងនាមជាអ្នកតំណាងសហគមន៍ម្នាក់ តើអ្នកដឹងឬទេថា អ្នកត្រូវមានការទទួលខុសត្រូវអ្វីខ្លះចំពោះការរក្សាសុវត្ថិភាពកុមារ ពីការរំលោភបំពានផ្លូវភេទឬទេ ? | | | |

# ឧបសម្ព័ន្ធទី៤៖ សំណួរក្រោយមេរៀន

គួរថតចម្លងទម្រង់សំណួរនេះ ចែកជូនដល់អ្នកចូលរួមម្នាក់ៗ នៅពេលចុងបញ្ចប់ម៉ោងរៀន។ អ្នកសម្របសម្រួលគួរតែប្រមូលទម្រង់ដែលបានបំពេញរួចទុកវិញ សម្រាប់ធ្វើការវិភាគ ( ដោយប្រើគំរូនៅក្នុងឧបសម្ព័ន្ធទី៦ ) បន្ទាប់ពីចប់ម៉ោងរៀន។ ក្រៅពីនេះ អាចប្រើសំណួរមុនចូលមេរៀន ជាទម្រង់ប្រាស្រ័យទាក់ទងគ្នាក៏បាន ដោយប្រើប្រាស់គំនិតនានាដែលមានស្រាប់ នៅក្នុងការណែនាំតាមរយៈស្លាយ។

| សូមអានសំណួរនីមួយៗ ហើយត្រូវជ្រើសរើសចម្លើយ | | បាទ/ចាស | ទេ | មិនដឹង |
|---|---|---|---|---|
| ១. | តើអ្នកយល់ថា "ការរំលោភបំពានផ្លូវភេទកុមារ" ជាអ្វីដែរឬទេ ? | | | |
| ២. | តើការរំលោភបំពានផ្លូវភេទកុមារ កើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ ? | | | |
| ៣. | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ? | | | |
| ៤. | ជាធម្មតា តើការរំលោភបំពានផ្លូវភេទកុមារ កើតឡើងដោយសារមនុស្សប្លែកមុខដែលគេមិនធ្លាប់ស្គាល់ឬ ? | | | |
| ៥. | តើកុមារមានការលំបាក ក្នុងការប្រាប់មនុស្សពេញវ័យឲ្យបានដឹងអំពីការរំលោភបំពានឬទេ ? | | | |
| ៦. | តើអ្នកស្គាល់ពីសញ្ញាសម្គាល់ដែលបង្ហាញថា កុមារអាចនឹងស្ថិតក្នុងគ្រោះថ្នាក់នៅក្នុងការរំលោភបំពានឬទេ ? | | | |
| ៧. | តើអ្នកដឹងថា អ្នកត្រូវអនុវត្តសកម្មភាពអ្វីខ្លះ ប្រសិនបើអ្នកទទួលដំណឹងថា មានកុមារស្ថិតក្នុងគ្រោះថ្នាក់ ឬត្រូវគេរំលោភបំពាន ? | | | |
| ៨. | តើអ្នកស្គាល់មនុស្ស/ ភ្នាក់ងារណាមួយដែលមានសមត្ថកិច្ច ដើម្បីរាយការពីករណីសង្ស័យនានា អំពីការរំលោភបំពានផ្លូវភេទកុមារ។ បើស្គាល់ ចូរសរសេរឈ្មោះ និង/ឬលេខទូរស័ព្ទនៅទីនេះ<br>..........................................................................................<br>.......................................................................................... | | | |
| ៩. | ក្នុងនាមជាអ្នកតំណាងសហគមន៍ម្នាក់ តើអ្នកដឹងឬទេថា អ្នកត្រូវមានការទទួលខុសត្រូវអ្វីខ្លះចំពោះការរក្សាសុវត្ថិភាពកុមារ ពីការរំលោភបំពានផ្លូវភេទឬទេ ? | | | |

# ឧបសម្ព័ន្ធទី៥៖ ប័ណ្ណឆ្លើយតបមុនចូលមេរៀន និងក្រោយមេរៀន



អាចប្រើប្រាស់ប័ណ្ណនេះ សម្រាប់សួរសំណួរចូលទៅកាន់មេរៀន និងក្រោយមេរៀនសារឡើងវិញ ក្នុងលក្ខណៈជាលំហាត់ដែលមានការប្រាស្រ័យទាក់ទងគ្នា។ អ្នកចូលរួម គួរទទួលបានប័ណ្ណម្នាក់មួយឈុត (ប័ណ្ណដែលមានសញ្ញាធីក (✓) មួយ សញ្ញាខ្វែង (x) មួយ និងសញ្ញាសួរ ( ? ) មួយ)។ អ្នកសម្របសម្រួល អាចសួរសំណួរនៅក្នុងឧបសម្ព័ន្ធទី៣ ហើយអ្នកចូលរួមអាចបង្ហាញចម្លើយតបរបស់ខ្លួន (បាទ/ចាស ទេ ឬមិនដឹង)។ ចំនួន និងប្រភេទចម្លើយតប គួរតែបានកត់ត្រានៅក្នុងទម្រង់គំរូ ដែលមានស្រាប់នៅក្នុង ឧបសម្ព័ន្ធទី ៦។



# ឧបសម្ព័ន្ធទី៦៖ ទម្រង់គំរូវិភាគសំណួរមុនចូលមេរៀន និងក្រោយមេរៀន

សំណួរចូលទៅកាន់/រំឭកមេរៀន អាចត្រូវបានសួរជាទម្រង់សំណេរ ឬជាការនិយាយ។ ទម្រង់គំរូនេះអាចឲ្យអ្នកសម្របសម្រួលប្រើប្រាស់ដើម្បីកត់ត្រាចម្លើយតបដែលបាននិយាយ ឬអាចប្រើនៅក្រោយចប់ម៉ោងរៀន ដើម្បីសរុប និងវិភាគលើចម្លើយតបជាសំណេរ។ សេចក្ដីសង្ខេបអាចត្រូវបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធទី៩៖ ទម្រង់គំរូរបាយការណ៍ក្រោយការបណ្ដុះបណ្ដាល។

| **សូមអានសំណួរនីមួយៗខាងក្រោម ហើយជ្រើសរើស ចម្លើយ** | | *សូមបញ្ចូលចំនួនអ្នកឆ្លើយតបចំពោះសំណួរនីមួយៗដូចខាងក្រោម ៖* | | | | | |
|---|---|---|---|---|---|---|---|
| | | សំណួរមុនចូលមេរៀន ខាងដើមការពិភាក្សា | | | សំណួរក្រោយមេរៀន ចុងបញ្ចប់ការពិភាក្សា | | |
| | | ✔ | X | ? | ✔ | X | ? |
| ១. | តើអ្នកយល់ថា "ការរំលោភបំពានផ្លូវភេទកុមារ" ជាអ្វីដែរឬទេ ? | | | | | | |
| ២. | តើការរំលោភបំពានផ្លូវភេទកុមារ កើតមាននៅក្នុងសហគមន៍របស់អ្នកដែរឬទេ ? | | | | | | |
| ៣. | តើមានតែកុមារីទេឬ ដែលងាយរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ? | | | | | | |
| ៤. | ជាធម្មតា តើការរំលោភបំពានផ្លូវភេទកុមារកើតឡើងដោយសារមនុស្សប្លែកមុខដែលគេមិនធ្លាប់ស្គាល់ឬ ? | | | | | | |
| ៥. | តើកុមារមានការលំបាក ក្នុងការប្រាប់មនុស្សពេញវ័យឲ្យបានដឹងអំពីការរំលោភបំពានឬទេ ? | | | | | | |
| ៦. | តើអ្នកស្គាល់ពីសញ្ញាសម្គាល់ដែលបង្ហាញថាកុមារអាចនឹងស្ថិតក្នុងគ្រោះថ្នាក់នៅក្នុងការរំលោភបំពានឬទេ ? | | | | | | |
| ៧. | តើអ្នកដឹងថា អ្នកត្រូវអនុវត្តសកម្មភាពអ្វីខ្លះ ប្រសិនបើអ្នកទទួល ដំណឹងថាមានកុមារស្ថិតក្នុងគ្រោះថ្នាក់ ឬត្រូវគេរំលោភបំពាន ? | | | | | | |
| ៨. | តើអ្នកស្គាល់មនុស្ស/ ភ្នាក់ងារណាមួយដែលមានសមត្ថកិច្ច ដើម្បី រាយការពីករណីសង្ស័យនានាអំពីការរំលោភបំពានផ្លូវភេទកុមារ។ បើស្គាល់ ចូរសរសេរឈ្មោះ និង/ឬលេខទូរស័ព្ទនៅទីនេះ ..................................................................... | | | | | | |
| ៩. | ក្នុងនាមជាអ្នកតំណាងសហគមន៍ម្នាក់ តើអ្នកដឹងឬទេថា អ្នកត្រូវមានការទទួលខុសត្រូវអ្វីខ្លះចំពោះការរក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទទេ ? | | | | | | |

# ឧបសម្ព័ន្ធទី៧៖ សេណារីយ៉ូករណីសិក្សាសំរាប់អ្នកតំណាងសហគមន៍

អ្នកសម្របសម្រួលគួរតែពិនិត្យទៅលើសេណារីយ៉ូ និងធ្វើការកែសម្រួលទៅតាមករណីដែលចាំបាច់ ដើម្បីឆ្លើយតបទៅនឹងបទដ្ឋានវប្បធម៌ និងបញ្ហានានា ដែលប្រឈមមុខនឹងសហគមន៍។ គួរតែថតចម្លងឯកសារសេណារីយ៉ូនេះឲ្យបានមុនវេទិកាពិភាក្សាចាប់ផ្ដើម។ សូមបែងចែកអ្នកចូលរួមជាក្រុមតូចៗ និងដាក់ឲ្យមានអ្នកតំណាងវិស័យផ្សេងៗនៅក្នុងក្រុមនីមួយៗ ( ឧទាហរណ៍ដូចជា វិស័យអប់រំ សុខភាព សង្គមកិច្ច និងការអនុវត្តច្បាប់ )។ សូមចែកជូនឯកសារសេណារីយ៉ូចំនួនមួយច្បាប់ដល់ក្រុមនីមួយៗ។សូមឲ្យក្រុមនីមួយៗពិភាក្សាទៅលើករណីសិក្សា និងរៀបចំឆ្លើយសំណួរដែលមានស្រាប់នៅក្នុងឯកសារចែកជូន។ បើមានពេលអ្នកសម្របសម្រួលអាចផ្ដល់ករណីសិក្សាមួយច្បាប់ទៀត ដល់ក្រុមនីមួយៗ។

## សេណារីយ៉ូទី ១

ថ្មីៗនេះ គេបានដឹងថា មានកុមារអាយុ១២ឆ្នាំម្នាក់នៅក្នុងសហគមន៍របស់អ្នក ជាជនរងគ្រោះនៅក្នុងការរំលោភបំពានផ្លូវភេទ។ តាមពិត កុមារម្នាក់នោះ បានរងគ្រោះអស់រយៈកាលប្រាំឆ្នាំមកហើយ ពីសំណាក់បុគ្គលិកសុខភាពម្នាក់នៅមូលដ្ឋាននោះ។ នៅក្នុងបណ្ដឹងតុលាការ មានអ្នកតំណាងសហគមន៍មួយចំនួន (រួមមានគ្រូបង្រៀន បុគ្គលិកពេទ្យ និងបុគ្គលិកផ្នែកសង្គមកិច្ច ) បាននិយាយថា ពេលខ្លះពួកគាត់ក៏មានការសង្ស័យខ្លះដែរ ប៉ុន្តែពួកគាត់មិនដឹងច្បាស់ថាតើត្រូវធ្វើដូចម្ដេច ឬមិនចង់ជ្រៀតជ្រែករឿងអ្នកដទៃ។

១. ក្នុងនាមអ្នកជាអ្នកតំណាងសហគមន៍ តើអ្នកត្រូវធ្វើដូចម្ដេច ប្រសិនបើអ្នកសង្ស័យថា មានកុមារម្នាក់កំពុងរងការរំលោភបំពានផ្លូវភេទ ?

២. ក្នុងនាមអ្នកជាអ្នកតំណាងសហគមន៍ តើអ្នកត្រូវធ្វើដូចម្ដេច ដើម្បីសហការគ្នាឲ្យបានល្អ ក្នុងការឆ្លើយតបទៅនឹងករណីសង្ស័យនានា នៅក្នុងការរំលោភបំពានផ្លូវភេទ ?

## សេណារីយ៉ូទី ២

អ្នកគឺជានាយកសាលាម្នាក់ ហើយគ្រូៗនិងឪពុកម្ដាយកុមារ បានមកប្ដឹងដល់អ្នក អំពីទង្វើរបស់ក្មេងប្រុសម្នាក់អាយុ១៥ឆ្នាំ។ គ្រូៗ និយាយថា កុមារាម្នាក់នោះ តែងចេញពីសាលារៀនជាញឹកញាប់ ហើយនៅពេលគាត់មកដល់សាលា គាត់ឡូឡា រំខាន និងមិនស្ដាប់បង្គាប់ឡើយ។ ឪពុកម្ដាយមិត្តរួមថ្នាក់របស់កុមារានោះបានប្ដឹងថា កុមារារូបនោះ ជះឥទ្ធិពលមិនល្អទៅលើកូនៗរបស់ពួកគាត់។ យ៉ាងហោចណាស់ ក៏មានគ្រូម្នាក់ដែរ ដែលបានស្ដីបន្ទោសទៅលើកុមារារូបនោះ លើករណីបាត់សម្ភារពីក្នុងថ្នាក់រៀន។ គ្រូដឹកនាំនៅក្នុងសាលាបានរាយការមកអ្នកថា កុមារានោះបានប្រាប់ឲ្យដឹងថា មានលោកគ្រូម្នាក់នៅសាលារៀននោះ បានបង្ហាញរូបភាពអាសអាភាសនៅក្នុងទូរស័ព្ទដៃរបស់គាត់ដល់ខ្លួន ហើយបានព្យាយាមប៉ះពាល់លើខ្លួន។ បើមើលទៅតាមកេរ្តិ៍ឈ្មោះរបស់កុមារានោះ អ្នកមិនទុកចិត្តទេថា កុមារានោះកំពុងនិយាយការពិត។

១. នៅពេលនេះ តើអ្នកគួរមានវិធានការដូចម្ដេចខ្លះ ?

២. តើអ្នកអាចមានវិធីណាខ្លះដែលល្អប្រសើរសម្រាប់សាលារបស់អ្នក ដើម្បីឆ្លើយតបទៅនឹងករណីសង្ស័យលើការរំលោភបំពានផ្លូវភេទលើកុមារ ?

✄

## សេណារីយ៉ូទី ៣

អ្នកបានបើកមជ្ឈមណ្ឌលកំសាន្តមួយសម្រាប់កុមារនៅក្នុងមូលដ្ឋាន និងក្មេងជំទង់ ដែលកំពុងរស់នៅ និងធ្វើការនៅតាមចិញ្ចើមថ្នល់។ ជាច្រើនឆ្នាំកន្លងទៅនេះ អ្នកទទួលបានបុគ្គលិកស្ម័គ្រចិត្តមួយចំនួន ដែលជួយកិច្ចការនៅក្នុងមជ្ឈមណ្ឌលនោះ និងចំណាយពេលជួយដល់កុមារ។ បុគ្គលិកស្ម័គ្រចិត្តទាំងនោះ ក៏បានឧបត្ថម្ភប្រាក់ជួយដល់មជ្ឈមណ្ឌលនៅដែរ ហើយប្រាក់នេះ មានសារៈសំខាន់ណាស់ សម្រាប់ជួយឲ្យមជ្ឈមណ្ឌលនោះនៅដំណើរការ។ មានបុគ្គលិកស្ម័គ្រចិត្តថ្មីម្នាក់ មានភាពរួសរាយជាពិសេសដាក់ក្មេងស្រីដែលមកលេងមជ្ឈមណ្ឌលនោះ ហើយអ្នកបានដឹងថា នាងកំពុងនៅជាមួយបុរសជាបុគ្គលិកស្ម័គ្រចិត្តរូបនោះ នៅក្នុងផ្ទះសំណាក់របស់គាត់។

១. នៅពេលនេះ តើអ្នកគួរមានវិធានការដូចម្ដេចខ្លះ ?

២. តើអ្នកអាចមានវិធីណា ដែលល្អប្រសើរសម្រាប់មជ្ឈមណ្ឌលរបស់អ្នកឬទេ  ដើម្បីធ្វើយ៉ាងណាមិនឲ្យកុមារមានទំនាក់ទំនងជាមួយ មនុស្សពេញវ័យ "ដែលគេមិនដឹងប្រវត្តិច្បាស់" (ដូចជាមនុស្សពេញវ័យដែលគេមិនបានពិនិត្យមើលថា តើប្រវត្តិការងារ និងបទល្មើសនានាដែលអាចមាននោះ សមស្របនឹងអាចធ្វើការជាមួយកុមារបានឬអត់) ?

៣. តើវិធីទាំងនេះ គួរប្រើចំពោះអ្នកណាខ្លះ ?

✄

## សេណារីយ៉ូទី ៤

នៅពេលវិស័យទេសចរណ៍នៅក្នុងសហគមន៍របស់អ្នកមានការរីកចម្រើន អ្នកចាប់អារម្មណ៍ថា កុមារបង្ហាញខ្លួនកាន់តែច្រើនឡើងនៅទីសាធារណៈ។ កុមារមិនបានទៅសាលារៀនឡើយ ហើយបែរជាមកធ្វើជាអ្នកលក់ដូរ (របស់របរអនុស្សាវរីយ៍ និងអាហារសម្រន់ ទៅឲ្យភ្ញៀវទេសចរ) ទៅវិញ និងធ្វើជាអ្នកសុំទានពីភ្ញៀវទេសចរបរទេស និងក្នុងស្រុក។

១. ចូរពន្យល់ពីគ្រោះថ្នាក់ដែលកុមារជួបប្រទះនៅក្នុងស្ថានភាពនេះ។

២. ក្នុងនាមជាអ្នកតំណាងសហគមន៍ តើអ្នកអាចធ្វើដូចម្ដេច ចំពោះបញ្ហានេះ ?

## សេណារីយ៉ូទី ៥

អ្នកមិនបានដឹងអំពីករណីជាច្រើនទាក់ទងទៅនឹងការរំលោភបំពានផ្លូវភេទកុមារ នៅក្នុងសហគមន៍របស់អ្នក។ ប៉ុន្តែ អ្នកបានឮថា បញ្ហានេះកំពុងកើនឡើងទូទាំងពិភពលោក ហើយតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អ្នកដឹងថា ករណីនានាត្រូវបានរកឃើញនៅក្នុងសហគមន៍នានាដែលនៅជិតអ្នក។ អ្នកចង់បង្កើតបរិយាកាសមួយ ប្រកបដោយសុវត្ថិភាព និងមានការពារចំពោះកុមារនៅក្នុងសហគមន៍របស់អ្នក ដើម្បីទប់ស្កាត់មិនឲ្យការបំពានផ្លូវភេទកុមារកើតមានឡើង។

១. នៅក្នុងវិស័យរបស់អ្នក (អប់រំ សុខភាព សង្គមកិច្ច ការអនុវត្តច្បាប់) សូមពិភាក្សាអំពីដំណោះស្រាយនានាដែលអ្នកអាចធ្វើបាន ដើម្បីការពារ និង/ឬស្គាល់ច្បាស់នូវការរំលោភបំពានផ្លូវភេទកុមារ។

២. ឥឡូវ សូមពិភាក្សាទៅលើវិធី ដែលអ្នកអាចសហការ ជាមួយក្រុមនានានៅក្នុងសហគមន៍ផ្សេងទៀតបាន ដើម្បីលើកកម្ពស់បរិយាកាសការពារកុមារ។

## សេណារីយ៉ូទី ៦

វិស័យទេសចរណ៍ កំពុងមានការរីកចម្រើននៅក្នុងសហគមន៍របស់អ្នក។ នៅពេលមានភ្ញៀវទេសចរមកកំសាន្តកាន់តែច្រើន អ្នកឃើញថា ស្ថានភាពសេដ្ឋកិច្ចក៏កំពុងកើនឡើងដែរ។ ប៉ុន្តែ ថ្មីៗនេះ អ្នកបានចាប់អារម្មណ៍ឃើញថា អ្នកដំណើរប្រុសៗដែលជាជនបរទេស កំពុងធ្វើជាមិត្តជាមួយស្ត្រីក្មេងៗនៅក្នុងមូលដ្ឋាន។ នៅពេលនេះ មានស្រីក្មេងៗខ្លះកំពុងរស់នៅជាមួយបុរសបរទេសទៅហើយ។ អ្នកក៏បានឮគេខ្សឹបប្រាប់ថា មិត្តស្រីទាំងនោះ កំពុងនាំក្មេងៗពីសហគមន៍របស់អ្នកទៅស្នាក់នៅឯផ្ទះរបស់ពួកគេទៀតផង។

១. តើសហគមន៍គួរធ្វើដូចម្តេច ដើម្បីរក្សាសុវត្ថិភាពដល់កុមារ មិនឲ្យរងការរំលោភបំពានផ្លូវភេទពីសំណាក់អ្នកដំណើរប្រុសៗ ដែលជាជនបរទេសទាំងនោះ?

២. តើអ្នកមានតួនាទីអ្វីខ្លះ ដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពាន ពីសំណាក់ជនបរទេស?

## សេណារីយ៉ូទី ៧

នៅក្នុងសហគមន៍របស់អ្នក មានម្តាយនៅលីវម្នាក់ បានសំដែងនូវការដឹងគុណចំពោះការឧបត្ថម្ភប្រាក់កាសដែលខ្លួនបានទទួលពីប្តីប្រពន្ធជាជនបរទេសមួយគូ អស់រយៈកាលពីរបីឆ្នាំកន្លងទៅនេះ ហេតុនេះ ម្តាយរូបនោះអាចសង់ផ្ទះ ផ្តល់ចំណីអាហារ និងអប់រំកូនរបស់នាងបាន។ ម្តាយរូបនោះ បានជូនយោបល់ដល់អ្នកថា នៅពេលនេះ ប្តីប្រពន្ធពីរនាក់នោះ ជួយនាំកូនច្បងរបស់នាងទៅរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រាមួយដែលខ្លួនបានបង្កើតឡើងនៅក្នុងទីក្រុងធំ ដើម្បីឲ្យកូនប្រុសម្នាក់នោះ ទទួលបានការអប់រំកាន់តែល្អ និងមានឱកាសកាន់តែប្រសើរ។

១. ចូរពន្យល់ពីគ្រោះថ្នាក់ ដែលកុមាររូបនោះជួបប្រទះ នៅក្នុងស្ថានភាពនេះ។

២. ក្នុងនាមជាអ្នកតំណាងសហគមន៍ តើអ្នកអាចជួយដូចម្តេចខ្លះ ដល់ឪពុកម្តាយ និងអ្នកថែទាំ ដើម្បីឲ្យពួកគាត់យល់ថា ស្ទើរគ្រប់កាលៈទេសៈ កុមារតែងទទួលបានការថែទាំយ៉ាងល្អបំផុតពីគ្រួសាររបស់ខ្លួន?

# ឧបសម្ព័ន្ធទី៨៖ ទម្រង់ទស្សនៈរបស់ខ្ញុំ

ត្រូវរៀបចំទម្រង់នេះ សម្រាប់អ្នកចូលរួមម្នាក់ៗ។ ត្រូវចែកជូនទម្រង់ទាំងនេះដល់អ្នកចូលរួម នៅក្នុងម៉ោងសរុបមេរៀន។ ក្រៅពីនេះ អ្នកសម្របសម្រួលអាចកំណត់កម្រិតចម្លើយរបស់អ្នកចូលរួមដោយការនិយាយតាមរយៈការសួរសំណួរងាយៗមួយចំនួនដូចជា តើម៉ោងសិក្សានេះមានប្រយោជន៍ឬទេ? តើថ្ងៃនេះអ្នកបានដឹងព័ត៌មានដែលមានប្រយោជន៍អ្វីខ្លះ? តើមានអ្វីដែលយើងគួរផ្លាស់ប្តូរសម្រាប់ម៉ោងសិក្សាក្រោយៗឬទេ?

## ទស្សនៈរបស់ខ្ញុំ

យើងឲ្យតម្លៃលើទស្សនៈរបស់អ្នក! ត្រូវផ្តល់ព័ត៌មានត្រឡប់វិញដោយស្មោះត្រង់របស់អ្នក ដើម្បីជួយដល់យើងក្នុងការលើកកម្ពស់កិច្ចការពារកុមាររបស់យើង។

**១. តើអ្នកធ្វើការនៅក្នុងវិស័យអ្វី?**

- ○ រដ្ឋាភិបាល
- ○ អាជីវកម្ម
- ○ សហគមន៍
- ○ បើផ្សេងពីនេះ សូមបញ្ជាក់

**២. តើភេទរបស់អ្នកជាអ្វី?**

- ○ ស្រី
- ○ ប្រុស
- ○ ផ្សេងពីនេះ

**៣. សូមដាក់កម្រិតវាយតម្លៃដូចខាងក្រោម ៖**

| | | | |
|---|---|---|---|
| អ្នកសម្របសម្រួលពន្យល់ច្បាស់លាស់ ហើយមេរៀនមានភាពងាយស្រួលអនុវត្ត។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |
| សម្ភារទាំងឡាយសុទ្ធតែមានប្រយោជន៍។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |
| ការពិភាក្សា ជួយលើកកម្ពស់ការយល់ដឹងរបស់ខ្ញុំពីបញ្ហានេះ។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |
| ការពិភាក្សាបានលើកទឹកចិត្តខ្ញុំឲ្យបង្កើនសកម្មភាពការពារកុមារ។ | ○ យល់ស្រប | ○ អព្យាក្រឹត | ○ មិនយល់ស្រប |

៤. តើមានចំណុចណាខ្លះនៅក្នុងវេទិកាពិភាក្សានេះ ដែលនឹងមានប្រយោជន៍សម្រាប់អ្នកនៅក្នុងការងារ/ជីវិត ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៥. តើយើងគួរធ្វើដូចម្តេច ដើម្បីធ្វើឲ្យវេទិកាពិភាក្សានេះ មានលក្ខណៈកាន់តែប្រសើរឡើង ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៦. សូមសរសេរចំណុចមួយ ដែលអ្នកនឹងផ្លាស់ប្តូរនូវទង្វើរបស់ខ្លួន បន្ទាប់ពីទទួលបានព័ត៌មាន និងធនធាននៅក្នុងវេទិកាពិភាក្សានេះ។

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

៧. តើអ្នកមានយោបល់អ្វីផ្សេងទៀតឬទេ ?

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

# ឧបសម្ព័ន្ធទី៩៖ ទម្រង់គំរូរបាយការណ៍ក្រោយការបណ្តុះបណ្តាល

គួរប្រើប្រាស់ទម្រង់គំរូនេះក្នុងការពង្រឹងឧបករណ៍ងាយៗសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ នៅក្នុងវេទិកាពិភាក្សានេះ។ អ្នកសម្របសម្រួលគួរតែជាអ្នកត្រូវបំពេញទម្រង់គំរូ និងចែកជូនទៅឲ្យអ្នកគ្រប់គ្រង/អង្គការនានា ដែលពាក់ព័ន្ធ ដើម្បីអាចប្រើប្រាស់លទ្ធផលតាមដានការសិក្សានេះ និងដើម្បីលើកកម្ពស់សកម្មភាពនានាក្នុងពេលអនាគត។

## ក. សំណួរមុនចូលមេរៀន និងក្រោយមេរៀន

*ត្រូវបញ្ចូលខ្លឹមសារសង្ខេបនៃ **ឧបសម្ព័ន្ធទី៦** ៖ ការវិភាគសំណួរមុនចូលមេរៀន និងរំឭកមេរៀនឡើងវិញ*

## ខ. ទស្សនៈរបស់ខ្ញុំ

*ចូរត្រួតពិនិត្យមើល ទម្រង់ស្តីពី "ទស្សនៈរបស់ខ្ញុំ" ដែលបានទទួល ដើម្បីធ្វើការសង្ខេបដូចតទៅ ៖*

### ១. តារាងលម្អិតតាមវិស័យ និង ភេទ

| វិស័យ | ចំនួនសរុប | ស្ត្រីសរុប | បុរសសរុប | ផ្សេងៗ សរុប |
|---|---|---|---|---|
| រដ្ឋាភិបាល | | | | |
| អាជីវកម្ម | | | | |
| សហគមន៍ | | | | |
| ផ្សេងពីនេះ | | | | |

### ២. កម្រិតវាយតម្លៃ

| | យល់ស្រប<br>លេខ និង % | | អព្យាក្រឹត<br>លេខ និង % | | មិនយល់ស្រប<br>លេខ និង % | |
|---|---|---|---|---|---|---|
| អ្នកសម្របសម្រួលពន្យល់ច្បាស់លាស់ ហើយមេរៀនមានភាពងាយស្រួលអនុវត្ត។ | | | | | | |
| សម្ភារៈទាំងឡាយសុទ្ធតែមានប្រយោជន៍។ | | | | | | |
| ការពិភាក្សា ជួយលើកកម្ពស់ការយល់ដឹងរបស់ខ្ញុំពីបញ្ហានេះ។ | | | | | | |
| ការពិភាក្សាបានលើកទឹកចិត្តខ្ញុំ ឲ្យបង្កើនសកម្មភាពការពារកុមារ។ | | | | | | |

៣. សូមរៀបរាប់ជាចំណុចៗ នៃការដកស្រង់សម្ដីដែលបានឆ្លើយសំណួរ "តើមានចំណុចណាខ្លះនៅក្នុងវេទិកាពិភាក្សានេះ ដែលនឹងមានប្រយោជន៍សម្រាប់អ្នកនៅក្នុងការងារ/ជីវិត ?"

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៤. សូមរៀបរាប់ជាចំណុចៗ នៃការដកស្រង់សម្ដីដែលបានឆ្លើយសំណួរ "តើយើងគួរធ្វើដូចម្ដេច ដើម្បីធ្វើឲ្យវេទិកាពិភាក្សានេះ មានលក្ខណៈកាន់តែប្រសើរឡើង ?"

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៥. សូមរៀបរាប់ជាចំណុចៗ នៃការដកស្រង់សម្ដីដែលបានឆ្លើយសំណួរ "ចូរសរសេរចំណុចមួយ ដែលនឹងធ្វើអ្នកផ្លាស់ប្ដូរទង្វើរបស់ខ្លួន បន្ទាប់ពីទទួលបានព័ត៌មាន និងធនធាននៅក្នុងវេទិកាពិភាក្សានេះ។"

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

៦. សូមរៀបរាប់ជាចំណុចៗ នូវយោបល់ផ្សេងៗ

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

## គ. ការសង្កេតរបស់អ្នកសម្របសម្រួល

ការសង្កេតរបស់អ្នកសម្របសម្រួល គឺជាផ្នែកមួយយ៉ាងសំខាន់ សម្រាប់វាយតម្លៃ និងលើកកម្ពស់សកម្មភាពនានា។ អ្នកសម្របសម្រួលគួរសង្កេតពីរបៀបឆ្លើយតបសំណួររបស់អ្នកចូលរួម របៀបចូលរួមសកម្មភាពក្រុម ចំណាប់អារម្មណ៍របស់អ្នកចូលរួម និងសង្កេតថា តើអ្នកចូលរួមសួរសំណួរដែលជំរុញឲ្យមានការគិតឬអត់។ នេះ គឺជាមធ្យោបាយមួយសម្រាប់ស្ទង់ការឆ្លើយតប ការរៀន និងការប្រែប្រួលឥរិយាបថរបស់អ្នកចូលរួម។

**១. សូមបង្ហាញពីចំណាប់អារម្មណ៍ទូទៅរបស់អ្នក ចំពោះកម្មវិធីបណ្តុះបណ្តាលនេះ។**

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

**២. សូមបង្ហាញអំពីបញ្ហានានា ដែលអ្នកបានជួបប្រទះ។**

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

**៣. តើបញ្ហាសំខាន់ៗអំពីកិច្ចការពារកុមារ ត្រូវបានលើកឡើងឬទេ ?**

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

៤. សូមឲ្យយោបល់ទៅលើកម្រិតយល់ដឹងរបស់អ្នកចូលរួម និងការចូលរួមរបស់ពួកគាត់។

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

៥. តើមេរៀនណាខ្លះ ដែលអ្នកបានដឹងច្បាស់ថា នឹងត្រូវប្រើប្រាស់សម្រាប់កម្មវិធីក្រោយៗទៀត ?

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

៦. តើអាចធ្វើដូចម្តេច ដើម្បីលើកកម្ពស់ការបណ្តុះបណ្តាល និងសម្ភារសម្រាប់បណ្តុះបណ្តាល ?

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

៧. តើចាំបាច់ត្រូវមានការបណ្តុះបណ្តាលបន្ថែមទៀតឬទេ ? សម្រាប់អ្នកណា ? ហេតុអ្វី ?

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

………………………………………………………………………………………………………….

# កំណត់ត្រា

សម្ភារអប់រំផ្សេងទៀត ដែលត្រូវបានបង្កើតឡើងសម្រាប់គម្រោងកុមារភាព ផ្នែកបង្ការ រួមមាន ៖



**រក្សាសុវត្ថិភាពពីការរំលោភបំពានផ្លូវភេទ៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួល សម្រាប់ការអប់រំកុមារ និងមនុស្សវ័យក្មេង



**រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទ៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួលសម្រាប់វេទិកាពិភាក្សា ជាមួយឪពុកម្តាយ និងអ្នកថែទាំ។



**រក្សាសុវត្ថិភាពកុមារពីការរំលោភបំពានផ្លូវភេទក្នុងវិស័យទេសចរណ៍៖**
កញ្ចប់ឧបករណ៍អ្នកសម្របសម្រួល សម្រាប់វគ្គបណ្តុះបណ្តាលក្នុងវិស័យទេសចរណ៍។

ឯកសារនេះក៏មានជាភាសាខ្មែរ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឲ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

កុមារដែលកំពុងធ្វើការ និងរស់នៅក្នុងបរិស្ថានទេសចរណ៍ មានភាពងាយរងគ្រោះជាពិសេស ទៅនឹងការបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ អ្នកតំណាងសហគមន៍ (អ្នកទទួលបន្ទុកនៅក្នុងសហគមន៍ ដែលមានមុខងារកាន់អំណាច ជាអ្នកដឹកនាំ និងអ្នកដែលមានឥទ្ធិពល) មានតួនាទីយ៉ាងសំខាន់ នៅក្នុងការរក្សាសុវត្ថិភាពដល់កុមារ ឲ្យរួចផុតពីការរំលោភបំពាន និងមាននាទីទប់ស្កាត់មិនឲ្យការរំលោភបំពានកើតឡើង ឬមានជាបន្តទៀត។ អ្វីដែលសំខាន់នោះ អ្នកតំណាងសហគមន៍ ទទួលបានព័ត៌មានត្រឹមត្រូវ និងមានសារៈសំខាន់ ស្តីពីការរំលោភបំពានផ្លូវភេទកុមារ។

រក្សាសុវត្ថិភាពកុមារ ពីការរំលោភបំពានផ្លូវភេទ៖ កញ្ចប់ឧបករណ៍អ្នកសម្របសម្រួល សម្រាប់វេទិកាពិភាក្សាជាមួយអ្នកតំណាងសហគមន៍ បានផ្តល់នូវគោលការណ៍ណែនាំនានា ដែលងាយស្រួលអនុវត្តតាម និងផ្តល់ឧបករណ៍ផ្សេងៗដល់អ្នកសម្របសម្រួល ដើម្បីប្រើប្រាស់នៅក្នុងដំណើរការវេទិកាពិភាក្សាមួយ ជាមួយអ្នកតំណាងសហគមន៍។ កញ្ចប់ឧបករណ៍នេះត្រូវបានរចនាឡើង ក្នុងគោលបំណងផ្តល់ចំណេះដឹង និងជំនាញដល់អ្នកចូលរួម ដើម្បីរក្សាសុវត្ថិភាពដល់កុមារ និងមិនឲ្យមានការរំលោភបំពានផ្លូវភេទនៅក្នុងសហគមន៍របស់ពួកគាត់ ហើយសៀវភៅនេះក៏មានអ្វីគ្រប់យ៉ាង ទៅតាមសេចក្តីត្រូវការរបស់អ្នកសម្របសម្រួលដែរ ដើម្បីរៀបចំមេរៀនដែលមានការប្រាស្រ័យទាក់ទងគ្នា ទាំងក្នុងបរិបទផ្លូវការ និងក្រៅផ្លូវការ ជាមួយនឹងសម្ភារតិចតួច និងដោយប្រើប្រាស់បច្ចេកវិជ្ជា។

ឯកសារនេះក៏មានជាភាសាអង់គ្លេស ឡាវ ថៃ និងវៀតណាមផងដែរ ដោយត្រូវបានកែសម្រួលឲ្យស្របទៅតាមបរិបទប្រទេសនីមួយៗ។

**Child Safe Tourism**

Take action against abuse

គម្រោងកុមារភាព គឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងគោលបំណងការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្លូវភេទ នៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ក្នុងប្រទេសកម្ពុជា ឡាវ ថៃ និងប្រទេសវៀតណាម (២០១១-២០១៤)។ គម្រោងកុមារភាពនេះ បាននាំមកនូវកិច្ចសហការគ្នារវាងអង្គការទស្សនៈពិភពលោក និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម។ កម្មវិធីបានផ្តោតទៅលើទាំងផ្នែកទប់ស្កាត់ និងការការពារ។

Australian Aid

World Vision®